# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣១ លេខ ៦ ខែមិថុនា

ព.ស. ២៥០២ គ.ស. ១៩៥៩

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា* — *បញ្ជីរឿង* — *ទំព័រ*


- មលធម្មកថា របស់ព្រះមហា ឡាច-ស៊ុមេធ . . . . . . . . ៦០៩
- ភេគចិត្ត លោក ស៊ុន-ហ៊ាន រៀបរៀង . . . . . . . . . . ៦១៧
- សុវណ្ណជាតក ( តមក ) លោក ថង-វង់ ចម្លងពីសាស្ត្រាស្លឹករឹត . . . . ៦២៣

*ផ្នែកអក្សរសាស្ត្រ*

- រឿងបព្ពសិទ្ធិ (តចប់) របស់ហ្លួងភក្ដីអក្សរ គង់ លោក ប៊ូ-ប៊ី ចំឡងពីសាស្ត្រាស្លឹករឹត ៦៣៥
- រឿងប្រយោជន៍មនុស្សដោយភិយម្លូបាយរកកត់ លោក ស៊ុន-ហ៊ាន រៀបរៀង . ៦៤២
- រឿងហង្សយន្ត (តមក) លោក អ៊ឹម-កេង ចម្លងពីសាស្ត្រាស្លឹករឹត . . . . ៦៤៧
- វត្តព្រៀងតំណាង លោក ស្រី-អ៊ូ រៀបរៀង . . . . . . . . ៦៦៩
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . . . . . . ៦៧០

*ផ្នែកកំណត់ទីដប្រវត្តិការណ៍*

- ពិធីបើកការសិក្សានៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងពិធីសម្ពោធគ្រឹះស្ថាន
  ព្រះសីហនុ លោក ថង-វង់ រៀបរៀង . . . . . . ៦៨៩
- វចនានុក្រមសំស្ក្រឹត-ខ្មែរ ( តមក ) ព្រះមហា ប៉ាង-ខាត់ រៀបរៀង. . . . ៧៦១



ប្រចាំឆ្នាំទី ១២ សៀវភៅ ដំឡៃផាវី ២៣០១០០

# KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

## sommaire

### Partie religieuse :


—Maladhammakatha par Préah Moha LACH SOMEDH . . . 605
—Les souffrances psychologiques par M. SIN HEAN . . . . 617
—Surabajataka (suite) relevé du manuscrit sur feuilles de latanier par M. THANG-VONG . . . . . . . 623


### Partie littéraire :


—Histoire de Sabbasiddhi (suite et fin) par Phakdei Aksar TAN revue et corrigée par M. BOU-PO . . . . . . 635
—La Correction par cent coups de rotin par M. SIN-HEAN . 642
—Histoire de Hang-Yon (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON . . . . . . . 647
—Les Objets symboliques selon les traditions khmères par M. SREY-OU . . . . . . . . . 665
—Histoire de Sam Kok (suite) par l'Oknha NOU-KAN . . . 670


### Notes et Chroniques :


—Cérémonie d'Ouverture de l'Université Bouddhique Préah Sihanouk Raj par M. THANG VONG . . . . . 689
—Dictionnaire Sanskrit-Khmer (suite) par vén. PANG-KHAT . 716



Prix d'abonnement annuel (comprenant 12 numéros): 230$00 .

ផ្នែកសាសនា

# មលធម្មកថា

ព្រះមហា ឡាច-សុមេធ វត្តឧណ្ណាលោម រៀបរៀង

## នមោ ៣ បទ

មហាការុណិកំ នាថំ ធម្មញ្ច វិមលំ វរំ
វន្ទេ អរិយសង្ឃញ្ច ទក្ខិណេយ្យំ និរន្តរំ ។

សូមថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកបដោយមហាករុណាធិគុណផង ព្រមទាំងព្រះធម៌ដែលប្រាសចាកមន្ទិលដ៏ប្រសើរផង ព្រមទាំងព្រះអរិយសង្ឃជាទក្ខិណេយ្យបុគ្គល មិនមានរាគាទិកិលេសក្នុងសន្តានផង (ដោយសេចក្ដីគោរព) ។

ពេលនេះ សូមសំដែងអំពីមលធម៌ ៨ យ៉ាង ដែលមានពុទ្ធភាសិតក្នុងគម្ពីរធម្មបទខុទ្ទកនិកាយត្រង់មលវគ្គ ដូចមានមាតិការៀបរៀងក្នុងទីនេះគឺ:

១– អសជ្ឈាយមលា មន្តា មន្តទាំងឡាយ មានការមិនស្វាធ្យាយជាមន្ទិល ។

២– អនុដ្ឋានមលា ឃរា ផ្ទះទាំងឡាយ មានការមិនជួសជុល មិនថែទាំជាមន្ទិល ។

៣– មលំ វណ្ណស្ស កោសជ្ជំ សេចក្ដីខ្ជិល ជាមន្ទិលរបស់សម្បុរ ។

៤- បមាទោ រក្ខតោ មលំ សេចក្ដីធ្វេសប្រហែស ជាមន្ទិលរបស់បុគ្គលអ្នករក្សា (ទ្រព្យ) ។

៥- មលិត្ថិយា ទុច្ចរិតំ ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់ស្ត្រី ។

៦- មច្ឆេរំ ទទតោ មលំ សេចក្ដីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ ។

៧- មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច បាបធម៌ទាំងឡាយ ជាមន្ទិលក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

៨- តតោ មលា មលតរំ អវិជ្ជា បរមំ មលំ អវិជ្ជាជាមន្ទិលដ៏ក្រៃលែង ជាងមន្ទិលទាំងនោះទៅទៀត ។

ត្រង់មាតិកាទី ១ ថា «មន្តទាំងឡាយ មានការមិនស្វាធ្យាយជាមន្ទិល», អធិប្បាយថា: បណ្ដាមន្ត គឺវិជ្ជាទាំងអស់ក្នុងលោកនេះ ទោះវិជ្ជាខាងផ្លូវលោក ដូចជាអក្សរសាស្ត្រនិងវិជ្ជាហត្ថកម្ម ការជាងឈើ ជាងដែកជាដើមក្ដី ឬវិជ្ជាខាងផ្លូវធម៌ ដូចជាធម្មវិន័យ បរិយត្តិសាសនា ជាដើមក្ដី សូម្បីវិជ្ជាណាមួយ បុគ្គលមិនបានសិក្សារៀនសូត្រសោះ ឬបានសិក្សារៀនសូត្រ ចេះចាំស្ទាត់ប្រាកដហើយដែរ ប៉ុន្តែខ្ជិលច្រអូស មិនយកចិត្តទុកដាក់ព្យាយាមរំលឹកបន្ថែមទៀតទេ ឬ មិនបានយកចំណេះដែលខ្លួនរៀនចេះដឹងហើយនោះ មកប្រកបប្រើការទេ យូរទៅនឹងនាំឲ្យ

ក្លាយទៅជាមន្ទិល គឺៈ ភ្លេចសូន្យឬបាំស្រពិចស្រពិល ប្រើការមិនកើត បុគ្គលខ្ជិលនោះ ក៏ធ្លាក់ខ្លួនទៅជាមនុស្សល្ងង់ខ្លៅ ; ធម្មតាមនុស្សល្ងង់ឥតចំណេះ ឈ្មោះថា បានសេចក្តីទុក្ខលំបាក ខ្សត់ក្រកំព្រាសូន្យសព្វទាំងអស់ ។

ចំណែកខាងអ្នកមានចំណេះវិជ្ជា ឈ្មោះថាបានសេចក្តីសុខ សេចក្តីចំរើនយ៉ាងប្រសើរ ព្រោះវិជ្ជា អាចឲ្យសម្រេចប្រយោជន៍ច្រើនយ៉ាង យោងខ្លួនឲ្យបានឃ្លាតពីកិលេសទុគ្គតជន ទាំងបំភ្លឺគំនិតឲ្យយល់ត្រូវយល់ល្អផង ជាសម្បត្តិមួយយ៉ាងស្រាលអាស្រ័យនៅនឹងខ្លួនបាន លោកទុកជាកំណប់ទ្រព្យមួយដ៏សំខាន់ ហៅថា អង្គិសមទិធិ "កំណប់ទ្រព្យស្មើដោយអង្គកាយ", សូម្បីទៅកាន់ទីឋានណា ៗ មិនបាច់ប្រែក-ស្រែង-លី-ពុន-វេច-ខ្ចប់ ឬព្រួយទីងការទុកដាក់ឡើយ ចោរលួចយកក៏មិនបាន ជាវិជ្ជាឲ្យសុខភាពនឹងវឌ្ឍនភាព ទាំងបច្ចុប្បន្នជាតិនេះនឹងបរលោក; សេចក្តីនេះ សមដូចសុភាសិតក្នុងគម្ពីរលោកនីតិថា.

សិប្បសមំ ធនំ នត្ថិ  សិប្បំ ចោរា ន គណ្ហន្តិ
ឥធ លោកេ សិប្បំ មិត្តំ  បរលោកេ សុខាវហំ ។

មានទ្រព្យមិនស្មើមានវិជ្ជា  វិជ្ជាចោរលួចយកមិនបាន
វិជ្ជាទុកជាមិត្រសន្តាន  ក្សាន្តក្នុងឥធលោកយោគបរលោក ។

វិជ្ជាជារបស់ថ្លៃថ្នូរយ៉ាងសំខាន់ អាចឲ្យប្រយោជន៍នឹងសេចក្តីសុខគ្រប់ប្រការ ដល់ខ្លួនប្រាណយ៉ាងនេះ បានជាត្រូវរៀន មិនត្រូវ

ដំអក់ទំរន់ទំលាក់ក្រាញ ដោយអាងហេតុផ្សេងៗ ក្រៅពីការរៀន ព្រោះប្រាជ្ញាអាប់ស្មារតីទន់នោះទេ ។

ម្យ៉ាងទៀត សូម្បីអ្នកមានទ្រព្យសម្បត្តិច្រើនស្រាប់ហើយក៏មិនត្រូវគិតថា ការរៀនវិជ្ជាប្រាជ្ញានឹងរកទ្រព្យ ចុះបើមានទ្រព្យហើយ ចាំបាច់រៀនធ្វើអ្វីទៀត! គំនិតយ៉ាងនេះក៏មិនត្រូវដែរ ព្រោះថាទ្រព្យដែលនឹងគង់នៅបាន ឬនឹងកើតចំរើនឡើងបាន អាស្រ័យដោយមានវិជ្ជា វិជ្ជាទុកដូចជាដើមពានសម្រាប់ទ្រ ឬទុកដូចជាសាសម្រាប់ចាក់ទុកដាក់ទ្រព្យសម្បត្តិដែលគេបានមក ឯមនុស្សឥតចំណេះនឹងរកទ្រព្យក៏មិនគង់ នឹងរកទ្រព្យសម្បត្តិក៏បានដោយកម្រពេកណាស់ ទ្រព្យសម្បត្តិរបស់មនុស្សដែលឥតចំណេះ ដូចគ្នានឹងរបស់ដែលនៅលើដៃមនុស្សវិកលចរិត សូម្បីគេបោកប្រាស់មុខក្រោយក៏មិនដឹង ។ អ្នកឥតចំណេះ ទុកដូចជាចំណី ឬយានជំនិះរបស់អ្នកមានចំណេះប្រាជ្ញា មនុស្សល្ងង់បើទុកជាមានរូបសមរម្យល្អ ក៏ឃើញល្អតែក្នុងវេលាមិនទាន់ហាមាត់និយាយ បើហាមាត់ឡើងនិយាយវេលាណា ក៏បាត់ល្អ អស់រសជាតិ អស់ថ្លៃថ្នូរវេលានោះ ។

ធម្មតាមនុស្ស ទោះបីមានប្រាជ្ញាស្មារតីឥតអាប់ទន់ខ្សោយយ៉ាងណាក៏ដោយ ឲ្យតែមានព្យាយាមខំប្រឹងរៀន គង់ពេះខួរមិនខាន, សមដូចសុភាសិតក្នុងគម្ពីរលោកនីតិថា:

អប្បកំ នាតិមញ្ញេយ្យ ចិត្តេន ឋាបយេ សុតំ
វម្មិកោទកពិន្ទូវ ចិរេន បរិបូរតិ ។

សេចក្ដីថា: បុគ្គលកុំមើលងាយថា ប្រាជ្ញារបស់ខ្លួនតិចតួចស្ដួចស្ដើងឡើយ គប្បីញុំាងគិច្ច គឺការស្ដាប់នឹងការរៀនឲ្យឋិតនៅជានិច្ចក្នុងសន្ដានចិត្ត យូរទៅគង់នឹងពេញបរិបូណ៌ដោយវិជ្ជាពុំខាន ប្រៀបដូចជាក្អមដែលគេយកទៅដាក់លើដំបូល វេលាភ្លៀងធ្លាក់ចុះមក ចូលក្នុងក្អមម្ដងមួយដំណក់ៗ យូរទៅក្អមនោះឯង គង់នឹងពេញៈដោយដំណក់ទឹកភ្លៀងមិនខាន ក៏ដូច្នោះដែរ ។

ម្យ៉ាងទៀត វិជ្ជាណាមួយដែលឥតទោសទោះបីតិចតួច តូចតាចថយថោក យ៉ាងណាក៏ដោយ. បើមានឱកាសល្មមខ្សៀតរៀនបាន ក៏គួរតែរៀនឲ្យចេះ ព្រោះសុទ្ធតែមានប្រយោជន៍ទាំងអស់ ។ មានសុភាសិតក្នុងគម្ពីរលោកនីតិប្រដៅទុកថា:

ថោកោតិ នាតិមញ្ញេយ្យ វិជ្ជំ វា សិប្បមត្តំ វា
ឯកំបិ បរិយោទាតំ ជីវិតកប្បការណំ ។

សេចក្ដីថា: បុគ្គលកុំគប្បីមើលងាយមន្ដសិល្បសាស្ដ្រវិជ្ជា ដោយគិតថា វិជ្ជាតូចតាច បន្តិចបន្តួច រៀនទៅក្រែងមិនសម្រេចប្រយោជន៍ សូម្បីវិជ្ជាតែមួយ បើបានរៀនចេះចាំស្ទាត់ប្រាកដហើយ គង់នឹងសម្រេចផលប្រយោជន៍ ក្នុងការចិញ្ចឹមជីវិតមិនខាន ។

វិជ្ជា គឺសេចក្ដីចេះដឹងគ្រប់យ៉ាង ដែលហុចប្រយោជន៍នឹងសេចក្ដីសុខមកឲ្យនោះសោត ក៏ត្រូវតែនឿយហត់ដោយការប្រឹងហាត់ ប្រឹងរៀនជាមុនសិនដែរ ទើបបានចេះ បើមិនខំរៀនក៏មិនចេះ, សមដូចបុរាណភាសិតប្រដៅថា: «ចេះមកពីរៀន មានមកពីរក, មិនរកមិនមាន មិនរៀនមិនចេះ" ។

បណ្ដាវិជ្ជាខាងផ្លូវលោកក្ដី ខាងផ្លូវធម៌ក្ដី វិជ្ជាណាមួយ អ្នករៀនៗមិនប្រាកដ ចាប់នេះបន្តិច ចាប់នោះបន្តិច ចោលៗ ត្រង់ណោះមួយចុប ត្រង់ណោះមួយចុប មិនប្រាកដដោយមុខវិជ្ជាណាមួយសោះ ពុំនោះសោត រៀនចេះដឹងស្ទាត់ប្រាកដហើយ ប៉ុន្តែមិនបានព្យាយាមរំលឹកបន្ថែមទៀតទេ ឬមិនយកវិជ្ជានោះមកប្រើការទេ មុខតែនឹងទៅជាមន្ទិល ជាទោស គឺភ្លេចបាត់ប្រើការមិនកើត ។ ព្រោះហេតុនោះ បានជាព្រះបរមលោកនាថ ទ្រង់សំដែងថា "អសជ្ឈាយមលា មន្តា មន្តទាំងឡាយមានការមិនស្វាធ្យាយជាមន្ទិល" ។

ត្រង់មាតិកាទី ២ ថា "ផ្ទះទាំងឡាយ មានការមិនជួសជុល មិនថែទាំជាមន្ទិល", អធិប្បាយថា: គេហដ្ឋានជាលំនៅ ដែលយើងនៅអាស្រ័យជាប្រក្រតីមិនអើពើថែទាំ បណ្ដោយឲ្យស្មោកគ្រោកដោយភក់ជ្រាំ ខាងក្រោមផ្ទះ ឬធូលីសំរាមសំរេចពាសពេញក្នុងផ្ទះខាងក្រៅផ្ទះ និងសម្បុកពីងពាង ប្រែងភ្លើងរុំខ្មៅពន្លត់ពីលើពីក្រោមស្រះគេកស្រកាកក្នុងផ្ទះ

ឬផ្ទះនោះលេចបាក់បែកធ្លាយធ្លុះទទ្រេតទទ្រោត មិនជួសជុលមិនសំអាតទេ ជាហេតុនាំឲ្យទៅជាមន្ទិលសៅហ្មង គឺបណ្ដាលឲ្យកើតអន្តរាយ ឬកេតផ្សេងៗ ដល់មនុស្សអ្នកនៅក្នុងផ្ទះមិនខាន ។ ចំណែកខាងបព្វជិតកិច្ចប្រព្រឹត្តតាមន័យនេះដូចគ្នាដែរ ។ ព្រោះហេតុនោះ បានជាព្រះលោកុត្តមាចារ្យ ត្រាស់សំដែងថា "អនុដ្ឋានមលា ឃរា ផ្ទះទាំងឡាយមានការមិនថែទាំ មិនជួសជុល ជាមន្ទិល" ។

គ្រង់មាតិកាទី ៣ ថា "សេចក្ដីខ្ជិលជាមន្ទិលរបស់សម្បុរ", អធិប្បាយថា បុគ្គលជាគ្រហស្ថក្ដី បព្វជិតក្ដី ប្រកបដោយសេចក្ដីខ្ជិលច្រអូស កាលបើពង់កាយប្រឡាក់ប្រឡូសដោយមន្ទិល គឺធូលីក្អែល ឬ បែកញើសហូរចេញមកអាប់អួធុំក្លិនអាក្រក់ហើយ មិនបានលាងជំរះដោយទឹក និងគ្រឿងលុបលាងទេ ជាហេតុនាំឲ្យទៅជាមន្ទិលសៅហ្មង គឺមានសម្បុរកាយអាក្រក់ បណ្ដាលទៅជាកេតផ្សេងៗ មានបុសបមកមរមាស់ជាដើម ពុំនោះសោត សំពត់ឬចីវរជាគ្រឿងសម្រាប់ស្លៀកពាក់ ប្រឡាក់ញើសក្អែលអាប់អួ មិនសោរបោកគក់លាងហាល ធ្វើឲ្យស្អាតបាតទេ ជាហេតុនាំឲ្យទៅជាមន្ទិលសៅហ្មង គឺមានពណ៌សម្បុរអន់អាប់អាក្រក់ ធុំក្លិនអសោចដល់អ្នកដទៃ ឆាប់ចាស់ ឆាប់រហែក, នេះជាទោសមកតែ

អំពីសេចក្ដីខ្ជិលច្រអូសនឹងឯង ។ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគសំដែងថា "មលំ វណ្ណស្ស កោសជ្ជំ សេចក្ដីខ្ជិលជាមន្ទិលរបស់សម្បុរ " ។

ត្រង់មាតិកាទី ៤ ថា "សេចក្ដីធ្វេសប្រហែសជាមន្ទិលរបស់បុគ្គលអ្នករក្សា (ទ្រព្យ)", អធិប្បាយថា បុគ្គលអ្នករក្សាទ្រព្យសម្បត្តិមានវិញ្ញាណ មានគោ, ក្របី, សេះជាដើម, ទ្រព្យឥតវិញ្ញាណ មានសំលៀកបំពាក់ជាដើម ជាអ្នកប្រកបដោយសេចក្ដីធ្វេសប្រហែស រវល់តែដេកឬរវល់តែដើរលេងមិនថែទាំប្រុងប្រយ័ត្ន បណ្ដោយឲ្យគោ, ក្របីទាំងនោះរត់បាត់ទៅ ឬអន្តរាយដោយម្រឹគសាហាវចាប់ធ្វើចំណី នឹងចោរលួចជាដើម បើមិនដូច្នោះទេ គោក្របីនោះឯងចូលទៅស៊ីដំណាំរបស់គេ ៗ ក៏ចាប់យកទៅប្ដឹងផ្ដល់ពិន័យលក់ជាសំណងសងទ្រព្យធនធាន ឬខ្លួនឯងដល់នូវពិន័យទោសថែមទៀត ពុំនោះសោត ត្រូវគេជេរប្រទេចផ្ដាសាផ្សេងៗ ក៏មាន ។

ម្យ៉ាងទៀត ទ្រព្យសម្បត្តិសម្រាប់ប្រើប្រាស់ក្នុងផ្ទះគឺគ្រឿងឧបភោគនឹងគ្រឿងបរិភោគ មិនចេះរៀបចំទុកដាក់ឲ្យមានសណ្ដាប់ធ្នាប់ បណ្ដោយឲ្យពុកពុយរាត់រាយទៅដោយហេតុផ្សេង ៗ ទ្រព្យទាំងនោះ ក៏នឹងដល់នូវសេចក្ដីវិនាសអន្តរាយ មានចោរលួចជាដើម ទាំងនេះក៏ជាហេ

មកតែអំពីមន្ទិល គឺសេចក្ដីធ្វេសប្រហែស ឥតគំនិតហ្នឹងឯង ។ បើចំណែកខាងបព្វជិតវិញ គឺមានការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន មិនគ្រប់គ្រងក្រសង្រួមទ្វារជាដើម បើកឱកាសឲ្យសត្រូវ គឺកិលេសមានរាគៈជាដើម ចូលមកញាំញីគ្របសង្កត់បង្កិលចិត្តនៃបព្វជិតនោះ ឲ្យហិនប្រព្រឹត្តធ្វើនូវអំពើអាក្រក់ផ្សេងៗ មានគរុកាបត្តិជាដើម ដែលជាអំពើមិនសមគួរដល់សមណៈភេទ ។ ព្រោះហេតុនោះ បានជាព្រះអរហំសម្មាសម្ពុទ្ធទ្រង់សំដែងថា " បមាទោ រក្ខតោ មលំ សេចក្ដីធ្វេសប្រហែស ជាមន្ទិលរបស់បុគ្គលអ្នករក្សាទ្រព្យ " ។

ត្រង់មាតិកាទី ៥ ថា " ការប្រព្រឹត្តិអាក្រក់ ជាមន្ទិលរបស់ស្ត្រី ", អធិប្បាយថា ស្ត្រីណាដែលប្រព្រឹត្តក្បត់ចិត្តស្វាមីរបស់ខ្លួន គឺថាខ្លួនមានគូស្រករស្វាមីពេញលក្ខណៈច្បាប់ហើយ មិនស្កប់ស្កល់ មានចិត្តលោភទៅលើបុរសផ្សេងទៀត, ការប្រព្រឹត្តិខុសប្រវេណីយ៉ាងនេះ ឈ្មោះថាជាមន្ទិលលាមកអាក្រក់បំផុតរបស់ស្ត្រីនោះ ។ ចំណែកខាងបុរសជាស្វាមីកើតវិប្បដិសារីសេចក្ដីស្ដាយក្រោយក្ដៅក្រហាយ ទៅជាកើតរឿងទាស់ទែងលែងលះគ្នា បណ្ដេញស្ត្រីជាភរិយានោះ ឲ្យចេញចាកត្រកូលរបស់ខ្លួន ស្ត្រីនោះឯង ក៏ទៅជាមនុស្សអនាថាឥតទីពឹង ដល់នូវសេចក្ដីទុក្ខលំបាក

គ្រប់យ៉ាង ៗ ព្រោះហេតុនោះ បានជាសម្តេចព្រះអនាវរណញ្ញាណ ទ្រង់ត្រាស់ថា " មលិត្ថិយា ទុច្ចរិតំ ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់ស្ត្រី " ។

ត្រង់មាតិកា ទី៦ ថា "សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ", អធិប្បាយថា បុគ្គលមានចាគចិត្តបំរុងនឹងលះវត្ថុអ្វីមួយឲ្យទៅជាទាន តែដោយអំណាចមច្ឆេរចិត្ត គឺចិត្តកំណាញ់កើតឡើងកាំងស្កាត់ដំណើរចាគចិត្ត មិនឲ្យលះបង់ទៅកើត តួយ៉ាងដូចជាបុគ្គលអ្នកធ្វើស្រែឬធ្វើជំនួញជាដើម វេលាកំពុងធ្វើមានគំនិតគិតថា របរស្រែឬជំនួញដែលអាត្មាអញធ្វើនេះ កាលណាផលប្រយោជន៍បានសម្រេចហើយ នឹងបរិច្ចាគទ្រព្យធ្វើជាទានក្នុងកាលនោះមិនខាន ។ លុះវេលាផលប្រយោជន៍បានសម្រេចហើយ ស្រាប់តែមច្ឆេរចិត្ត គឺចិត្តកំណាញ់កើតឡើងកាំងគំនិតបែរទៅជាគិតថា បុះបើអញចំណាយទ្រព្យនោះៗ ធ្វើជាទានអស់ទៅ ខ្លួនអញក្តី ប្រពន្ធកូនរបស់អញក្តី នឹងបានអ្វីចិញ្ចឹមជីវិត នឹងបានអ្វីប្រើប្រាស់ក្នុងគ្រួសារ នឹងបានអ្វីទុកការពារទៅមុខ ។ កាលបើមច្ឆេរចិត្តដ៏មានកម្លាំងកើតឡើង គ្របសង្កត់ចាគចិត្តមិនឲ្យងើបរួចឡើងដរាបណា បុគ្គលនោះឯងឈ្មោះថាឃ្លាតខានបានទទួលអំណោយផល ដែលកើតអំពីការបរិច្ចាគ

ទានដកបនោះ ។ ព្រោះហេតុនោះ បានជាព្រះលោកុត្តមាចារ្យត្រាស់ ថា "មច្ឆេរំ ទទតោ មលំ សេចក្ដីកំណាញ់ជាមន្ទិលរបស់អ្នកឲ្យ ។

ត្រង់មាតិកាទី ៧ ថា "បាបធម៌ ជាមន្ទិលក្នុងលោកនេះផង និងលោកខាងមុខផង", អធិប្បាយថា បាបធម៌ជាធម៌ដ៏លាមកប៉ែកខាងអកុសល ដែលបុគ្គលប្រព្រឹត្តអាក្រក់ដោយកាយ, វាចា, ចិត្ត រាប់បញ្ចូលក្នុងអកុសលកម្មបថទាំង ១០ ឬក្នុងឧបក្កិលេសទាំង ១៦ មានអភិជ្ឈាវិសមលោភៈ ជាដើម ហៅថាបាបធម៌ ។ ធម្មតាអំពើអាក្រក់ដែលបុគ្គលធ្វើហើយ កុំថាឡើយដល់ទៅអំពើធំ ៗ សូម្បីតែអំពើតូច ៗ ក៏មិនកំបាំងបាត់ស្ងាត់ដែរ បើទុកជាកំបាំងបាត់ក្នុងលោកនេះ ទៅលោកខាងមុខគង់តែឃើញជាក់ស្ដែងដោយខ្លួនឯងមិនខាន ជួនកាលក៏ឃើញជាក់ស្ដែងក្នុងលោកនេះ លុះទៅកាន់លោកខាងមុខ ក៏ឃើញជាក់ស្ដែងទៀត ។ ព្រោះហេតុនោះ បានជាព្រះសយម្ភូញាណទ្រង់សំដែងថា "មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច បាបធម៌ទាំងឡាយ ជាមន្ទិលក្នុងលោកនេះផង ក្នុងលោកខាងមុខផង" ។

ត្រង់មាតិកាទី ៨ ថា "អវិជ្ជា ជាមន្ទិលដ៏ក្រៃលែង ជាងមន្ទិលទាំងនោះទៅទៀត", អធិប្បាយថា សេចក្ដីមិនចេះមិនដឹងល្អិតល្អន់វង្វេង មិនយល់ការពិតនឹងឯង ហៅថា អវិជ្ជា ។ អវិជ្ជានេះ ជាដើមអាទិ ដើម

បម ធ្វើមនុស្ស-សត្វឲ្យលង់ វង្វេងក្នុងគំនិត មិនយល់សេចក្តីពិតតាមគតិលោក និងគតិធម៌ ៗ បើនិយាយដល់ថ្នាក់ជាន់ខ្ពស់ គឺមិនដឹងនូវហេតុ ៨ យ៉ាង មានមិនដឹងថា នេះជាទុក្ខ, នេះជាហេតុនាំឲ្យកើតទុក្ខ, នេះជាឧបាយនាំឲ្យរលត់ទុក្ខ, នេះជាបដិបទា ដំណើរនាំឲ្យដល់នូវសេចក្តីរលត់ទុក្ខជាដើម ៗ ព្រោះហេតុនោះ បានជាព្រះបរមសាស្តាទ្រង់ត្រាស់សំដែងថា "តតោ មលា មលតរំ អវិជ្ជា បរមំ មលំ អវិជ្ជាជាមន្ទិលដ៏ក្រៃលែង ជាងមន្ទិលដូចបានពោលមកហើយនោះទៅទៀត ៗ

ដំណើរនេះ គួរអស់លោកជាពុទ្ធបរិស័ទ ទាំងឡាយលះបង់នូវធម៌ជាមន្ទិលឲ្យបានផុតស្រឡះអំពីខ្លួនចេញ ដូចបានសំដែងមកហើយនេះ គង់នឹងបានជួបប្រសព្វ ឬពេបពះប្រទះ នូវសុខភាពនិងវឌ្ឍនភាពគ្រប់ប្រការ ក្នុងបច្ចុប្បន្នជាតិនិងអនាគតជាតិ ជាលំដាប់តទៅពុំខាន ៗ

បញ្ចប់ធម្មទេសនា ដោយសង្ខេបត្រឹមប៉ុណ្ណោះឯង

---

# រោគចិត្ត

លោក ស៊ុន - ហ៊ាន រៀបរៀង

សភាពដែលធ្វើចិត្ត ឲ្យសៅហ្មង ឲ្យកករល្អក់ ឲ្យក្តៅក្រហាយ ឲ្យអន្ទះអន្ទែងជាដើម ហៅថា រោគចិត្ត ។

ពាក្យថា "រោគចិត្ត" នេះ គង់មានជនខ្លះស្ញើងត្រចៀកពុំខាន ព្រោះមនុស្សភាគច្រើនតែងយល់ថា អ្នកដែលកើតរោគចិត្ត គឺមនុស្សមានសតិវិបល្លាស ឬមនុស្សឆ្កួតដែលនៅក្នុងមន្ទីរពេទ្យព្យាបាលរោគចិត្តនោះ តែបើពិចារណាតាមគោលនៃព្រះពុទ្ធសាសនា មនុស្សដែលមានរោគចិត្ត ពុំមែនសំដៅយកមនុស្សមានសតិវិបល្លាសនោះទេ គឺសំដៅយកបុថុជ្ជនអ្នកមានកិលេសតណ្ហា, ឯអ្នកដែលគ្មានរោគចិត្ត មានតែព្រះអរហន្តដែលលះកិលេសអស់ហើយប៉ុណ្ណោះ ។ ធម្មជាតដ៏ពិតប្រាកដរបស់ដួងចិត្តនោះ បរិសុទ្ធស្អាតណាស់ បើពុំមានរោគអ្វីមកបៀតបៀនទេ, វត្ថុដែលធ្វើឲ្យដួងចិត្តក្លាយពីសភាពដើមនោះ ខាងភាសាបាលីហៅថា "ឧបក្កិលេស" គ្រឿងសៅហ្មងចិត្ត ឬគ្រឿងធ្វើចិត្តឲ្យមានពណ៌ស្រអាប់ពុំមានពន្លឺ ។

រោគចិត្ត មានលក្ខណៈប្រហែលគ្នានឹងរោគផ្លូវកាយ, រាងកាយរបស់មនុស្ស បើចេះរក្សាតាមច្បាប់អនាម័យ, ឧស្សាហ៍ហាត់ពង្រឹងកម្លាំង, ចេះបរិភោគអាហារ ដែលជាប្រយោជន៍ដល់រាងកាយ នឹងទទួលបានថ្នាំព្យាបាលរោគ, អ្នកដែលចេះរក្សារាងកាយដូច្នេះ ការឈឺចាប់ពុំមានឱកាស

ទឹងចូលមកបៀតបៀនបាន, ឯរោគចិត្តក៏មានលក្ខណៈដូចគ្នា បើបេះវិធីរក្សាចិត្តរបស់ខ្លួន ចិត្តក៏មិនអាចមានរោគទៅបាន តែការព្យាបាលរោគចិត្តលំបាកជាងការព្យាបាលរោគផ្លូវកាយ ព្រោះរោគផ្លូវកាយពេទ្យអាចនឹងពិនិត្យទៅឃើញសមុដ្ឋានរោគ ហើយព្យាបាលឲ្យសះជាបានដោយងាយ ឯរោគចិត្តជារោគ ដែលពេទ្យពិនិត្យទៅឃើញបានដោយកម្រណាស់, មនុស្សខ្លះសូម្បីកើតរោគចិត្ត ក៏មិនដឹងថាខ្លួនកើតមានរោគចិត្តផង ។ រោគដែលនឹងចូលមកបៀតបៀនចិត្តមានច្រើនណាស់ទឹងប្រមាណមិនបាន តែកាលបើរួបរួមពោលចំពោះតែរោគចិត្តប្រភេទធំៗ មាន ៣ យ៉ាងគឺ :

១– រោគស្រឡាញ់,

២– រោគស្អប់,

៣– រោគវង្វេង,

រោគស្រឡាញ់បានដល់ពួកៈ ដែលលោមឡំដោយកិលេសតណ្ហា មានពិសក្ដៅក្រហាយណាស់, ព្រះសម្ពុទ្ធទ្រង់ត្រាស់ថាជាភ្លើងមួយយ៉ាង ដែលដុតកំដៅចិត្តឲ្យក្ដៅក្រហាយក្រវល់ក្រវាយជានិច្ច, សេចក្ដីស្រឡាញ់ ទើបថាជារោគចិត្តមួយបែប ។ បុគ្គលដែលមានរោគស្រឡាញ់ សង្កេតឃើញនូវអាការដែលសំដែងចេញមកផ្លូវកាយ ដូចស្រីក្រមុំ ហ៊ឺហាខ្ជះខ្ជាយទ្រព្យសម្បត្តិក្នុងការតែងខ្លួនប្រាណ មិនស្គាល់ប្រមាណខ្លួន ទោះបីខ្លួនមាន

ហានៈក្រឡេត កំមិនបានទឹកដល់ដៃ សុំឲ្យតែបានតែងខ្លួនយ៉ាងហ៊ឺហា ប៉ុណ្ណោះក៏ហើយគ្នា ។ ប្រុសកម្លោះសំដែងខ្លួនជាអ្នកចំណូលខាងស្រី កាលបើបានជួបប្រទះភេទនេះ ក៏ព្យាយាមសំដែងអាការ ឬនិយាយលួងលោម ជាអ្នកចំណូលហួសហេតុ ។ ឪពុកម្ដាយដែលស្រឡាញ់កូនខ្លាំងពេកបើកអំណាចតាមចិត្តកូនគ្រប់យ៉ាង ធ្វើឲ្យកូនមាននិស្ស័យជាអ្នកទំរើសជាអ្នកខ្ជះខ្ជាយហ៊ឺហា, អាការទាំងនេះឯង ជាអាការរបស់រោគស្រឡាញ់ដែលសំដែងចេញមកឲ្យប្រាកដខាងក្រៅ ។

រោគស្អប់ ជារោគចិត្តមួយបែប ដែលបង្កសេចក្ដីក្ដៅក្រហាយ, មនុស្សដែលកើតរោគស្អប់ គេសង្កេតឃើញបានដល់មនុស្សដែលខឹងឆាប់ ចិត្តច្រើនមានមុខក្រមឹងកល់ពេលវេលា និយាយបះបោះបញ្ចេញទៅមិនពិគេះដល់គ្រាបៀក ។ មនុស្សខ្លះកើតរោគស្អប់ខ្លាំងឡើង បានទៅវាយកាប់សម្លាប់គ្នាក៏មាន ។

រោគវង្វេង ជារោគចិត្តមួយបែបទៀត, អាការរបស់មនុស្សដែលកើតរោគវង្វេង គឺការភ្លេចមុខ ភ្លេចក្រោយ ច្រើននិយាយផ្ដេសផ្ដាសគ្មានសារប្រយោជន៍, ទាំងនេះឯងជាអាការរបស់រោគវង្វេង ។

រោគចិត្ត ៣ បែប គឺ រោគស្រឡាញ់, រោគស្អប់និងរោគវង្វេងនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានឱសថ ៣ បែប ទុកសម្រាប់ព្យាបាលរោគចិត្ត គឺ ប្រទានអសុភកម្មដ្ឋាន សម្រាប់ព្យាបាលរោគស្រឡាញ់, ប្រទានមេត្តា

ព្រហ្មវិហារ សម្រាប់ព្យាបាលភេទស្អប់ នឹងប្រធានអានាបាណស្សតិ សម្រាប់ព្យាបាលភេទវង្វេង ។

ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានអសុភកម្មដ្ឋាន ទុកឲ្យរក្សាភេទស្រឡាញ់នោះ ព្រោះទ្រង់យល់ឃើញថា ភេទស្រឡាញ់ត្រូវព្យាបាលដោយឱសថដែលជាសត្រូវនឹងគ្នា ។ អសុភកម្មដ្ឋានជាកម្មដ្ឋានមួយបទក្នុងកម្មដ្ឋាន ៤០ ប្រែថា « ការពិចារណាឃើញថាមិនស្អាតគួរខ្ពើមឆ្អើម » ។ មនុស្សដែលកើតភេទស្រឡាញ់ គួរចំរើនកម្មដ្ឋានបទថា មិនស្អាតនេះ គឺកុំឲ្យសម្លឹងមើលទៅឃើញសុទ្ធតែល្អទាំងអស់ខ្លាំងពេក ដូចស្រីក្រមុំចូលទៅក្នុងរានផ្សារ កុំឲ្យសម្លឹងមើលរបស់គេរៀងៗ ក្នុងរានផ្សារ សុទ្ធតែល្អទាំងអស់នោះ, គួរនឹកថារបស់ទាំងនេះ « មិនល្អ , មិនស្អាត » ខ្ពើមរអើម ដើម្បីបន្ថយនូវសេចក្ដីស្រឡាញ់ នឹងសេចក្ដីប្រាថ្នាចង់បាន ឲ្យស្រាលស្រើនតិចទៅ តែបើបេះតែនឹកថា អាវ - សំពត់នេះល្អ, កំប្រោងនេះល្អ ក្របូបនេះល្អ នឹងធ្វើឲ្យភេទស្រឡាញ់កំរើកកាន់តែខ្លាំងឡើង ក្នុងទីបំផុតក៏ត្រូវចាយវាយប្រាក់កាស ទិញនូវរបស់ទាំងនោះយ៉ាងខ្ជះខ្ជាយ ហួសការចាំបាច់ ។ ក្មេងកម្លោះដែលបានឃើញស្រីក្រមុំ ក៏កុំឲ្យសម្លឹងមើលដោយកំណត់ក្នុងចិត្តថា នាងនោះល្អស្អាតជ្រុលហួសពេក នឹងធ្វើឲ្យចិត្តកំរើកស្រឡាញ់ នាំឲ្យរាថយចិត្តចំពោះការសិក្សារៀនសូត្រ អាចឲ្យប្រឡងធ្លាក់ក្នុងវេលាកំណត់ឆ្នាំម្ដងៗ ពុំខាន ។ ឧទាហរណ៍ដែលពោល

មកពាក់លើនេះ នាំឲ្យខ្ញុំយល់ឃើញថា អសុភកម្មដ្ឋានជាកម្មដ្ឋានដែលណែនាំសាធុជនគ្រប់ប្រភេទឲ្យមានសេចក្តីព្យាយាម នឹកគិតនឹងពិចារណាមើលចំពោះវត្ថុផ្សេង ៗ ថា មិនស្អាតមិនល្អ ដើម្បីជាគ្រឿងកែរាគស្រឡាញ់ដោយពិតប្រាកដ ។ សូមសាធុជនគ្រប់ឋានៈ ដែលមានរាគស្រឡាញ់ បិតនៅក្នុងសន្តាន គួរនាំគ្នាយកទៅពិសោធមើល ។

រាគស្អប់ ព្រះអង្គទ្រង់ប្រទានព្រហ្មវិហារ គឺមេត្តា, ករុណា, មុទិតា, ឧបេក្ខា ដើម្បីជាគ្រឿងកែរាគស្អប់ ព្រោះរាគស្អប់ជារោគដ៏ក្តៅ ។ ឯព្រហ្មវិហារជាធម៌ត្រជាក់ ល្មមនឹងរំលត់រាគស្អប់បាន ។ មនុស្សដែលកើតរាគស្អប់ មានអាការក្រោធខឹងឆាប់ ចិត្តច្រើននោះ បើបានមេត្តាធម៌ មកអប់រំបណ្តុះបណ្តាលនូវសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ, បណ្តុះករុណាធម៌ កាលឃើញអ្នកដទៃបានទទួលនូវសេចក្តីទុក្ខ, បណ្តុះមុទិតាធម៌ មិនឥច្ឆា ឫស្យា សំដែងសេចក្តីត្រេកអររីករាយ កាលឃើញអ្នកដទៃបានល្អ បានចំរើន ទីនឹងបណ្តុះឧបេក្ខាធម៌ គឺដាក់ខ្លួនជាកណ្តាលមិនលំអៀងចូលទៅខាងណា ។ ព្រហ្មវិហារទាំង ៤ យ៉ាងនេះ មនុស្សដែលមានរាគស្អប់បិតនៅក្នុងសន្តាន គួរនាំគ្នាយកទៅពិសោធមើល ។

រាគវង្វេង ព្រះអង្គទ្រង់ប្រទាន អានាបាណស្សតិ ជាគ្រឿងកែរាគវង្វេង ព្រោះមនុស្សដែលកើតរាគវង្វេង ច្រើនមានចិត្តកាយមាយ

មិនស្ងប់ស្ងាប់ គួរតែអប់រំចិត្តឲ្យមានសមាធិជាធម៌សមគួរសម្រាប់កែរោគវង្វេងបាន ពុំមានអ្វីស្មើនឹងអានាបាណស្សតិ ការកំណត់ដង្ហើមចេញចូលនេះឡើយ ។ កម្មដ្ឋាននេះ មនុស្សដែលកើតរោគវង្វេង អាចនឹងនាំយកទៅអប់រំចិត្តបានច្រើនពេលវេលា ដូចវេលាអាស្រ័យដំណេក មានចិត្តរាយមាយអណ្ដែតអណ្ដូងទៅគិតរឿងច្រើនយ៉ាង ក៏ចូរណែនាំចិត្តឲ្យមកកំណត់នូវអានាបាណស្សតិ គឺដង្ហើមចេញចូលនេះ ដូចកាលដង្ហើមចេញចូលខ្លី ក៏ឲ្យដឹងថា ដង្ហើមចេញចូលខ្លី, ដង្ហើមចេញចូលវែង ក៏ឲ្យដឹងថា ដង្ហើមចេញចូលវែង ។ ការកំណត់ដង្ហើមចេញចូលនឹងអាចធ្វើចិត្តឲ្យស្ងប់ស្ងាប់ដោយពិត អាចអាស្រ័យដំណេកលក់បានដោយស្រួល មិនចាំបាច់ញ៉ាំថ្នាំដេកលក់យកមកលេប នាំឲ្យអស់ប្រាក់កាសឡើយ ។

ការព្យាបាលរោគចិត្ត គឺរោគស្រឡាញ់, រោគស្អប់ និងរោគវង្វេង ដោយឧសថ ៣ មុខនេះ គឺព្យាបាលរោគស្រឡាញ់ ដោយកម្មដ្ឋានឈ្មោះអសុភ, ព្យាបាលរោគស្អប់ដោយកម្មដ្ឋានឈ្មោះព្រហ្មវិហារ និងព្យាបាលរោគវង្វេង ដោយកម្មដ្ឋានឈ្មោះអានាបាណស្សតិ ដូចពោលមកដោយសង្ខេបនេះ ជាវិធីមួយយ៉ាងដែលព្យាបាលរោគចិត្តល្អណាស់ ពុំសូវមានរបៀបច្រើនប៉ុន្មានឡើយ ។ ឯការសំខាន់បំផុតនៅត្រង់ពុទ្ធមាមកជនដែលមានសេចក្ដីគោរពចំពោះព្រះពុទ្ធសាសនា ហើយនាំយកវិធីនេះទៅប្រតិបត្តិតាមប៉ុណ្ណោះ ។

---

# សុរពជាតក

(តមក)

លោក ថង-វង ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះនគរហើយ ចូលទៅក្នុងប្រាសាទមាស ។ ព្រះនាងគល្យាណី ឃើញខុសចាក ក៏ទើតសង្ស័យ ហើយប្រឹងពិនិត្យឫកពា ក៏ពុំមានសីហនាទដូចព្រះមហាក្សត្រ ទាំងពាក្យសំដីក៏ញញើតញញើម ទ្រង់មន្ទិលពិផលក្នុងព្រះរាជហឫទ័យណាស់ ហៅអាមាត្យម្នាក់មកត្រាស់សួរថា ម្នាលអាមាត្យ ! រីសេនាបតីមកជាមួយដែរឬ ? ។ អាមាត្យក្រាបទូលថា អរយេ បពិត្រព្រះនាងជាម្ចាស់ ! រីរូបសេនាបតីនោះ ដេកដួលនៅកណ្ដាលព្រៃ ដំណើរនេះ ទូលព្រះបង្គំពុំដឹងឡើយ ។ ព្រះនាងស្ដាប់ហើយ ទ្រង់ព្រះចិន្ដាថា " នេះសមព្រះមហាក្សត្រដកចិត្តចេញពីព្រះរូប ទៅចូលក្នុងយក្សី ឬម្រឹគស្លាប់ណាមួយ, ឯសេនាបតីនេះ ដកដួងចិត្តរបស់វា ចូលក្នុងព្រះរូបស្វាមីនៃអញ ហើយនាំយោធាចូលមកព្រះនគរវិញ ពោលព្រះមហាក្សត្រឲ្យនៅក្នុងព្រៃពុំលែងឡើយ , នុ៎ះសេនាបតីនេះហើយ ជាមនុស្សអកតញ្ញូណាស់តើ"; ចាប់តាំងពីពេលនោះមក ព្រះនាងពុំទៅគាល់សេនាបតីនោះឡើយ ទោះបីសេនាបតីមកកាន់សំណាក់ព្រះនាង ក៏ព្រះនាងពុំទទួល ពុំស្រដីសោះ ។

រឿងនេះសូមស្ទុះទុកសិន, យើងនឹងនិទានពីព្រះមហាក្សត្រវិញ ។

កាលស្តេចចូលក្នុងរូបម្រឹគនោះ បានត្រាច់ទៅក្នុងលំនៅព្រៃគាំងពីព្រឹក រហូតថ្ងៃត្រង់ ទើបលំបាកក្នុងកាយជាខ្លាំង ទើបដើរទៅទៀតឃើញ ស្រះមួយចុះផឹក ហើយក្រឡេកមើលទៅ យល់សេកសោមបណ្ឌិតមួយ ស្លាប់ថ្មីៗ ក៏រាយមន្តបន្ទយចិត្តចេញអំពីម្រឹគ ចូលក្នុងសេកសោមបណ្ឌិត ហើយហើរមកតាមអាកាសចូលដល់ប្រាសាទព្រះនាងកល្យាណីៗ ព្រះនាង យល់សេកសោមបណ្ឌិតហើយ ស្គាល់ជាក់ថាជាស្វាមីព្រះនាង ក៏ពិនិត្យ ពិចារណាឥរិយាបថ យល់ច្បាស់ថាជាព្រះមហាក្សត្រចូលក្នុងសេកសោម បណ្ឌិតពិតប្រាកដៗ ក្សណៈនោះ សេកសោមបណ្ឌិត ពោលជាភាសា មនុស្សថា "បុគ្គលមិនគួរជឿហេតុពីរយ៉ាងគឺ: សឹកសត្រូវមានចិត្តល្អ ១, ស្រីមានចិត្តត្រង់ ឬ ភរិយាមិនបោះក្បត់ស្វាមី ១", បុគ្គលមិនគួរសេពគប់ មនុស្សពីរពួកនេះឡើយ ។ ព្រះនាងទ្រង់ព្រះសណ្តាប់ហើយ មានព្រះ សវនីយទៅកាន់សេកសោមបណ្ឌិតថា កាំ កាចេសិ បពិត្រសេក សោមបណ្ឌិត! ហេតុអ្វីក៏អ្នកស្រដីដូច្នោះ? ស្តើងទៀតក៏អ្នកមិនស្រដីផង មាធិសា ស្រីដូចខ្ញុំម្ចាស់ តើមានចិត្តក្បត់ដូចម្តេច? ខ្ញុំម្ចាស់ស្គាល់ ជាក់ជាព្រះអង្គហើយ បើកុំតែដួងចិត្តព្រះអង្គនៅក្នុងសេកសោមបណ្ឌិត ខ្ញុំម្ចាស់ពុំស្រដីរកឡើយ, បពិត្រសេកសោមបណ្ឌិត! អញ្ជើញស្តេច គង់លើបល្ល័ង្ករ័ត្ន ដ៏ប្រកបទៅទូវកម្រាលដ៏វិចិត្រ សូមស្តេចប្រថាប់ នៅហោង ។ សេកសោមបណ្ឌិត ក៏ឡើងគង់លើបល្ល័ង្ករ័ត្ន ។ ព្រះ

នាងគលព្រាណី បានយកឈាដលាយដោយទឹកឃ្មុំ ដាក់ក្នុងផ្តិលមាសថ្វាយសោយរួចហើយ ទ្រង់ព្រះចិន្តាថា គួរអញគិតឧបាយគលយកព្រះរូបព្រះស្វាមីនៃអញឲ្យបានវិញ ព្រះនាងជណ្ដឹងសួរថា បពិត្រសេកៈសោមបណ្ឌិត! ព្រះអង្គយាងមកពីទីណា ? ។ សេកៈសោមបណ្ឌិតឆ្លើយថា យើងមកពីព្រៃ ។ តើព្រះអង្គចេញពីប្រទេសណាទៅ ? ។ ម្នាលនាងទេវី ! យើងចេញពីប្រាសាទ-ពីនគរនេះទៅប្រពាតព្រៃ ឃើញម្រឹគមួយស្លាប់ថ្មី ៗ យើងមានចិត្តចង់ត្រាច់លេងក្នុងល្វែកព្រៃ ទើបកាយមន្តបន្ទយចិត្តចូលក្នុងរូបម្រឹគនោះ ត្រាច់ចូលទៅក្នុងព្រៃតែម្នាក់ឯង លុះនឿយហត់ខ្លាំង វិលមករកសេនាយោធាក៏ពុំឃើញឡើយ ឃើញតែរូបសេនាបតី ក៏ដឹងថា សេនាបតីជាមនុស្សក្បត់, យើងដើរទៅដល់ស្រះមួយ បានឃើញរូបសេកសោមបណ្ឌិតមួយស្លាប់ថ្មីៗ ក៏ដកចិត្តចេញពីរូបម្រឹគ ចូលក្នុងរូបសេកសោមបណ្ឌិត ហើយហើរមករកព្រះនាងនេះហោង ករុណា វិប្បការំ ម្នាលព្រះនាងដ៏ចំរើន! តើព្រះនាងឃើញស្វាមីរបស់ព្រះនាង មានកិរិយាបថផ្លែកពីធម្មតាខ្លះដែរឬទេ ? ។ ព្រះនាងក្រាបទូលថា បពិត្រព្រះអង្គ! ខ្ញុំម្ចាស់សង្កេតកិរិយាបថ ឃើញខុសពីកិរិយាបថរបស់ព្រះអង្គ ទើបខ្ញុំម្ចាស់មិនស្ដីរក, ព្រោះខ្ញុំម្ចាស់យល់ថាព្រះអង្គទ្រង់ដកដួងចិត្តចូលក្នុងរូបបក្សី ឬម្រឹគណាមួយ ។ ឯសេនាបតីដកដួងចិត្តចូលក្នុងព្រះរូបរបស់ព្រះអង្គ, ខ្ញុំម្ចាស់នឹងស្វែងរកតែចិត្តព្រះ

អង្គឲ្យឃើញ ដូចនាងសិរីសោភា កាលដែលប្តីរបស់នាងស្លាប់ នាងខំស្វែងរកទាល់តែឃើញ ។ សេកៈ ហាមបណ្ឌិតសួរថា ម្នាលព្រះនាងកល្យាណី កាលដែលនាងសិរីសោភា ស្វែងរកចិត្តស្វាមីរបស់ព្រះនាង តើស្វែងរកដូចម្តេច ? ។ ព្រះនាងកល្យាណី នាំនិទានមកថ្វាយមានសេចក្តីដូចតទៅនេះ ៖

ក្នុងកាលដែលកន្លងទៅហើយ មានព្រះមហាក្សត្រាធិរាជមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទសាមន្តរាជ សោយរាជសម្បត្តិនៅនគរមួយមានឈ្មោះពុំប្រាកដ មានព្រះអគ្គមហេសីព្រះនាមសិរីសោភា ព្រះអង្គនៅវ័យក្មេង ពុំទាន់ចាស់នៅឡើយ, ថ្ងៃមួយ ទ្រង់មានព្រះរោគមកបៀតបៀនព្រះកាយ ក៏សោយព្រះទិវង្គតទៅ ។ ព្រះនាងសិរីសោភាអញ្ជើញព្រះសពព្រះស្វាមី ដាក់ក្នុងហិបមាសបិទយ៉ាងជិតល្អ ទ្រង់ផ្តាំអស់សេនាមាត្យថា យើងទៅរកជីវិតព្រះស្វាមីយើងឲ្យបានវិញ អ្នកទាំងឡាយ កុំថ្វាយព្រះភ្លើងព្រះសពព្រះស្វាមីយើងឡើយ ផ្តាំស្រេចព្រះនាងចុះពីប្រាសាទសង្កាតសាកសួរ ពួកសមណព្រាហ្មណ៍ នូវអ្នកប្រាជ្ញរាជបណ្ឌិត អំពីមន្តឱសថសម្រាប់ធ្វើជីវិតមនុស្សឲ្យរស់ ។ ពួកសមណៈព្រាហ្មណ៍ នូវអ្នកប្រាជ្ញទាំងឡាយ ពុំបានបេះឡើយ ។ ព្រះនាងត្រាច់ទៅទៀតដរាបដល់នគរមួយ ។ នៅនគរនោះ មានព្រះមហាក្សត្រមួយព្រះអង្គ ស្តេចមានព្រះសុពណ៌បាទុក់កែវមួយ ។ រីព្រះសុពណ៌បាទុក់កែវ

នោះ  កាលបើស្តេចមានព្រះរាជហឫទ័យ  ចង់ទៅនគរណា ៗ ក្តី  ទ្រង់ប្រដាប់ព្រះសុពណ៌បាទុកនោះ  ហោះតាមអាកាសវេហាស៍  បានដល់ទៅនគរនោះមួយរំពេច  អបិ យោ ការាលំ  កត្វា  បើអ្នកណាមួយស្លាប់ហើយក៏ដោយ  ត្រូវពួកញាតិវង្សទាំងឡាយ  អញ្ជើញព្រះសុពណ៌បាទុកនោះយកទៅស្រង់ទឹក  ហើយយកទឹកនោះទៅផ្តុំ-បំផឹកបុគ្គលស្លាប់នោះ, រីបុគ្គលស្លាប់ ក៏មានជីវិតរស់ត្រឡប់ឡើង  ឥតមានរោគាអ្វីមកបៀតបៀនទៅទៀត ៗ  សា  ច  តំ  ឆត្រំ  បត្វា  រីព្រះនាងសិរីសោភា ទ្រង់យានទៅដល់នគរនោះ  ចូលទៅក្នុងឧទ្យាន  អាស្រ័យនៅនឹងដូនចាស់ម្នាក់ជាអ្នកក្រងផ្កាថ្វាយព្រះមហាក្សត្រ ៗ រីដូនចាស់នោះសោត  ឥតកូនចៅឡើយ  លុះឃើញព្រះនាងសិរីសោភាហើយ  មានចិត្តស្រឡាញ់យកព្រះនាងមកចិញ្ចឹមជាកូនធម៌ ៗ ឯព្រះនាងសិរីសោភា  តែងបេះផ្កាយកមកដោតក្រងជូនដូនចាស់ ៗ ដូនចាស់នាំកម្រងមាលានោះ  ទៅថ្វាយព្រះមហាក្សត្រាធិរាជ ៗ  ស្តេចទតព្រះនេត្រយល់  កម្រងមាលាល្អបម្លែកប្លែកនឹងសព្វដង  ក៏ដណ្តឹងសួរថា  ហៃដូនចាស់ ! ផ្កានេះនរណាក្រង ? ៗ ដូនចាស់ក្រាបទូលថា  កូនខ្ញុំម្ចាស់ឈ្មោះសិរីសោភាក្រងថ្វាយ ៗ  ទើបស្តេចត្រាស់សួរថា  កុតោ  លភសិ  ដូនបានមកពីណា ? ពីដើមយើងពុំដែលឮថា  មានកូន ៗ ដូនចាស់ក្រាបទូលថា  ទេវ បពិត្រព្រះសម្មតិទេព !  រីនាងនេះ ឥតបិតាមាតា

ជាអ្នកខ្វាត់ព្រាត់មកអំពីនគរដទៃ ខ្ញុំម្ចាស់មានសេចក្ដីអាណិតអាសូរ ក៏យកមកចិញ្ចឹមជាកូនធម៌ ។ ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ដូនចាស់ដូច្នោះហើយ ត្រាស់សួរថា នាងនោះជាស្រីដូចម្ដេច ? ។ ដូនចាស់ក្រាបទូលថា នាងនោះមិនមែនជាស្រីខ្ជីខ្ជា កើតក្នុងត្រកូលរាស្ត្រទេ ប្រាកដជាកើតក្នុងត្រកូលក្សត្រហោង, ព្រោះនាងនេះ មានរូបល្អប្រពៃ ៗ តំ សុត្វា ព្រះមហាក្សត្រាធិរាជ ទ្រង់ព្រះសណ្ដាប់ហើយ មានព្រះរាជហឫទ័យសោមនស្សយ៉ាងក្រៃលែង ទើបត្រាស់ប្រើយាយអករ[១] ទាំងឡាយ ដែលស្គាល់លក្ខណៈស្រ្តី ឲ្យទៅពិនិត្យមើល ថាបើចតុសដ្ឋី ជាស្រីបរិបូណ៌ដោយលក្ខណៈ ៦៤ ប្រការ ចូរឲ្យនាងនោះឡើងជិះលើយានមាសដំកូម ឲ្យសមនឹងសក្ដានុភាពរបស់នាងហោង ។ យាយអករទាំងឡាយ ក្រាបបង្គំលាទៅកាន់ឧទ្យាន ឃើញព្រះនាងសិរីសោភាមានលំអគ្រប់លក្ខណៈទាំង ៦៤ ហើយអញ្ជើញព្រះនាងឡើងលើយានមាស ។ ព្រះនាងពុំមកឡើយ ។ ព្រះមហាក្សត្រទ្រង់ឲ្យទៅអញ្ជើញអស់វារៈ ពីរ បីដង ក៏ព្រះនាងមិនព្រមមក ។ ក្សណនោះ ព្រះមហាក្សត្រទ្រង់យាងទៅអញ្ជើញដោយព្រះអង្គឯង ទើបព្រះនាងឡើងគង់លើយានមាស ចូលទៅក្នុងប្រាសាទមាស ។ លុះចូលទៅ

---

(១) អករ = អ្នកមិនធ្វើការអ្វី ។ សំដៅយកស្រីដែលមានអាយុច្រើន ហើយចេះដឹងព្រះរាជពិធីទាំងពួងជាងយាយ,ចាស់,ទុំ ព្រមទាំងជាអ្នកនាំក្សត្រីឬបៅចមក្នុងព្រះបរមរាជវាំងទៅមកដោយកិច្ចណាមួយម្ដងៗប៉ុណ្ណោះ ។

ដល់ប្រាសាទមាសហើយ, ព្រះនាងសិរីសោភាគ្យមើលមើលសព្វគ្រប់ទៅ ឃើញព្រះបុពណ៌បាទុកកែវព្យួរនៅទីនោះ ទើបទូលសួរព្រះមហាក្សត្រថា អ្វីព្យួរនៅទីនោះ? ។ ស្តេចត្រាស់ថា ព្រះសុពណ៌បាទុកកែវ ៗ បពិត្រក្សត្រថ្លៃប្រសើរអើយ! ហេតុអ្វីក៏ព្រះអង្គយកព្រះសុពណ៌-បាទុកទៅព្យួរពីទីនោះវិញ? ។ -ករុណា ម្នាលនាងដ៏ចំរើន! ព្រះសុ-ពណ៌បាទុកនេះ មានគុណច្រើនណាស់ បើមនុស្សស្លាប់ហើយ យកព្រះសុពណ៌បាទុកនេះទៅដាក់ក្នុងផ្តិលមាស រួចយកទឹកនោះទៅស្រោចមនុស្សស្លាប់ នឹងមានជីវិតរស់ឡើងវិញ, មួយសោត បើចង់ទៅលេងឯណាក្តី ត្រូវយកព្រះសុពណ៌បាទុកនោះមកប្រដាប់ អាចហោះទៅតាមអាកាសវេហាស៍បាន ហេតុនេះ ទើបយើងឲ្យព្យួរនៅទីខ្ពស់ ៗ ព្រះនាងឮហើយ មានព្រះរាជហឫទ័យសោមនស្សយ៉ាងក្រៃលែង ទ្រង់ព្រះចិន្តាថា នឹងយកព្រះសុពណ៌បាទុកនេះតែទៅ ហើយព្រះនាងទូលដោយឧបាយកលថា បពិត្រក្សត្រថ្លៃប្រសើរអើយ! ព្រះអង្គថា "មង្គល", ឯខ្ញុំម្ចាស់ថា "អមង្គល" វិញ, ព្រោះយកគ្រឿងទាបទៅដាក់កន្លែងខ្ពស់ បើខ្ញុំម្ចាស់យកមកដាក់កន្លែងទាបទើបសមគួរ ។ ស្តេចស្តាប់ហើយ ក៏យកព្រះសុពណ៌បាទុកមកដាក់កន្លែងទាប ៗ លំដាប់នោះ ព្រះនាងសិរីសោភា ក្រាបទូលទៀតថា បពិត្រក្សត្រថ្លៃប្រសើរអើយ! ព្រះអង្គនាំយកខ្ញុំម្ចាស់មកពុំមានគ្រឿងបណ្ណាការថ្វាយព្រះរាជមាតាដល់ជួនបុសនោះសោះ គឺព្រះអង្គនាំខ្ញុំម្ចាស់មកដោយអំណាច ជាប្តីអមង្គល បើព្រះអង្គព្រះរាជទានបណ្ណាការ

ដល់ដូនចាស់នោះហើយ ជាមន្តិលសួស្តីល្អណាស់ ៗ ស្តេចត្រាស់ថា ម្នាលនាង ! រីដូនចាស់នេះ, ជាទាសីរបស់យើងទេតើ ៗ បពិត្រព្រះអង្គដ៏ចំរើន ! ដូនចាស់នោះ ជាទាសីរបស់ព្រះអង្គក៏ពិតមែនហើយ ប៉ុន្តែ គួរព្រះអង្គព្រះរាជទានបណ្ណាការផ្សេង ១ ទើបត្រូវតាមប្រពៃណីធម៌ពីបុរាណ ៗ ស្តេចស្តាប់ហើយ ទ្រង់ត្រាស់ប្រើយាយអករឲ្យតាក់តែងគ្រឿងបណ្ណាការ ព្រះរាជទានដល់ដូនចាស់នោះ ៗ លុះពេលរសៀលល្ងាច ព្រះនាងយល់អាការរបស់ព្រះរាជា ចង់ប្រមាថមកលើរូបព្រះនាង.១ យកព្រះសុពណ៌បាទុកមកទ្រង់ ហោះឡើងលើអាកាសទៅកាន់ព្រះនគរវិញ ហើយចូលទៅក្នុងប្រាង្គប្រាសាទ យកទឹកដាក់ក្នុងផ្តិលមាសមួយយ៉ាងធំ មកស្រង់ព្រះសុពណ៌បាទុក រួចលើកសពព្រះរាជ-ស្វាមីព្រះនាង មកដាក់ក្នុងផ្តិលមាសនោះ ៗ រីព្រះកាយព្រះស្វាមីរបស់ព្រះនាង ក៏មានសម្បុរល្អបរិសុទ្ធដូចមាសដម្កូវ: មានជីវិតរស់ឡើងវិញហោង ៗ

ព្រះនាងកល្យាណី លុះនាំអតីតទិពានមកទូលព្រះស្វាមីដូច្នេះរួចហើយ ក៏ទូលថា «បពិត្រសេកសោមបណ្ឌិត ! រីព្រះនាងសិរីសោភា មានចិត្តសុចរិតពិតត្រង់នឹងព្រះស្វាមី មានសេចក្តីព្យាយាមយ៉ាងធំរកជីវិតឲ្យព្រះស្វាមីបានដូចមេ្តចមិញ, រីឯខ្ញុំម្ចាស់ក៏នឹងធ្វើសេចក្តីព្យាយាមដូចព្រះនាងនោះហោង , ថ្ងៃនេះ . ខ្ញុំម្ចាស់បានជួបនឹងជីវិតព្រះស្វាមីរួចហើយ នឹង

អញ្ជើញព្រះអង្គចូលគន់ព្រះរូបព្រះអង្គវិញឲ្យបាន" , ព្រះនាងទូលដូច្នោះហើយ ក៏ទ្រង់គ្រឿងប្រដាប់ល្អប្រពៃ យាងចូលទៅគាល់សេនាបតី ។ រីសេនាបតី លុះឃើញព្រះនាងចូលមកគាល់ហើយ មានចិត្តត្រេកអរឥតឧបមា គិតថា ថ្ងៃនេះព្រះនាងកល្យាណីមកគាល់អញហើយតើ ។ ទើបព្រះនាងក្រាបទូលថា បពិត្រព្រះរាជកុមារ ! ខ្ញុំម្ចាស់ប្រាថ្នាចង់ឃើញឫទ្ធិចេស្តារបស់ព្រះអង្គ, សូមព្រះអង្គសំដែងឲ្យខ្ញុំម្ចាស់ បានឃើញផងហោង ។ សេនាបតីទទួលពាក្យរបស់ព្រះនាងហើយ ក៏ប្រើពួកអាមាត្យឲ្យទៅរកសត្វស្លាប់ ។ អាមាត្យទាំងឡាយស្ទុះយ៉ាងប្រញាប់ រកបានពពែមួយទើបនឹងស្លាប់ថ្មីៗ នាំមកថ្វាយ ។ សេនាបតីរាយមន្តដកចិត្តចូលគន់រូបពពែៗ ក៏ក្រោកឡើងស្ទុះបោលទៅ ។ ឯសេកសោមបណ្ឌិតរាយមន្តដកចិត្តចូលគន់ព្រះរូបព្រះអង្គវិញ ត្រាស់ប្រើឲ្យអាមាត្យបាញ់ពពែនោះសម្លាប់ ។ ពួកអាមាត្យទទួលព្រះរាជឱង្ការហើយ នាំគ្នាបាញ់ពពែនោះសម្លាប់កាលនោះហោង ។ ចាប់តាំងពីថ្ងៃនោះមក ព្រះបាទវេច្ចកុមារនឹងព្រះនាងកល្យាណី សោយរាជ្យជាបរមសុខតាមទសពិធរាជធម៌ តែងទូន្មានប្រៀនប្រដៅអ្នកនគរផង តាមព្រះរាជប្រវេណីអំពីបុរាណរៀងមកៗ

រីនាងបណ្ឌិតនារី លុះនាំមកនូវឧទាហរណ៍ដូច្នេះរួចហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ទ្រង់នូវព្រះគុណធ្ងន់ ! យោ ច រាជា រីព្រះមហាក្សត្រណាមួយ បានរក្សាប្រវេណីធម៌ ហើយសូមរកស្រីឲ្យមានចិត្ត

ទៀងត្រង់ មានប្រាជ្ញាដូចនាងកល្យាណី ទីឯសិរីសោភា គួរដំកល់ជាមហេសីបាន, មួយសោត បើបាននាងកែវដូចខាងលើនេះ ជាមហេសីហើយ គួរព្រះអង្គរកបុរសមានប្រាជ្ញាទៀងត្រង់ដំកល់ជាអាមាត្យ កុំអាលដំកល់បុគ្គលដូចយ៉ាងសេនាបតីនោះឡើយ; នាងបាននាំនិទានឧកថ្វាយតាំងពីបឋមយាម ដរាបដល់មជ្ឈិមយាមកន្លងទៅ ៗ ទើបព្រះចៅចន្ទរាជត្រាស់សួរថា ព្រះបាទវេទ្ធមានជិតរាជ ស្តេចដំកល់បុរសទៀងត្រង់កតញ្ញូ ជាអ្នកដឹងគុណម្ចាស់ខ្លួន ឲ្យជាសេនាបតី នោះតើដូចម្តេច ? ។ នាងបណ្ឌិតនារី ក៏នាំនិទានមកថ្វាយទៀតថា ៖

បុព្វេ មហារាជ បពិត្រមហារាជ ! ក្នុងកាលមុនឡើយ ព្រះចៅវេទ្ធមានជិតរាជនោះ សោយរាជសម្បត្តិនៅនគរពារាណសី ស្តេចកើតក្នុងត្រកូលមហាសម្បត្តិធំ ចាប់តាំងពីស្តេចប្រសូតចេញចាកព្រះគភ៌នៃព្រះរាជមាតាមក ឯកន្តសុខេ ឋិតោ ស្តេចមានតែសេចក្តីសុខ ពុំដែលស្គាល់សេចក្តីទុក្ខឡើយ, ហេតុនោះ ទើបព្រះមហាក្សត្រគិតពោលរឿយ ៗ ដូច្នេះថា: គឺ ទុក្ខំ នាម វេទនា នាម បរិឡាហោ រីសេចក្តីទុក្ខដូចម្តេច? វេទនាដូចម្តេច ? សេចក្តីក្តៅក្រហាយដូចម្តេច ? យើងពុំដែលដឹង-ស្គាល់ឡើយ" ៗ គ្រានោះ មានអាមាត្យម្នាក់គិតថា អញនឹងធ្វើឲ្យព្រះមហាក្សត្រ ស្គាល់សេចក្តីទុក្ខវេទនាក្រហល់ក្រហាយព្រះកាយម្តង គិតស្រេចក៏ហៅនាយព្រានម្នាក់មកបង្គាប់ឲ្យចាប់

ម្រឹគព្រៃមួយ យកគ្រឿងសេះចងប្រដាប់ម្រឹគនោះ ហើយចូលទៅគាល់ព្រះរាជាទូលថា បពិត្រព្រះសម្មតិទេព! បើស្ដេចចង់ស្គាល់សេចក្ដីទុក្ខវេទនាក្រហល់ក្រហាយលំបាកព្រះកាយ សូមស្ដេចឡើងគង់លើម្រឹគនេះហោង ។ សម្ដេចព្រះមហាក្សត្រាធិរាជ ទ្រង់ឡើងគង់លើខ្នងម្រឹគ ព្រះហស្ដចាប់ខ្សែបង្ហៀរខ្ជាប់ ។ ឯម្រឹគនោះ ស្ទុះលោតផ្លោះតាមកម្លាំង, ព្រះរាជាទាញបង្ហៀរទាញក្រឡាក់ប៉ុន្មានទៅក្ដី ក៏សត្វព្រៃពុំបែរវិលក្រោយឡើយ រឹងរឹតតែស្ទុះផ្លោះល្បោះទៅមុខទាំងយប់ទាំងថ្ងៃ នាំព្រះមហាក្សត្រដកបដល់ទួលមួយ ទើបម្រឹគនោះអស់កម្លាំងទន់ទាំងខ្លួន ទំរំហោះទៅទៀតពុំបាន ឈរនៅស្ងៀម ។ ព្រះមហាក្សត្រ ទ្រង់នឿយលំបាកព្រះកាយពន់ ដោយត្រូវខ្យល់ទឹកកំដៅថ្ងៃ អត់ទាំងព្រះក្រយា-ស្ងោយ សោយទុក្ខវេទនាដ៏ខ្លាំងក្លាលើខ្នងម្រឹគនោះ លុះជ្រាបថា ម្រឹគព្រៃលែងហោះទៅទៀតហើយ ទ្រង់ចុះពីខ្នងម្រឹគចូលទៅអាស្រ័យនឹងស្រុកមួយ ។

នៅស្រុកនោះ មានស្រីជាងម្នាក់ ប្រកបដោយរូបឆោមលោមពណ៌ដ៏ប្រពៃ គ្រប់ស្រេចទាំងគួរស្នេហ៍ដោយកាមគុណ, តែថា នាងនោះយកឈ្នួលជាទ្រព្យ ១ ពាន់ដំឡឹង លុះឃើញព្រះមហាក្សត្រអង្គនេះយាងមកដល់ នាងគិតថា បុរសនេះ មិនមែនជាអ្នកកំសត់ទុគ៌តឡើយ ទើបនាងថ្វាយខាទនីយភោជនីយាហារ ។ ព្រះរាជា បានរួមសំពាសនឹង

នាងនោះដោយព្រះរាជហឫទ័យរីករាយយ៉ាងក្រៃលែង លុះព្រឹកឡើងស្ដេចប្រុងនឹងលីលាយាត្រាទៅទៀត ។ នាងនោះ តឹងទារថា ប្រស្ដេចមករួមរសកាមគុណនឹងយើង ត្រូវឲ្យទ្រព្យ ១ ពាន់ដំឡឹងមកយើង ទើបយើងឲ្យប្រស្ដេចទៅ ។ មួយសោត កាលអាមាត្យរៀបចំដំណើរព្រះមហាក្សត្រនោះ បានវេចមាស ១ ពាន់ដំឡឹងមកផង ។ ព្រះមហាក្សត្របានឲ្យថ្លៃឈ្នួលជាមាស ហើយនៅរួមរក្សនឹងនាងនោះ ទាល់តែអស់ទ្រព្យនោះហោង, តមក ពុំមានទ្រព្យឲ្យឡើយ ។ ស្រីផ្កាមាសក៏យកព្រះមហាក្សត្រជាខ្ញុំបំរើ គឺឲ្យធ្វើកិច្ចការទាំងឡាយ មានដងទឹកចីសស្រូវជាដើម ។ តៈតោ បន្ដាយ ចាប់ដើមតាំងពីថ្ងៃនោះមក, ព្រះរាជាក៏ស្គាល់នូវសេចក្ដីទុក្ខវេទនា ទុក្ខេន ភុញ្ជតិ សោយក៏ជាទុក្ខ, ទុក្ខេន និសីទតិ ប្រថាប់ក៏ជាទុក្ខ ទុក្ខេន សយតិ ផ្ទំក៏ជាទុក្ខ; ព្រះអង្គទ្រង់ព្រួយព្រះរាជហឫទ័យណាស់ លាន់ព្រះឱស្ឋថា ឱ ! អាត្មាអញស្គាល់សេចក្ដីទុក្ខហើយតើ ! ។

នឹងស្រដីអំពីអាមាត្យ ដែលឲ្យដំណើរព្រះមហាក្សត្រវិញ, កាលបើព្រះរាជាទៅបាត់យូរថ្ងៃហើយ ទើបគិតថា យន្នូនាហំ រាជានំ អនុពន្ធិស្សាមិ គួរអាត្មាអញ ទៅតាមព្រះមហាក្សត្រឲ្យត្រឡប់វិញហោង, ឥទានិ កុហឹ គច្ឆតិ ឥឡូវ ស្ដេចហោងទៅទីណា ?

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងសព្វសិទ្ធិ

( តចប់ )

របស់ហ្មឺនភក្តីអក្សរគង់ លោក ញូ - ប៉ូ ចំឡងពីសាស្ត្រាស្លឹករឹត

---

តែថាជាការណ៍គ្រាស់បង្គាប់ ត្រូវធ្វើតាមច្បាប់កុំប្រណី ត្រូវបទអយ្យកា-ស្ថានទីបី ត្រូវកាត់សិរសើពុះឆកាវ គិតស្រេចបង្គាប់ពួកពេជ្ឈឃាត ថាឯងចូរឃាតគិតតាមការ ចាប់សត្វពពែធ្វើទោសា តាមព្រះអាជ្ញាជាប្រញាប់ ៗ ពេជ្ឈឃាតឮហើយស្រែកហៅគ្នា ព័ទ្ធរោមចាប់ពាបានស្រេចស្រាប់ ពពែបំរះដួលផ្ការផ្កាប់ គិតថាអញស្លាប់គ្រោះទម្ងន់ ៗ ហើយប្រឹងសម្លឹងមើលសព្វស្ថាន ក្រែងមានសត្វស្លាបទីងគិតបង ដកចិត្តទៅចូលរូបទៀតផង តាមដោយបំណងឲ្យពន់រួស ៗ រកមើលពុំមានសត្វក្បែណក្បែរ រឹងរិតសង្ស័យភ័យញ័ររោះ រំពឹងគិតថាឆកម្មគ្រោះ ពីព្រោះខ្លួនឯងវង្វេងខ្លាំង ៗ ប្រែចិត្តទុជិនពន់ប្រមាណ ហៅហ៊ានចូលរូបគេហើយតាំងលើកខ្លួនជាតាំងកាងបំបាំង ប្រណាំងរក់សនាឲ្យគេក្បែរ ៗ ពេលនេះផលកម្មប្រចាំកេទ ទិដ្ឋធម្មវេទបណ្តោយដៃ ផ្តល់ផ្តាច់កាច់កិនមិនសំចៃម៉ោះទីងប្រល័យដន្ទដីក ៗ អស់ពួកពេជ្ឈឃាតឃ្មាតចាប់ចង ខាប់ខ្លួន

ផាមុក្ខគ្នានមេត្តា លុះដល់ទៅទីធ្មើរទោសា នាំគ្នាប្រហារកាត់សរសៃ ៗ
ហើយពុះដើមទ្រូងរួចយកថ្លើម មុខគ្មានឲ្យស្មើរខ្លាចពេកក្រៃ គឺលៀន
ទុជិនកំក្បៀណក្បៀយ ធ្លាក់ទៅនរកយនរកជ្រៅ ៗ ដោយកម្មគិតក្បត់
អកតញ្ញូ រង់ទុក្ខជាយូរលង់ទិត្យនៅ ស៊ូតែឈាមខ្ទុះខោះរៀងទៅ
ព្រោះចិត្តឃោរឃៅក្រៅធម្មា ៗ ឯជនទំលុងក្នុងក្រុងត្រៃ សុខសាន្ត
សន្តិ៍យតែរក្សាគ្នា ពុំដឹងដើមដល់កលពជា ទ្រង់ព្រះត្រាធាតុហេតុអ្វី ៗ
នានានាថសុវណ្ណកេសរថៃ យល់ព្រះគួរទេយ្យចមបក្រ ចូលរូបអគ្គប្រាណ
បានវិញខ្ញុំ ក្សត្រិត្រេកអរផេតខុបមា ព្រះបៅសព្វសិទ្ធិទ្ធិហាន និង
នានកល្យាណក្រុងរដ្ឋា ទូលព្រះបមពន្ធអគ្គបិតា ក្សេមក្សាន្តសុខាគាំង
ពីរប្រាណ ៗ សុភក្តិនានសុំក្រមកំណាន់ ប៉ែតម៉ឺនសែនពាន់ពេញព្រះ
ស្ថាន គាល់ហៅបំរើមហាក្សត្រក្សាន្ត ពុំផលខតខានមួយថ្ងៃ ៗ
នាម៉ឺនចតុរង្គគង្គនិកាយ ក្សេមក្សាន្តសប្បាយនិពេភា ទាំងស្រុកតូចធំ
និគមា ក្នុងព្រះភាពគរណាចក្រ ៗ បង្កើតកៀងទូរជារជោគជាំ តាម
រដ្ឋូវធ្លាក់ពុំផលអាក់ សារពើដំណាំដាំដុះជោគជាំ បានផលអនេកអនេក
ក្រៃ ៗ ពុំមានឃ្លានអត់កំសត់ក្រ ទាំងស្រវអង្ករគ្របួរថៃ ចោរក្មេងក៏ស្ងប់
ទាំងយប់ថ្ងៃ អាស្រ័យរកស៊ីតាមសម្មា ៗ ឯអគ្គពុជពង្សព្រះទ្រង់រិទ្ធ
ប្រកបខ្លួនដោយពិជិតដាប់ប្រការ ស្តេចទាំងពីរយមួយនាំស្នូយសារ មកថ្វាយ

ព្រះមហាក្សត្រថ្កើនថ្កល់ ៗ ថ្ងៃនីព្រះបាទព្រហ្មទត្ត ស្រាយរាជសម្បត្តិ
សុខសៃនសល់ ប្រជុំប្រជុំព្រះជន្មដល់ ទសពលទ្រង់ព្រះជរាពាធ ៗ
ប្រឈួនព្រះពេគរឹតតែខ្លាំង ជាហេតុអនិច្ចំពុំឃ្លៀងឃ្លាត រំលាងជីវិត
ជន្មខន្ធធាតុ ប្រែជាតិទៅកើតត្រៃត្រឹង្ស ៗ គ្រានោះកុសុមាជាមហេសី
នូវរាជបុត្រីស្រីបរិវារ មន្ត្រីសេនីយនូវសេនា សឹងសោយសោកាសព្វអឹង
កង ៗ ដោយក្តីអាល័យក្រៃពេកពិត រលឹកនឹកគិតក្សត្របាស់បង់
ហើយព្រាមប្រាប់អស់ព្រះស្ត្រាសជង កាន់ទុក្ខតាលង្វង់បុណ្យព្រះសព ៗ
ព្រះពង្សពោធិ៍ទីទេវរាជ ទ្រើសទ្រង់អំណាចលើសដែនភព បេញត្រួត
បង្គាប់ប្រាប់ប្រាព្ញ ត្រាស់សព្វពួកក្រុមខាងមេការ ៗ ឲ្យសង់ព្រះមេរុ
មាសមណ្ឌប ទីតាំងព្រះសពធ្វើបញ្ញា ក្បូរក្បាច់លេចរចនា មានកូង
បុប្ផាចង្កាយរៀង ៗ ពេងជួរជុំវិញពេញប្រកិត បាំងបិទឡាប់ខ្សែក្បែរ
រះបៀង របបប្រុងប្រៀបរៀបឥតល្អៀង យប់អុជបង្គៀងភ្លឺព្រោងព្រាយ ៗ
ហើយបាត់ឲ្យមានល្បែងមហោស្រព លេងតាំងថ្ងៃយប់ដោយឡែកលាយ
គ្រឿងហែសឹងរូបសត្វសម្ពាយ ប្រើសព្រាយសិង្ហគោគោមហង្ស ៗ លុះ
រៀបរួចគ្រប់នាំសពចេញ មន្ត្រីពាសពេញហែគ្រៀបគ្រា សុទ្ធសឹងតែង
តាមយសសក្តា គឹកកងកោលាដោយបារមី ៗ ហែដល់លើកដាក់លើ
មណ្ឌប ដម្កើងព្រះសពក្សត្រធិបតី និមន្តព្រះសង្ឃតាំងបូរ ថ្វាយតានប្រ-
ក្រតីពល់វេលា ៗ បង្សុកូលទេសនាតាំងថ្ងៃយប់ លុះជួបគ្រប់សត្តទិវា ទ្រង់

ឲ្យប្រជុំក្រុមមុខងារ រួសរៀបបូជាព្រះសពស្រេច ៗ រើសព្រះអដ្ឋិដាក់កោដ្ឋ
មាស រូបិវិលាសមាសល្អដាច់ បើនតែបម្លាក់ឆ្លាក់ក្បូរក្បាច់ ហើយស្រេច
ឲ្យសាងព្រះចេតិយ ៗ រួចទើបដង្ហែព្រះធាតុទៅ បញ្ចុះទិត្យនៅចេតិយថ្មី
ស្រេចការពុលធំអគ្គចក្រី នាំអគ្គមហេសីស្រីស្រឹង្គារ ៗ ចូលកាន់មន្ទីរ
ខែមណ្ឌល ពុំមានអំពល់ទុក្ខភ័យា ទើបអស់ចតុរង្គអង្គយោធា ជំនុំ
ព្រមគ្នាទាំងផែនដី ៗ អញ្ជើញពិពង្សអង្គមហាក្សត្រ ឲ្យគ្រងសម្បត្តិកុង
បុរី ទ្រង់លើកព្រះនាងនាថក្សត្រី ជាអគ្គមហេសីសិរីក្ស ៗ ព្រះអង្គ
ស្តេចបានស្ថានពិភព បារមីលើសលប់ចប់ត្រៃចក្រ ព្រះកិត្តិយសខ្ពស់
អន័ក្ស អតិរេកឯកអគ្គឧត្តម ៗ ប្រកបព្រះទ័យអភ័យទោស សន្តោស
អំណត់អត់សង្ឃំ សប្តាដោយចិត្តទ្រង់គិតតាំង · ប្រោសសត្វសន្ធ្យៀំ
ដែលខាំងខាន ៗ ទ្រង់សីលសច្ចាទិគុណខ្ជាប់ បាយព្រះពជទ្រង់ឥត
ប្រមាណ បំពេញកុសលផលបុណ្យបាន បរិបូណ៌ក្សេមក្សាន្តកុងភាព ៗ
គ្រប់ទីប្រទេសទិវេសន៍ស្ថាន ពុំហ៊ានប្រឡងព្រះរាជា បរបូលមូលមកថ្វាយ
វន្ទា តាំងព្រះសម្ភារពោធិវង្ស ៗ ព្រះអង្គគ្រប់គ្រងរាជសម្បត្តិ សម្បូណ៌
ពេកក្តាត់ជាយូរលង់ នៃបនឹងមហេសីស្រីធោមយង់ ទ្រើសទ្រង់ព្រះជន្ម
ប្រជួបបាន ៗ មួយរយម្ភៃព្រះវស្សា ទើបមហាក្សត្រាថ្ងៃថ្កើងថ្កាន
ទ្រង់ព្រះអាពាធបៀតអង្គប្រាណ ក្សត្រក្សាន្តសោយព្រះវិលាល័យ ៗ ទៅ

កើតក្នុងឋានតុសិតា មានមហាប្រាសាទខ្ពស់ត្រៃឈ ប្រាំដណ្តប់យោជន៍ -
យល់ប្រពៃ និរភ័យនិរទុក្ខសែនសុខា ៗ ចុះចាកច្យុតស្រុតចុះមក យោន
យកកំណើតជាមនុស្សា ដូនបក្រពាង្សវង្សក្សត្រា ដូនជាសេនាបតីផង ៗ
វិលកើតវិលស្លាប់រាប់យូរក្រៃ ច្រើនអសង្ខេយ្យពេកកន្លង តាមដោយផល
កម្មដែលចាំបង បំណាំងនៃវដ្តសង្សារ ៗ កំណើតអនិច្ចំតាំងពុំទៀង ដូន
ល្អៀងមិនល្អដោយយថា- កម្មកើតអំពីទិតណ្ហា ដូនណាកើតជាមនុស្ស
ក្រក្រៃ ៗ ដូនកាលកើតជាសត្វម្រឹគា ដូនណាកើតជាសត្វបក្សី ជា
ព្រហ្មទេវតានាគគតក្រៃ តែពង្សដិនស្រីប្រល័យខ្ជាប់ ៗ ប្រឹងចំសន្សំ
សាងសីលទាន ពុំដែលខ្ជិលតាមដោយទំលាប់ យោនយកកំណើតកើត
គួរគាប់ មិនត្រូវអក័ព្វប្រាំបីស្ថាន ៗ ព្រះអង្គបំពេញទសបារមី បរិបូណ៌
ឥតបីខ្វះខាតខាន បតុរាសង្ខេយ្យកំរៃបាន សែនកប្បអាសាទៃផុតជាតិ ៗ
ស្តេចលះសម្បត្តិតុសិតា មកចាប់ជាតិជាព្រះសិទ្ធាថ ចេញទ្រង់បព្វជិតពុំ
គិតញាតិ ចំឃ្លាតសង្វាតសាងចរិយា ៗ បានត្រាស់ចំហុតជាពុទ្ធអង្គ
ហើយទ្រង់សំដែងធម៌ទេសនា ប្រោសសត្វច្រើនលន់អនន្តា ដាក់ដល់
ថ្ងល់មហានិព្វានពិត ៗ ទើបព្រះសាស្តាចរិយវង្ស ស្តេចទ្រង់និទានរឿង
សព្វសិទ្ធិ ដោយបទគាថាជាអតីត សកុណជាតិជិតវិភាគ ៗ លុះដួប

គំរប់ចប់គ្រប់គ្រាន់ តាមជាន់ជាតកដោយប្រការ ទ្រង់រើសប្រមូលរួមជាគា នាំមកទេសនាជាបរិយាយ ។ ភិក្ខុអើយ ! កំលៀងចោរទ្រុះក្បត់ កើតជាទេវទត្តគាត់អន្តរាយ ព្រះធរណីស្រូបទាំងរូបកាយ ធ្លុះធ្លាយធ្លាក់ដល់មហាអវិចី ។ ព្រះបាទព្រហ្មទត្តមហាក្សត្រា ចេរវិលវិធីជាគហបតី អនាថ. បិណ្ឌិកមហាសេដ្ឋី ឧបដ្ឋាកជិនស្រីសម្ពុទ្ធ ។ កុសុមានាងនាថពុំឃ្លាតឃ្លៀត ជាក់ជៀងជួបជួនចាប់ជាតិជា នាមនាងពលីកាសមសោភា គបដោយអភិញ្ញាសម្មាបត្តិ ។ កោណ្ឌញ្ញសេដ្ឋីជាបិតា នៃព្រះកុមារចេរវិលប្ញាត់ ជាព្រះសុទ្ធោទន៍មហាក្សត្រ បានលុះអរហត្តកាត់សង្ខារ ។ ខេមាភរិយានៃកោណ្ឌញ្ញ ចេរវិលវិធីវិញដោយយថា- កម្មបានមកជាពុទ្ធមាតា នាមនាងមហាមាយាថ្លៃ ។ សុវណ្ណកេសរបវរមិត្រ យោនយកជាតិជិតជាកកៃ្យ សាពេជ្រលើសលុបទាំងភពត្រៃ នាមនៃព្រះនាងនាថពិម្ពា ។ ព្រះមហាសត្វសិទ្ធត្ថទ្វីគ្គ គឺអង្គអញត្រាស់បញ្ជាស់ធម្មា ប្រោសសត្វស៊ុសសត្វភូមិកពការ ដាក់ដល់ថ្កល់នាមមហានិព្វាន ។

សាធុនរៈជាតិទាំងឡាយ ចូរស្តាប់បរិយាយរឿងនិទាន សកុណាជាតកទុកទូន្មាន គ្រប់ប្រាណសប្បុរសទាំងប្រុសស្រី ។ គ្រាន់មើលគ្រាន់ស្តាប់គ្រាប់គ្រងវង្ស ទំនងទំនើបទើបតែងថ្មី ក្រែងជួនពុំចំសមសេចក្តី

សាំងអត់ទោសក្រោសមេត្តា ៗ ត្បិតខ្ញុំលើកពាក្យពិបាកណាស់ ខុសខ្លះ ត្រូវខ្លះតាមតែថា បន្ទុបន្ទាយល្បាយវោហារ តែងតាមប្រាជ្ញាអធ្យាស្រ័យ ៗ ហើយប្រើនតែពាក្យល្អៀងឃ្លៀងឃ្លាត សម្បូរលាវាទវាចាក្រៃ ក្រែងជូនជាប់ទោសជាបច្ច័យ និស្ស័យវាសនាអនាគត ៗ សូមមានស្មាលាវេរាកម្ម កុំឲ្យបងិតាំឲ្យរួចផុត មគ្គផលឯណាជាសុខសុទ្ធ សូមបានចំហុតដល់អញខ្ញុំ ៗ បើអ្នកណាស្តាប់ចាប់ចូលចិត្ត តាមរឿងសព្វសិទ្ធិជាសុខុម ប៉េះឃើញខាតខុសលោះដោយជុំ សូមសុំជួយថែមកែមវាចា ៗ បើកែមានតែឲ្យជាងនេះ ប្រសិនមិនបេះកុំចង់ថា រឿងនេះថែងចប់សព្វប្រការ ឥតិបកាកទិដ្ឋិតំ ៗ

រឿងសព្វសិទ្ធិ ចប់ប៉ុណ្ណេះ ។

# រឿងប្រដៅមនុស្សដោយវាយមួយរយរំពាត់

លោក ស៊ុខ-ហ៊ីន រៀបរៀង

---

កាលពីព្រេងនាយ មានព្រះរាជា ១ ព្រះអង្គ សោយរាជ្យក្នុងនគរមួយ ។ ព្រះរាជាអង្គនោះ ទ្រង់សោយព្រះស្ងោយតែមួយបែប គឺព្រះស្ងោយ ដែលនាយពិសេសគេធ្វើពីសាច់ត្រីប៉ុណ្ណោះ ។

ខណៈនោះ មហាមេឃមិនបង្អុរភ្លៀងអស់កាលដ៏យូរអង្វែង, ស្ទឹងទន្លេបឹងបួទាំងឡាយ ក្នុងព្រះរាជអាណាចក្រ ក៏គោកគាំងរីងស្ងួតអស់ជាច្រើនកន្លែង ។ នាយពិសេសលំបាកនឹងរកត្រីយកមកធ្វើព្រះស្ងោយពន់ពេក ។ ព្រះរាជាក៏ទ្រង់ព្រះរាជបញ្ជាឲ្យផ្សាយព្រះរាជសារ ទៅគ្រប់ទីតំបន់ក្នុងព្រះរាជអាណាចក្រថា "បើអ្នកណារកត្រីមកថ្វាយយើងបាន យើងនឹងឲ្យរង្វាន់ជាទីគាប់ចិត្តដល់អ្នកនោះពុំខាន" ។

លំដាប់នោះ មានកសិករម្នាក់បានឃើញព្រះរាជសារផ្សាយទៅគ្រប់ទីតំបន់ដូច្នោះ មានចិត្តស្វាមីភក្តិចំពោះព្រះរាជាជាខ្លាំង បានខំដើររកត្រីក្នុងទីផ្សេងៗ ទាល់តែបាន, លុះបានហើយ ក៏យកត្រីនោះទៅថ្វាយព្រះរាជាដោយខ្លួនឯង ; ទៅដល់ព្រះរាជវាំង , ពាហានឆ្មាំទ្វារក៏ហាមឃាត់មិនឲ្យចូលសោះ, កសិករនោះ ក៏អង្វរករដោយពាក្យទន់ផ្អែមល្ហែមផ្សេងៗថា "សុំលោកមេត្តាដល់ខ្ញុំ ឲ្យខ្ញុំចូលទៅក្នុងព្រះរាជវាំង នាំត្រីនេះ

ទៅថ្វាយព្រះរាជាដោយខ្លួនឯង" ។ ទាហានឆ្មាំទ្វារពោលថា មិនបាច់អ្នកចូលទៅខ្លួនឯងទេ សុំឲ្យត្រីនេះមកខ្ញុំ យកទៅថ្វាយព្រះរាជាឲ្យ មិនបាច់ទៅណាទេ អ្នកកុំព្រួយបារម្ភអី ! ។ កសិករក៏ពុំព្រមប្រគល់ត្រីនោះឲ្យទៅទាហានឆ្មាំទ្វារសោះ បេះតែទទូចអង្វរគេ ដោយសំដីផ្អែមល្ហែមផ្សេងៗ ទីបំផុតទាល់តែទាហានឆ្មាំទ្វារពោលថា "បើអ្នកត្រូវការចូលទៅក្នុងព្រះរាជវាំង យកត្រីទៅថ្វាយព្រះរាជាដោយខ្លួនឯង មិនអីទេ យើងនឹងអនុញ្ញាតឲ្យអ្នកចូលទៅបាន តែបើព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យប្រទានរង្វាន់អ្វីជាទីគាប់ចិត្តដល់អ្នក ត្រូវអ្នកបែងចែករង្វាន់នោះឲ្យយើងពាក់កណ្ដាល" ។ កសិករបានឮដូច្នោះ ទើបតបថា "មិនអីទេ កាលបើខ្ញុំចូលទៅក្នុងវាំងហើយ បានរង្វាន់អ្វីអំពីព្រះរាជា សឹមខ្ញុំបែងចែករង្វាន់នោះឲ្យអ្នកពាក់កណ្ដាលពុំខានទេ" ។ ទាហានឆ្មាំទ្វារបានស្ដាប់ដូច្នោះហើយ ក៏មានសេចក្ដីត្រេកអរជាពន្លឹក ទើបអនុញ្ញាតឲ្យកសិករនោះចូលទៅ, អំពើបែបនេះ បង្ហាញឲ្យឃើញថា ទាហានឆ្មាំទ្វារជាអ្នកមិនសុចរិតយុត្តិធម៌ ស្មោះត្រង់ចំពោះមុខងាររបស់ខ្លួនដោយពិត ។

កសិករនោះ លុះដើរចូលទៅបាន២-៣ជំហានក៏ត្រឡប់មកសួរទាហានឆ្មាំទ្វារវិញថា លោកនាយ! លោកឈ្មោះអ្វី? ទាហានឆ្មាំទ្វារនោះប្រាប់ថា ខ្ញុំឈ្មោះអាយ័ក្សខ្វាក់ភ្នែកម្ខាង" ។ កសិករពោលថា "បានជាខ្ញុំសួរនាំឈ្មោះលោកនាយឲ្យជាក់លាក់ដូច្នេះ ក្រែងលោលោកនាយផ្លាស់វេន

យាម កាលបើខ្ញុំចេញពីក្នុងវាំងមកវិញ បានរង្វាន់អ្វីអំពីព្រះរាជា ហើយបែងចែករង្វាន់នោះឲ្យទៅខុសឈ្មោះលោកនាយ ដូចដែលបានសន្យាគ្នា " ។ លុះកសិករនោះចូលទៅដល់ ក៏ថ្វាយបង្គំព្រះរាជា ហើយថ្វាយត្រីនោះ ។ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យចំពោះកសិករនោះ ដែលមានចិត្តស្វាមីភក្តិចំពោះព្រះអង្គយ៉ាងក្រៃលែង ហើយទ្រង់មានព្រះរាជឱង្ការថា «អើកសិករ! បើអ្នកត្រូវការចង់បានរបស់អ្វីពីយើង ក៏ចូរថាមកចុះ បើយើងអាចឲ្យបាន យើងនឹងឲ្យ"។ កសិករក្រាបបង្គំទូលថា "ព្រះករុណាថ្លៃវិសេស បើព្រះអង្គទ្រង់ព្រះមេត្តាប្រោស ព្រះរាជទានរង្វាន់ហើយ សូមទ្រង់ព្រះមេត្តាប្រោស ឲ្យវាយទូលព្រះបង្គំជាខ្ញុំឲ្យតាល់តែគ្រប់១០០រំពាត់ជារង្វាន់ចុះ, ទូលព្រះបង្គំជាខ្ញុំ ពុំប្រាថ្នារបស់អ្វីដែលព្រះអង្គមិនអាចព្រះរាជទានបាននោះទេ" ។ ព្រះរាជាមិនទ្រង់ជ្រាបបំណងរបស់គេ ក៏ទ្រង់លំបាកក្នុងព្រះរាជហឫទ័យជាខ្លាំង ទើបត្រាស់តបថា "នែបុរសកសិករ! អ្នកចូរឈប់និយាយពីរឿងវាយដោយរំពាត់ទៅ បើអ្នកត្រូវការដោយមាសប្រាក់កែវកងឯណា ក៏ចូរប្រាប់មកចុះ យើងនឹងរកឲ្យបានគ្រប់យ៉ាង" ។ កសិករក្រាបទូលថា "បពិត្រព្រះសម្មតិទេព! បើទ្រង់ព្រះមេត្តាប្រោស ញុំាងសេចក្តីប្រាថ្នារបស់កសិករឲ្យពេញបរិបូណ៌ ក៏សូមទ្រង់ព្រះរាជទានរង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ ដោយការវាយឲ្យតាល់តែគ្រប់ ១០០ រំពាត់ចុះ, បើមិនដូច្នោះទេ ទូលព្រះបង្គំជាខ្ញុំ នឹងថ្វាយបង្គំលា សូមសួស្តីបូរមានចំពោះ

ព្រះអង្គចុះ ” ។ កាលព្រះរាជាមិនទ្រង់ឃើញផ្លូវដទៃ ដើម្បីញុំាងសេចក្តីប្រាថ្នារបស់កសិករឲ្យពេញបាន ទើបត្រាស់បង្គាប់ឲ្យនាយតម្រួតបាត់ការដាក់ព្រះរាជអាជ្ញា ។ លុះតម្រួតវាយបាន ៥០ រំពាត់ ដោយថ្នមៗ ព្រោះជាមនុស្សគ្មានទោសកំហុស គឺវាយបង្គ្រប់តែកិច្ចប៉ុណ្ណោះ , កសិករក៏ស្រែកប្រាប់ថា «ឈប់បង្អង់វាយត្រឹមប៉ុណ្ណោះសិនចុះលោក! ព្រោះទាហានឆ្មាំទ្វារម្នាក់ ឈ្មោះអាយ័ក្សខ្វាក់ភ្នែកម្ខាង ជាអ្នកត្រូវបានទទួលចំណែកនៃរង្វាន់ដោយការវាយនេះដែរ ដ្បិតអីខ្ញុំបានចុះសន្យាទឹងគេទុកថា រង្វាន់ឯណាដែលខ្ញុំបានអំពីព្រះរាជា ត្រូវបែងចែកពាក់កណ្តាល ឲ្យដល់ទាហានឆ្មាំទ្វារនោះ បើមិនដូច្នោះទេ ខ្ញុំទឹងមិនបានចូលគាល់ នាំត្រីមកថ្វាយព្រះរាជាឡើយ, ។ ហេតុនេះ សូមមេត្តាចែករង្វាន់ គឺការវាយ៥០រំពាត់ខាងក្រោយនេះ ដល់ទាហានឆ្មាំទ្វារនោះ ដើម្បីកុំឲ្យខូចសច្ចៈរបស់ខ្ញុំដែលបានប្តេជ្ញាទឹងគេហើយ ” ។

ដោយការអង្វររបស់កសិករនោះ , ទាហានឆ្មាំទ្វារឈ្មោះអាយ័ក្សខ្វាក់ភ្នែកម្ខាង ក៏ត្រូវគេនាំខ្លួនយកមកក្នុងទីចំពោះព្រះភ័ក្ត្រព្រះរាជា ហើយវាយខ្នង ៥០ រំពាត់ យ៉ាងធ្ងន់ៗ ។

ព្រោះសេចក្តីឈ្លាសវៃនៃកសិករនោះ, ព្រះរាជាទឹងមន្ត្រីទាំងឡាយមានសេចក្តីស្ងើចសរសើរក្នុងចិត្តជាងខ្លាំង ក៏តាំងបន្ថែមសេចក្តីរាប់អានចំពោះកសិករនោះ យ៉ាងសន្ធឹក ។

រឿងនេះ គឺជាបទរៀនមួយបែប ដែលកសិករប្រឌិតឡើង ដើម្បីប្រដៅមនុស្សលោកទូទៅ ឲ្យមានចិត្តប្រកបដោយសុចរិតយុត្តិធម៌ ក្នុងមុខងាររបស់ខ្លួនគ្រប់ៗគ្នា ។

វិធីនេះជាគន្លងផ្លូវនៃយុត្តិធម៌ មិនមែនជាវិធីធ្វើឲ្យទោសចំរើនឡើងដោយការធ្វើអាក្រក់តបនឹងអាក្រក់ទេ , គឺជាវិធីតបតនឹងសេចក្ដីអាក្រក់ដោយសេចក្ដីល្អ ដើម្បីវែកញែករកសេចក្ដីសុចរិតយុត្តិធម៌ សម្រាប់មនុស្សលោកតទៅ ។

សេចក្ដីនេះ សមដូចពុទ្ធភាសិតក្នុងធម្មបទខុទ្ទកនិកាយថា :

អក្កោធេន ជិនេ កោធំ    អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន    សច្ចេនាលិកវាទិនំ ។

បុគ្គលគប្បីឈ្នះបុគ្គលក្រោធ ដោយការអត់មិនក្រោធតប, គប្បីឈ្នះបុគ្គលអសប្បុរស ដោយសេចក្ដីសប្បុរស, គប្បីឈ្នះបុគ្គលកំណាញ់ដោយការឲ្យ, គប្បីឈ្នះបុគ្គលលេះលោះ ដោយពោលពាក្យទៀងត្រង់ ។

# រឿងបាង្សយ័ន្ត

(តមក)

លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត

## បទ កាកគតិ

កាលនោះបុរោហិត អ្នកប្រាជ្ញព្រាហ្មណ៍ព្រឹទ្ធ ប្រដៅសិស្សផង អង្គុយរៀនកល់ រៀនធម៌អឺនកង ច្រើនទៃក្រកន្ទង ជុំជាប្រក្រតី ។ ព្រាហ្មណ៍យល់ព្រះអង្គ ប្រសើរកិម-ន្តលគាប់ពិសី វរធោមវរលក្ខណ៍ វរក្រៅសោភី ព្រាហ្មណ៍ប្រាជ្ញបតី កើតក្តួចស្រឡាញ់ ។ គេជ:សម្ភារ សម្ដេចកូបាល សានពីមុនមិញ ព្រាហ្មណ៍យល់ហើយគិត ក្នុងចិត្តឯងវិញ កន្ទក់កន្ទេញ សោកសារសើរថា ។ រីអ្នកនេះនៃ រូបល្អប្រពៃ ដើរមកពីណា មិនគឺកូនពស្ត្រ តាំងផ្កាសខ្ចីខា សមកូនក្សត្រា ពីបរទេសឆ្ងាយ ។ សមមកនេះណា រករៀនសាស្ត្រា ធម៌ផងតាំងឡាយ អញហៅមកសួរ ទទួលនិយាយ ប្រការសម្ងួយ ឲ្យអស់សេចក្ដី ។ ទើបព្រាហ្មណ៍ប្រាជ្ញហៅ ថារើយនៃទៅ កំឡោះពិសី អាពុកយល់ទៅ ល្អញស្ដៅប្រិមប្រិយ អញ្ជើញអ្នកលី-លាមកឯអាយ ។ អាពុកទឹងដ-ណ្ដឹងអ្នកប្រុសគន់ បន្ទិចពីកាយ ក្សណោះនោះព្រះអង្គ ដំទ្រង់ធោមធាយ ឮព្រាហ្មណ៍ប្រាជ្ញប្រាយ ហៅដូច្នោះណា ។ ទើបអ្នកទតទៅ យល់សិងសិស្សនៅ រៀនធម៌សាស្ត្រា ស្ងួនស្ដេចគិតក្នុង កំឡុងទ័យា ទ្រង់ព្រះចិន្ដា គ្រែកអរ

ពេកក្រៃ ៗ អញមកនេះម្តង បានដូចបំណង ពុំក្រឡើយនៃ អញនឹង សំណាក់ ពឹងពាក់អាស្រ័យ យកព្រាហ្មណ៍នេះនៃ ជាអាពុកធម៌ ៗ ហើយអញនឹងរៀន ឲ្យអស់រៀន សិល្បសាស្ត្រាគាថា បំណេះអ្វីៗ កុំបីទើសទាល់ ដូចអញគិតគាល់ ប៉ុនប៉ង់ប្រាថ្នា ៗ ទ្រង់ចិន្តាស្រេច នោះទើបស្តែងស្តេច យាងយាសយាត្រា ចរចូលទៅដ្ឋាន គ្រឹះស្ថានព្រាហ្មណ៍ណា ព្រាហ្មណ៍សោតបរា សាកសួរព្រះអង្គ ៗ ថាហៃអ្នកមាស ឯកឯងយាងយាស មកពីកន្លែង ដំបន់ឋានណា យាត្រាត្រាច់ត្រង់ នេះអ្នកចោទចង់ ប្រការកលអ្វី ៗ ចូរអ្នកប្រុសប្រាប់ ឲ្យអាពុកស្តាប់ ដឹងដើមសេចក្តី មាសមកនេះណា ប្រាថ្នាពស្តុអ្វី ចូរអ្នកស្រដី កុំលាក់លៀមឡើយ ៗ មួយសោតនាមករ កូនស្ងួនបវរ ឈ្មោះអ្វីកូនអើយ រីស្រុកទេសគន់ ដំបន់ត្រាណត្រើយ នៅឯណាឡើយ នាមហៅស្រុកអ្វី ? ៗ មួយទីសោតណា រីឯមាតា បិតាជាតី បង្កើតនៃបា ស្ងួនក្ខាពិសី នាមហៅឈ្មោះអ្វី ? ណាអ្នកកូនអើយ ៗ ក្សណនោះព្រះអង្គ អម្បូរពូជពង្សក្សត្រាត្រាណត្រើយ ស្តេចស្តាប់ព្រាហ្មណ៍សួរ ទទួលមកហើយ ទើបព្រះអង្គឆ្លើយ សារសងប្រាប់ ៗ ថាខ្ញុំនេះណា ជាកូនក្សត្រា. ធិពជជៀស្លជ័យ ជាចៅបូរី ដែនដីគពាក្រៃ ឥស្សូរឯងឮ គ្រប់គ្រងភាព ៗ ខ្ញុំឈ្មោះសុវណ្ណ-កុមារសោភ័ណ ត្រាច់ចរយាត្រា មកទាំងម៉្លេះហោង ប៉ុនប៉ង់ប្រាថ្នា រៀនសិល្បសាស្ត្រា អស់គាថាធម៌ផង ៗ ក្សណនោះព្រាហ្មណ៍ស្តាប់ ព្រះ

អន្តថ្លែងប្រាប់ បទដើមទំនង ដំណើរក្សត្រា ប្រាជ្ញាប៉ុនប៉ង រករៀនធម៌ផង សព្វព្រះហឫទ័យ ។ ព្រាហ្មណ៍ថាខ្ញុំសូម អ្នកមានឧត្តម ជាកូនធម៌ថ្លៃ នឹងប្រដៅសិល្ប ធម៌វិសេសសេយ្យ តាមតែព្រះទ័យ អ្នកនឹងប្រាជ្ញា ។ កាលនោះព្រះចៅ ស្តែងស្តេចអ្នកនៅ នឹងព្រាហ្មណ៍ហោក ព្រាហ្មណ៍ប្រដៅធម៌ សព្វសិល្បសាស្ត្រា សម្តេចក៏ជា រៀនអស់ធម៌ផង ។ ហេតុព្រះប្រាជ្ញា ចិត្តវិសេសប្រា- ក់ដគបគន្ធន ស្តេចរៀនសេធម៌ សិល្បសាស្ត្រាផង បានដូចបំណង ចប់ប៉ិនដកត្រៃ ។ ព្រាហ្មណ៍សរសើរថា កូនស្ងួនពុំហ៊ា មានប្រាជ្ញាថ្លៃ អ្នករៀនអស់ធម៌ សព្វសិល្បសាស្ត្រសេយ្យ តែរំពេចនៃ ចប់សាស្ត្រាគម (១) ។ អាពុកនឹងបែងបំណាច់ខ្លួនឯង ឲ្យមានឧត្តម តាំងតួអាពុក សេពសុខភិរម្យ ជាអ្នកប្រាជ្ញធំ លើសលែងលោកា ។ អាពុកនឹងយក បាបុត្រពន្លក កូនស្ងួនពុំហ៊ា ទៅថ្វាយព្រះបាទ នរោថជេដ្ឋា រីឯចិត្តបា គិតម្តេចកូនអើយ ។ ព្រះអង្គស្តេចស្តាប់ វាក្យពីរោះគាប់ ព្រាហ្មណ៍ប្រាប់ឡោះហើយ ក្សៀណក្សត្រត្រកូល បង្គួលឡាស់ឆ្លើយ អ្នកអាពុកអើយ ខ្ញុំនឹងថាអ្វី ។ ក្សៀណនោះព្រាហ្មណ៍យក ព្រះអង្គពន្លក សពោធិជិនស្រី ទៅថ្វាយព្រះបាទ

---

១ សាស្ត្រ ន. (សំ.ម.) គម្ពីរ, ច្បាប់, ក្បួន, តម្រា, អាគម ។ ន. (សំ.ម.) ការរៀ-សូត្រ, ការចេះដឹង; ផ្សំសាស្ត្រានឹងអាគម ជាសាស្ត្រាគម ចប់សាស្ត្រាគម គឺចប់ការរៀនសូត្រតាមគម្ពីរ ក្បួនច្បាប់ ។

ខរទាចនរបតី ជាចៅបូរី នគរបញ្ចាល់ ។ ព្រាហ្មណ៍ទូនសិរសី ក្រួញ
ក្រាបវន្ទិយ បង្គំទូលថា ខ្ញុំថ្វាយកូនប្រុស ស្រេចស្រស់សោភា ជា
ខ្ញុំករុណា តាំងខ្ញុំឯងហោង ។ ក្សិណានោះក្សត្រា ស្តេចបន្ទូលថា
ព្រាហ្មណ៍នេះជាមួន ព្រាហ្មណ៍យកបុត្រា ពុំឆាស្ងួនគ្រង មកថ្វាយជាស្នង
តួព្រាហ្មណ៍ប្រាជ្ញប្រាយ ។ កូនព្រាហ្មណ៍តើញាំង ចេះចប់ទូទាំង សិល្ប
សាស្ត្រសព្វសាយ ធម៌អាថ៌ក្បួនច្បាប់ គម្រោប់ទាំងឡាយ ដូចព្រាហ្មណ៍
ប្រាជ្ញប្រាយ ឬទេព្រាហ្មណ៍ព្រឹទ្ធ ។ ទើបព្រាហ្មណ៍ទូលថា បពិត្រ
ព្រះមហា–ក្សត្រថ្លៃទ្រង់រិទ្ធិ កូនខ្ញុំនេះណា ប្រាជ្ញាចាំពិត ទោះខ្ញុំឯងគិត
ផ្ទឹមផងពុំបាន ។ ស្តេចស្តាប់ព្រាហ្មណ៍ទូល ព្រះបាទឥស្សូរ ក្សត្រ
ថ្លៃថ្កើងថ្កាន ត្រាស់ថាអញអរ សាទរស្មោះស្មាន អរជៀតព្រាហ្មណ៍មាន
កូនប្រុសប្រាជ្ញប្រាយ ។ ទ្រង់ព្រះចិន្តា ក្នុងព្រះទ័យា ថាទុអញស្តាយ
កូនព្រាហ្មណ៍នេះណា សោភាពោមពាយ លែងប្រុសទាំងឡាយ
លោកិយនេះណា ។ ដៀតតែយសតូច ពុំស្មើពុំដូច នាងនាថធីតា
បុត្រីសំឡាញ់ កូនអញនេះណា នឹងផ្សំផងគ្នា ពុំបានឡើយហោង ។
សម្តេចរាជា ព្រះអង្គករុណា ស្រឡាញ់ស្នេហ៍ស្នង អាសូរពោធិ-សត្វ
វិសេសហោង លើសលែងអ្នកផង ទាំងឡាយនា ។ ។ ឯពុទ្ធង្កូរ
ពន្ធកបណ្ឌូល សពេជ្ញសាស្តា ព្រះអង្គតែងទៅ គាល់ហៀកជា
តាំងព្រាហ្មណ៍ហោរា ជាអ្នកប្រាជ្ញប្រាយ ។ រីឯបុរោហិត ហោរា-

ព្រាហ្មណ៍ព្រឹទ្ធ នៅសុខសប្បាយ រក្សាព្រះអគ្គ ទ្រើសទ្រង់ធោមធាយ
ក្សត្រថ្ងៃពណ្ណរាយ នៅទីនព្រាហ្មណ៍ណា ។ ព្រះបាទឥស្សូរ ក្សត្រា
ត្រកូល ព្រះចៅបញ្ចាល ស្ដេចមានបុត្រី ស្រស់ស្រីសោភា នាងទ្រង់
នាមា បទុមកេសរ ។ នាងនាថនារី កបបញ្ចត្រ្ទើយ ធោមធាយ
បវរ ដូចចន្ទថែងចាំង ទូវាំងអម្ពរ ជាឆ្នើមនគរ បញ្ចាលបុរី ។
នាងល្អគន្ធង ទ្រទេសទង់វង់ ទ្រទន់សល់ស្រី វរអគ្គវរលក្ខណ៍ វរកេត្រ
សោភី ជាមកុដអស់ស្រី ទាំងត្រៃភពផង ។ ទោះបីប្រើសូត្រ ប្រពៃ
គាប់គួរ ថ្វាថ្ងៃកន្ទង នៅត្រៃត្រឹង្សា សួតានាយហោង ទោះទឹងផ្ទឹមផង
នាងពុំបានណា ។ សម្ដេចជនទី ជនកបតី កូនស្ងួនពុំងា ស្ដេចឲ្យស្រី
ថ្ងៃ នៅព្រប្រាង្គប្រា-សាទសួគ៌សោភា មាសមៃព្រោងព្រាយ ។ ស្ដេច
ឲ្យស្រាលស្រី ស្រស់ស្រៀបប្រិមប្រិយ (១)ក៏លៀនទាំងឡាយ ឲ្យចាំ
រក្សា បុត្រក្សាធោមធាយ នៅសុខសប្បាយ លើប្រាសាទសម ។
រតនពជធីតា ធោមធាយសោភា ពាលពេញក្រមុំ ស្រីស្រស់ថ្វាថ្ងៃ ល្អម
ល្អៃក្មៀវកុំ នាងនាថឧត្ដម សោឡសឆ្នាំណា ។ នាងនៅប្រាសាទ
ប្រសើរស្អាងស្អាត មាសមៃសោភា ទីងអស់ស្រីឆ្គារ បរពារនាងណា
គៀមក្សាន្តសុខស-ប្បាយបរិបូណ៌ក្រៃ ។ ហេតុតែបុណ្យនាង បរិបូណ៌
បានសាង ជាអសន្ធយ្យ ទីងព្រះពោធិ៍ សត្វវិសេសថ្ងៃ ទីងបាន

១ ពាក្យសៀម ប្រែថា បងបិញ្ចឹម ។

មូលមៃ ត្រីត្រកផង់គ្នា ៗ មានកាលមួយថ្ងៃ ស្រីរតន៍ថាថ្ងៃ បើក ព្រះកៅវិតា ទតយល់ព្រះអង្គ ពូជពង្សក្សត្រា វិស្ដង់ស្ដេចលីលា ទំម ប្រាសាទថ្ងៃ ៗ ទើបនាងចិន្តា ក្នុងព្រះទ័យា ថាអ្នកនេះនៃ មកពី ឋានណា ថ្វកនាសត្វថ្ងៃ មានរូបប្រពៃ សស្ដ៍សមសោភា ៗ ទើប នាងប្រាប់ទៅ ភីលៀងមួយនៅ ខាងនាងធីតា បងអើយបងមើល គេដើរនោះណា រូបឆោមឆាយា ចំណាប់ពេកក្រៃ ៗ នាងនាថជាយា នូវភីលៀងភ្លា គយគន់វៃពៃ ហើយសឹងសរសើរ ដំណើរក្សត្រថ្ងៃ ទាំងពីរនាក់នៃ ពុំលែងឡើយណា ៗ នាងគយគន់មើល ព្រះរាជ ដំណើរ លុះអស់នេត្រា នាងនារីរតន៍ ចង់ចិត្តស្នេហា គិតព្រះរាជា ពិត ពុំភ្លេចឡើយ ៗ នាងនាថឆោមឆាយ ធ្វើជានិយាយ ឯទៀតព្រងើយ ធ្វើពុំនាំពា ហាក់ដាក់តោះតើយ គឺមោះពុំស្បើយ ក្នុងព្រះទព ៗ

បទព្រហ្មគីតិ

លុះចូលដល់រាត្រី នាងនារីរតន៍ទិព្រា ទ្រង់ព្រះរាជចិន្តា រំពឹងពីព្រះ អង្គថ្ងៃ ៗ ថាឲអង្គកល នាអញយល់អំពីថ្ងៃ ប្រុសនោះល្អប្រពៃ តើគាត់ មកពីឋានណា ៗ បើដោយដែលគញយល់ រូបនិមិលឆោមសោភា សម គាត់កូនក្សត្រា ត្រាច់មកពីឋានចម្ងាយ ៗ ពុំគឺកូនសេនា រាស្ត្រប្រជា នៅស្រុកឆ្ងាយ បើកូនអ្នកក្សណក្សយ មិនមានរូបដល់ម្ល៉េះណា ៗ ល្អ វិថូកនាលោកិយ ហាក់មកពីត្រៃត្រឹង្ស ព្រះភក្ត្រដូចចន្ទ្រា ត្រចះថែង

ពេញបូណ៌មី ៗ គន់ឯអស់ព្រះអង្គ សឹងវរវង់សមសោភី ល្អល្អះអស់
ឥន្ទ្រីយ រូបល្អញៀតពាលប្រពៃ ៗ នាងទ្រង់ព្រះចិន្តា វរជាយាព្រួយ
ព្រះទ័យ គិតគឹងវរងអាល័យ អាណោះលន់ពន់ប្រមាណ ៗ ឲអញឥឡូវ
អើយ ធ្វើម្ដេចឡើយក៏ឯងបាន អ្នកៈនាះមករួមឋាន ជាស្វាមីអញសព្វ
ថ្ងៃ ៗ អញបង់ឲ្យទៅសួរ យល់ពុំសួរពេកណាស់នៃ គិតទៅវង់ក្រក្រៃ
ឥតអ្នកណាទីងជួយចាត់ ៗ បើអញស្ងៀមទេនៅ ក្រែងគាត់ទៅឯមុខបាត់
ក៏ក្ដីនេះក្រគាត់ នឹងធ្វើម្ដេចឥឡូវណា ៗ រូបអ្នកល្អពិសី ដូចបុណ៌មីព្រះ
ចន្ទ្រា គួរគួសិទស្នេហា ជាស្វាមីអញនេះសម ៗ គិតឡើងពត្រើហ្មត់ នារីគេង
រែងបារម្ភ នាងនាថពុំបានផ្ទំ ឡើយនាងគិតព្រះកជា ៗ លុះព្រឹកព្រហាម
ស្រាង ស្រេចហើយនាងនាថជាយា នាងគេងតាក់ក្រឡា បន្ទំទែនទិព្វពង្រៀៗ
ទើបនាងសោយព្រះស្ងួន ស្រេចស្រិតទៅសោយព្រះស្រី ហើយនាងនាថ
ទៅបើកព្រះកៅតាទៀត ៗ នាងផ្អកគិតអាល័យ គង់ព្រះទ័យវរងបង្អៀត
នាងគយគន់មើលទៀត នាងពុំយល់ព្រះភូមី ៗ នាងគង់ឯងសញ្ចប់
ស្ងៀមស្ងួតស្ងប់ព្រះគ្រស្រី នាងនាថពាំស្រេង ចរចាចែងដល់តិចណា ៗ
គិលៀងជំនិតនាង ចូលនាំនាងកដធីតា យល់នាងជាកក្រោ ស្រពោន
ពន្ធុចសព្វដង ៗ គិលៀងអញ្ជាស្រ័យ ថាស្រីថ្ងៃមានបេចង់ នឹងអ្នកប្រុស
ណាហោង ទើបជាទុក្ខអនិត្ត ៗ គិលៀងទូលស្នើថា នាងធីតាអង្គត្រឹ
ស្រពោនព្រះភក្ត្រស្រី ចូរអ្នកថ្ងៃប្រាប់ខ្ញុំ ៗ ទើបនាងថាបងអើយ ឥឡូវ

ហើយអញប្អូនមហា- ព្រួយចិត្តពន់ពេកណា៎ បងមិនជួយគិតប្អូនឡើយ ៗ ភីលៀងទូលវាងវៃ ព្រួយព្រះទ័យអ្វីមាសអើយ កុំអ្នកថ្ងៃលាក់ឡើយ ប្រាប់ឲ្យបងបានដឹងផង ៗ ទើបនាងត្រាស់ថាហៃ បងឯងនៃស្រាប់ហើយណា៎ ស្មើកើតឯកមាតា តើប្អូនខឹងលាក់ធ្វើអ្វី ៗ បងអើយប្អូនបងធ្លាប់ ដ្បិតប្អូនយល់ប្រុសពិសី ពីម្សិលអង្គិគ្គ តើគាត់មកពីឋានណា ៗ បងអើយ អញប្អូនថប់ គិតទៅគ្រប់ហើយវែងជា ព្រួយចិត្តពេកមិនគ្រា ស្បើយពីទ្រូងដល់តិចឡើយ ៗ បើអ្នកណាទៅដល់ សួរឲ្យយល់ពាក្យគាត់ហើយ អ្នកនោះណាបងអើយ អញនឹងឲ្យរង្វាន់ផង ៗ នាងបរបាបញ្ញៀង ទើបភីលៀងទូលរឹងស្នង អ្នកនោះទុកងារបង កុំព្រួយចិត្តណា៎មាសថ្លៃ ៗ នាងស្ដាប់ភីលៀងថា ទូលធានាដូច្នោះនៃ ទើបនាងត្រាស់ថាហៃ បើបងទៅសួរឲ្យជាក់ ៗ សួរឈ្មោះម្ដាយអាពុក សួរទាំងស្រុកទាំងនាមអ្នក បងសួរឲ្យជាក់លាក់ ក្រែងគាត់មានប្រពន្ធហើយ ៗ ភីលៀងក្រួញក្រាបលា នាងជីតាពុំលង់ឡើយ ទៅឋានព្រះត្រាណត្រើយ ចាំមើលផ្លូវព្រះកជា ៗ កាលនោះពោធិសត្វ បុរសរ័តន៍ស្ដេចលីលា នឹងទៅគាល់ក្សត្រា ដូចនឹងនាងភីលៀងនោះ ៗ ឯនាងភីលៀងណា ដណ្ដឹងថាអ្នកកំឡោះ នឹងទៅឯណាហ្នោះ ឈប់ខ្ញុំនឹងសួរសិនពា៎ ៗ រីឯព្រះជៀស្ពជ័យ សងសម័យត្រាស់ទៅថា អញនឹងកាលយាត្រា អញមិនឈប់ណា៎នាងអើយ ភីលៀងលោមបរបា អ្នកកុំថាដូច្នោះឡើយ ឥឡូវនេះអ្នកអើយ មានគេ

ប្រើខ្ញុំមកណ៎ា ៗ ស្ដេចជ្រាបដូច្នោះនៃ ក្សណក្សត្រថ្វៃឈប់រោគ ក៏លៀង នោះម្នីម្នា ចូលទៅទូលព្រះជៀស្ឋជ័យ ៗ នាងថាឱ្យអ្នកអើយ ឥឡូវហើយ ក្សត្រថ្វៃ នៅប្រាសាទមាសមៃ បុត្រីព្រះបៅបញ្ចាល៍ ៗ នាងទ្រង់នោម ពិសី លើសលែងស្រីទេពសួគ៌ា នាងទ្រង់ព្រះនាមា ឈ្មោះបទុមកេសរ ៗ នាងប្រើខ្ញុំមកណ៎ា នាងធីតារតនបវរ ចង់ជ្រាបនាមករ ឈ្មោះអ្នក ឯងណ៎ាអ្នកអើយ ៗ មួយសោតក្រែងអ្នកមាន គូបុព្វណជាស្រេច ហើយ ឬមួយអ្នកគ្មានឡើយ នាងចង់ដឹងដោយទំនង ៗ ហើយសួរ ពីមាតា ទូលបិតាអ្នកឯងផង ឯឈ្មោះស្រុកនោះហោង លំនៅតើនៅឋាន ណា ៗ ក្សណៈនោះព្រះភូមី ត្រាស់ទៀងទូលថា ពីនាងនោមសោភា ឱ្យដណ្ដឹងដូច្នោះហើយ ៗ ស្ដេចគិតក្នុងព្រះទ័យ អរពេកក្រៃទើបស្ដេច ឆ្លើយ ស្នងថ្លែងថាឯងអើយ អញអរបងនាំពាក្យគ្នា ៗ ពីនាងឱ្យ មកសួរ សាកបរិបូណ៌ហើយអញបាន ដឹងពាក្យពីកល្យាណ វែងសាយ សព្វប្រការផង ៗ បងអើយឯមាតា ទូលបិតាអញនេះហោង ជាស្ដេច ស្ដែងគ្រប់គ្រង គ្រងភាពទេពបូរី ៗ ឯអង្គអញនេះណ៎ា ឥតជាយា-កដទេពី ទើបអញត្រាច់ចរលី មកស្រុកអាយណ៎ាបងអើយ ៗ អញ មកប្រយោជន៍ណ៎ា រកជាយាណ៎ាអ្នកអើយ នៅអាស្រ័យនៅឡើយ ផ្ទះព្រាហ្មណ៍ប្រាជ្ញប្រាយនោះហោង ៗ ឯឈ្មោះអញនេះណ៎ា ក្នុង ព្រះបាលីជាមួង ថាទ្រព្យប្រសើរផង វែងតែងសៀតព្រះកេសី ៗ

ឈ្មោះអញដូហ្មោះណា បងយាត្រាវិលវិនខ្ញុំ ទៅទូលនាងទេវី តាម-ប្រាជ្ញាមានគតិយល់ ។ កំលៀងសោតស្ដែងស្ដាប់ ព្រះអង្គប្រាប់ប្រការកល ជឿជាព្រះទសពល ជាស្ដេចស្ដែងប្រាកដហោង ។ អរឯងទូនសំរោ បង្គំមហាក្សត្រជាច្បង លុតលាវិលវិងស្នង ទៅប្រាសាទប្រសើរសល់ ។ ឯព្រះបាទពកជា ស្ដេចសីលាឡើងទៅដល់ កេងរ័តន៍កជមណ្ឌល គង់គាល់ព្រះចៅបញ្ចាល ។ ស្រេចហើយព្រះពោធិ-សត្វចុះពីគាល់ពកជា ទៅឋានព្រាហ្មណ៍ហោក ស្ដេចនិត្យនៅដូចសព្វ-ជង ។ ឯកំលៀងនោះណា ទៅប្រាង្គប្រាសាទនោះហោង មុំមាឡើងទៅផ្គង ក្រាបទូលនាងនាថជាយា ។ បពិត្រអ្នកអម្ចាស់ ឥឡូវនេះខ្ញុំយាត្រា ទៅជួបដូចប្រាថ្នា បាននិយាយសព្វសេចក្ដី ។ ម្ចាស់អើយអ្នកនោះណា មិនគឺជាកូនមន្ត្រី មិនគឺកូនសេដ្ឋី មិនគឺកូនព្រាហ្មណ៍ហោក ។ ព្រះអង្គជាត្រកូល ជាអម្បូរបុត្រក្សត្រា សោយរាជ្យគ្រង់កាកនគរឈ្មោះទេពបុរី ។ ព្រះអង្គឥតជាយា ប្រសើរជាអគ្គមហេសី នោះទើបព្រះភូមី ស្ដេចត្រាច់មកដល់ស្រុកកាយ ។ ស្ដែងស្ដេចអាល័យនានៅគ្រឹហាព្រាហ្មណ៍ប្រាជ្ញប្រាយ ប៉ុនប៉ងមកពីឆ្ងាយ ប្រយោជន៍រកពជទេពី ។ រីឯព្រះនាមា ស្ដេចប្រាប់ជាព្រះបាលី ជាព្រេញប្រសើរវិ-សេសវែងសៀតព្រះកេសា ។ ព្រះអង្គប្រាថ្នាមក ឲ្យនាងរកតាមប្រាជ្ញា ព្រះនាមព្រះពកជា ក្នុងព្រះបាលីឯងនៃ ។ នាងជ្រាបសព្វប្រការ

ហើយនាងនាថព្រះហឫទ័យ ត្រេកអរឯងពេកក្រៃ ទើនថ្លែងថ្វីនពុំ

បានណា ៗ នាងជឿថាព្រះអគ្គ ប្រះបីរពង្សពូជក្សត្រា ឥតបីមាន

សង្កា គុនព្រះទ័យផល់តិចឡើយ ៗ ទើបនាងទ្រង់ចិន្តា ដោះប្រស្នា

ព្រះគ្រាណត្រើយ ឃើញឈ្មោះពុំលង់ឡើយ ទើបនាងនាថបន្ទូលថា ៗ

បងអើយអញអាក្តាត់ បងឯងគិតឲ្យប្អូនក្វា បងអើយឯងប្រស្នា នោះប្អូន

ស្រាយឲ្យបងស្តាប់ ៗ ចាំទ្រព្យល្អប្រពៃ ប្រសើរក្រៃលោកនែឥតប់

នែងស្អាងនែងប្រដាប់ សៀតកេសិតស្មៀតសក់ ៗ នេះឯងទ្រព្យប្រពៃ

មានតម្លៃពុំគាក្រក់ បងអើយឯស្មៀតសក់ សោតសឹងមាសឯងហោង

ណា ៗ អស់មនុស្សសឹងហៅមាស ហៅទាំងផ្កាសសិង្ឃដូចគ្នា ថា

បើទឹងហៅថា ព្រះផ្កាលីថាសុវណ្ណ ៗ នាមអ្នកដ្ឋះប្អោះហោង គុំបី

បងគិតៈគ្នាគាន់ ស្តេចឈ្មោះព្រះសុវណ្ណ- កុមារឯងមិនខុសឡើយ ៗ នាង

នាថមានប្រាជ្ញា ដោះប្រស្នាព្រះគ្រាណត្រើយ ស្គាល់ព្រះនាមស្រេច

ហើយ នាងនែងពេញព្រះហឫទ័យ ៗ គិតលៀងសងស្រមៃ ថាមាសថ្លៃ

មានប្រាជ្ញា ដោះសាកាចប្រស្នា រំពេចពុំកម្រឡើយ ៗ ទម្ងន់ព្រះ

សុរិយា នាងពីភាគឥតឯស្បើយ នាងថាហៃបងអើយ បងជួយគិតប្អូន

ទាំបពំ ៗ គិតលៀងចិតដិតខាង ទូលហោមនាងនាថថាយា ម្ចាស់អើយ

កុំនាងបា- រម្ភគិតព្រះភៀមពេកឡើយ ៗ កំសាន្តព្រះទ័យា មានគង់

ជាសុខម្ចាស់អើយ ទុកជាខ្ញុំឯងហើយ ខំគិតគួរថ្វាយម្ចាស់ថ្លៃ ៗ ខ្ញុំ

នឹងចុះទៅដល់ ឲ្យបានយល់ព្រះចមក្រៃ អញ្ជើញអ្នកបងវ៉ៃ រួមមណ្ឌល នឹងនាងណា ។ នាងស្ដាប់ក៏លៀនទូល នាងជួបចូលព្រះទ័យា ទើប នាងបន្ទូលថា តាមតែបងឯងគិតវៃ ។ ក៏លៀនក្រញូញក្រាបលា នាង ហើយយាត្រាធាប់វៃ ទៅដល់ព្រះចមក្រៃ ថ្វាយបង្គំព្រះរាជា ។ ក្សណ នោះព្រះកុមារ យល់តាសីដល់ហើយណា ស្ដេចត្រេកសោមនស្សា បន្ទូល នូវពាក្យមេត្រី ។ បងមកឥឡូវណា នាងដីតាប្រើប្ដី ចូលបងវៃថ្ងៃ ពាក្យពី បង្គាប់នាងឲ្យរួសរាក់ ។ ក៏លៀនសោតស្ដែងស្ដាប់ ទៀនទូល ប្រាប់ព្រះរាជា ថាថ្ងៃនេះដោយប្រាជ្ញ បំណោះនាងជានិស័ន ។ ខ្ញុំម្ចាស់ មកក្រាបទូល ព្រះឥស្សរខ្ពស់ជាតិ ជាមកុដលើសិរសី ឲ្យបានជ្រាបព្រះ ទ័យា ។ ពីនាងនួនទេវី មានស្វាមីកក្តិរាជា អនុជស្ងួនពុំងា នាងក្រញូញ ក្រាបថ្វាយបង្គំ ។ មកអង្គព្រះជៀស្ដជ័យ ឲ្យក្សត្រថ្ងៃស្ដេចស្ដែងថ្ងៃ ឯកឯង កុមារម្ចាស់ សូមក្រសាលព្រះហឫទ័យ ។ ថាបើព្រះអង្គផ្ទុំ ឯកឯងពុំលក់ ឡើយនៃ ស្ដេចយកព្រះពស្ត្រថ្ងៃ ដណ្ដប់ផ្ទុំឲ្យលក់ណា ។ ស្ដែងស្ដាប់ ក៏លៀនទូល ព្រះឥស្សរសោមនស្សា ត្រិត្រូចព្រះទ័យា ហើយហាក់ យល់រំពេចពិត ។ សម្ដេចព្រះរាជា ទ្រង់ចិន្ដាថាវរមិត្រ នាងនាថព្រម ចូលចិត្ត នាងឲ្យហៅអញទៅហោង ។ ក្សណនោះព្រះរាជា បន្ទូលថា ហៃអ្នកបង បងអើយចូរនឹងផង ទៅទូលនាងនាថទេវី ។ ថាអញបង្គាប់ទៅ នាងម្ចួនពៅ ។ ពិសី អញរង់ចូលរាត្រី ហើយគញទៅជួននាងហោង ។

ក៏លៀនក្រញូក្រាបលា ព្រះអង្គមហាក្សត្រជាប្បន លីលាវិលវិញផ្គន
ដល់ប្រាសាទនាងទេវី ៗ ក៏លៀនវិតចូលខាង ក្រាបទូលនាង
នាថនារី ថាថ្ងៃអស់សេចក្តី ដូចបណ្តាំព្រះពជា ៗ នាងជ្រាប
ដូច្នោះនៃ ក្សត្រីថ្ងៃសោមទស្សា អវឯងឥតគណនា ទឹងថ្ងៃថ្មីពុំបាន
ឡើយ ៗ កាលនោះពោធិសត្វ បុរសរតន៍ក្សត្រត្រាណត្រើយ ស្តេច
ទៅថ្កានព្រាហ្មណ៍ហើយ ព្រះអង្គថ្លែងប្រាប់ព្រាហ្មណ៍ថា ៗ ហៃអ្នក
តាពុកអើយ ឥឡូវអើយថ្ងៃនេះណា ខ្ញុំទៅចាំសីលា កុំអ្នកគេអញខ្ញុំ
ឡើយ ៗ ព្រាហ្មណ៍ប្រាជ្ញសួរពៅ ថាមាសថ្លៃគាប់ចិត្តអើយ សីលសត្យ
នេះឯងហើយ ជាត្រើយត្រាណអ្នកសត្វថ្លៃ ៗ ក្សណៈនោះព្រះពជា ព្រះ
អង្គលាព្រាហ្មណ៍នោះនៃ ស្តែងស្តេចត្រាច់ដល់ព្រៃ ឈើដែលទុកយន្ត
នោះណា ៗ កាលនោះឯព្រះអង្គ ឡើងដល់ចុងដើមព្រឹក្សា គង់លើ
យន្តនោះណា ស្តេចស្រាវិឡស្រេចហើយនៃ ៗ ពត្រើពន់ពេលា កាល
ហើយណាព្រះជៀស្ដជ័យ ស្តេចកើចយន្តមាសមៃ ហោះអណ្តែតដោយ
វេហាស៍ ៗ កាលនោះឯក្សត្រី រតន៍ទេវីពជធីតា នាងនាថពុំនិទ្រា ឡើយ
នាងចាំព្រះចមត្រៃ ៗ នាងពំងឹងទ្វារប្រាសាទ ប្រសើរស្អាតខ្ជាប់ពេកក្រៃ
នាងនាថនារីថ្លៃ នាងចង់ល្បងព្រះប្រាជ្ញា ៗ ឯពន្យពោធិសត្វ បុរស
រតន៍ស្តេចលីលា ហិចហោះដោយវេហាស៍ ដល់ប្រាសាទនាងទេវី ៗ
ស្តេចចុះចាកពីយន្ត ហើយព្រះអង្គព្រះភូមី ស្តែងស្តេចត្រាច់ឡើងពិមាន .

ប្រាសាទប្រសើរសព្វ ៗ ស្ដេចយកព្រះហស្តថ្លៃ ទៅប្រាននៃទ្វារទាំង
គ្រប់ យល់រឹងតឹងសាយសព្វ សោកសឹងរាំងខ្ញាប់ក្តាំងក្តិត ៗ ស្ដេចទ្រង់ព្រះ
ចិន្តា ពិចារណាផងគន់គិត ថានៃនាងវរមិត្ត នាងចង់ធ្វើលងប្រាជ្ញា ៗ
បើដោយអញគិតទៅ គួរអញហៅនាងជាយា ស្ដេចទ្រង់ពិចារណា គន់
គំឡុងព្រះហឫទ័យ ៗ ទ្រង់ព្រះចិន្តាស្រេច ទើបស្តែងស្ដេចត្រាស់ថាហៃ
ប្អូនមាសមិត្តថ្លើមថ្លៃ បងនាំមកដល់ហើយណា ៗ ឲ្យប្អូនទៅពទក បើក
ទ្វារយកបងស្រក់ មាសអើយបងនេះណា តែម្នាក់ឯងណាប្អូនស្រី ៗ នាង
ស្ដាប់ព្រះបន្ទូល នាងអាសូរព្រះភូមី ស្រយុតអស់ឥន្ទ្រិយ រំភើបចិត្តជាប់
ស្នេហា ៗ គឺមោះនាងខំអត់ ខំសង្កត់ព្រះទ័យា បង់ដឹងព្រះប្រាជ្ញា ទើប
នាងទាចដណ្ដឹងទៅ ៗ ថាអ្នកណាស្រដី ថ្លែងថាអ្នកមកពីក្រៅ ស្ដេច
ឆ្លើយស្នេហ៍ប្អូនទៅ ថាបងឯងណាប្អូនស្រី ៗ នាងសងស្រាមែថា ខ្ញុំបុត្រ
ភ្នាបៅបុរី កើតតែឯកឥន្ទ្រិយ ឥតបងប្អូនជាពីរឡើយ ៗ ទើបស្ដេចបន្ទូល
ថា ហៃប្អូនភ្នាមាសបងអើយ កុំថាដូច្នោះឡើយ នាងស្ដាប់បងនឹងប្រាយ
ប្រាប់ ៗ អង្គប្អូនជាបុត្រ ក្សត្រពីរគ្រងស្រុកអាយ បងនេះណាប្អូន
អាយ សឹងកូនស្ដេចដែលដូចទៅ ៗ ឥតបងប្អូនឡើយណា អង្គឯកាដូច
ប្អូនពៅ ពួនាមនាងប្អូនទៅ ដល់ស្រុកបងឯនាយណា ៗ ថាប្អូនល្អពិសី
លើសលែងស្រីទេពស្នួគា តែខ្លួននាងប្អូនភ្នា អង្គឯកាដូចខ្លួនបង ៗ
ទើបបងស្មះស្វែងមក សង្ឃាតរកប្អូនឯងហោង ចិន្តាប្រាជ្ញាបង យកជា

អាឃិអគ្គមហេសី ៗ ប្អូនអើយបងទំបមា យើងនេះណាដូចអគ្គី បើ
អង្កត់ទសម្មួយនៃ ផ្ទុំកម្រទីងនេះឆាប់ ៗ ប្អូនអើយបើយើងយក ទស
ពីរមកផ្គុំផ្គួបផ្គាប់ ជាពីរផ្ទុំនេះឆាប់ រំពេចពុំកម្រឡើយ ៗ ដូចគលអគ្គប្អូន
ស្រី ខ្ទួនបងក្តីណាប្អូនអើយ ប្បប្អូនកុំព្រងើយ កុំគោះតើយណាមាស
ពៅ ៗ ថាបើប្អូនស្រីស្រួល នាងទទួលយកបងទៅ ជាពីរនាក់ទីងបៅ
សើខ្លួនមួយទីងប្អូនស្រី ៗ មាសអើយគោះបីបើ គិតសារពើការផងក្តី
បងភ្លេចមានប្អូនស្រី បើប្អូនភ្លេចមាសមានបង ៗ ទើបនាងសងស្រមៃ
ថាគាប់ចៃព្រះអគ្គហោង ជួយគិតឲ្យប្អូនផង ខ្ញុំមិនឆ្លាបេដោយកជា ៗ
អញ្ចើញព្រះអគ្គស្តេច យាត្រាត្រាច់ទៅមុខា វិលវិញបានសីមា ស្រុក
ព្រះអង្គឯណាយនៃ ៗ ស្តេចឆ្លើយស្នងប្អូនពៅ បងមិនទៅឡើយមាសថ្ងៃ
បងទីងនៅនេះនៃ ចាំយកប្អូនឯងឲ្យបាន ៗ ថាបើនាងប្អូនគន់ ស្ងួន
ទីងខ្ញុំមាសមិនក្រាន្ត បងឲ្យបងវិលបាន គ្រឡប់ទៅស្រុកនាយណា ៗ
ប្អូនមាសត្រូវការ មកៈបីកទ្វារចាប់សែរ៉ា បងអ្នកទីងយាត្រា ទៅ
ឲ្យបានយល់មុខពៅ ៗ សោះតែឥតក្តក្នុក ដល់ថ្ងៃស្អែកបងទីងទៅ
កុំឲ្យព្រួយចិត្តបៅ តែងចំណេញចំបរបង ៗ នាងសងស្រមៃថា
ខ្ញុំក្រណាតែងផ្តោះផ្តង ជន្មជន្មញលង ហាក់ដូចខ្ញុំសហាយស្មន់ ៗ
ពុំគោតពុំគិតខ្វាច យល់អំណាចណាស់ពេកពន់ ហាក់ហានក្តុំគួនលន់
ពុំគិតខ្លួនក្រែងក្រៃ ៗ ទើបព្រះអគ្គផ្ទាស់ឆ្លើយ ថាមាសអើយបងនេះនៃ

ពុំគិតពុំគាល័យ ពុំខ្លាចខ្លួនស្លាប់ឡើយណា ៗ យ៉ាងតែប្អូនព្រលឹង ឲ្យ បានខឹងចិត្តចិន្ដា បើបានដូចប្រាថ្នា នោះប្រសើរនាលោកិយ ៗ ខ្លួនបង ដូចមមាច ពុំគិតខ្លាចនូវអគ្គី ឃើញភ្លើងហើរចូលខ្ញី ដូចបងឃើញប្អូន ស្នេហា ៗ ម៉្លេះហើយបងទឹងនៅ ចាំយកពៅស្ងួនពុំផា ឲ្យបានដូច ប្រាថ្នា បងមិនមានស្តាយជីវី ៗ ស៊ូស្លាប់ក្លូវបានខ្នាត លើប្រាសាទ នាងប្អូនស្រី ទឹងរស់នៅធ្វើអ្វី បើប្អូនពៅពុំព្រមផង ៗ ស៊ូរស្លាប់ ពេញជាប្រុស ទុកជារស់កាលនេះម្តង ខ្មាសប្អូនបញ្ឆោតបង ឲ្យមក ដល់ហើយប្រែវិញ ៗ គេជះបង់បានសាង សូមទឹងនាងពីមុនមិញ ផកកិរិយាសំឡាញ់ ពីបុកណាមែនពិតណា ៗ សូមឲ្យទ្វារប្រាសាទ របើកស្អាតចាកចេញក៏ ប្រាកដដូចសច្ចា— អធិដ្ឋានកាលនេះវៃ ៗ ឯនាង នាថទងវង បន្ទូលផ្សងដូចក្សត្រថ្លៃ ហេតុបុណ្យព្រះចមត្រៃ ទឹងនាង នាថពីមុនមិញ ៗ មកជ្រោមជួយព្រះបាទ ទ្វារប្រាសាទរបើកចេញ នាងនាថវង់គោរពេញ ចិត្តះស្ញើជាបារមីមាន ៗ ក្សណនោះព្រះរាជា ស្ដេចលីលាចរចូលឋាន ទៀបនាងនាថកល្យាណ ទើបនាងយល់ព្រះ រាជា ៗ នាងខ្មាសនាងអៀនអាក់ វិប្រព្រះភក្ត្រនាងចេញណា នាង យកព្រះពស្ត្រា មកទទូរហើយនាងផ្ទុំ ៗ ទៀនយាមភ្លឺព្រោងព្រោត ក្នុងប្រាសាទប្រសើរសម នារីរតនឧត្តម នាងទ្រោលក់សេយ្យាសន៍ ៗ ក្សណនោះព្រះរាជា ស្ដេចលីលាដើរយាងយាស ទៅដល់គ្រែទងមាស

ចិត្តបន្ទំនាងនិមិល ។ ស្តេចបើកភ័ងនទណា ព្រះពជាទតទៅយល់ នាងផ្តុលក់សុំខសល់ ពុំកម្រើកព្រះអង្គ ។ ស្ដែងស្ដេចចិតបូលដិត ព្រះអង្គបិតវាងនាងណា ព្រះទុស្សថ្លៃបរិចា ថាថ្លៃងនូវពាក្យមេត្រី ។ ថាហៃប្អូនព្រលឹង មានបើទឹងអាក់អន់អ្វី ប្អូនមាសមិនស្រដី មកទឹងបងដល់តិចឡើយ ។ បុម្ញយប្អូនអផ្សុក បុផ្តុំលក់ណាទាំងអើយ បងមកដល់នេះហើយ ម្តេចប្អូនមាសមិនទាំពា ។ ស្ដេចលើកនូវព្រះពស្ត្រ ពីស្រស់ស្រស់អង្គនាងណា ឯនាងនាថផ្ទើជា ពុំរញ្ជកព្រះស្មារតី ។ ស្ដេចទតសព្វសព្វាង្គ រូបនៃនាងនាថនារី សម្ដេចព្រះភូមី សព្វព្រះទ័យមិននាងណាស់ ។ ស្ដេចទ្រង់ព្រះចិន្តា គិតឯងថាបើអញជាស់ នាងរព្ញកឡើងច្បាស់ ពុំបានគន់សព្វឥន្ទ្រិយ ។ ទើបព្រះអង្គពណ៌នា អស់អង្គព្រះប្អូនស្រី ព្រះទុស្សថ្លៃប្រិមប្រិយ ថ្លៃងសរសើរព្រះប្អូនភ្ញា ។ ឥឡូវបងមកដល់ ចង់បានឃល់ប្អូនពុំងា ចង់មានចិត្តស្នេហា ប្អូនពិសីយាំងក្រៃលែង ។

បទ ទ ភា ភា.កតិ

នេះបទកាកគតិ - ត្រិទើបបរោ និទានបាយថៃង ដំណើរអិពី ពោធិជាក់ស្ដែង បើកព្រះទុស្សថ្លៃង សរសើរស្ងួនភ្ញា ។ រៀមរិះគិតគន់ អស់អង្គប្អូនគន់ ស្ងួនស្ដិ៍សមសោភា បង់គន់គិតពី កេសីប្អូនភ្ញា ដូចស្វាបកមកខ្មៅឆ្មារដុំកផិត ។ រៀមរក្សស្នេហា គន់ព្រះសិរសា នួនមាសមៃមិត្ត ហាក់ដូចពពិល ស្រស់ស្រិលពិចិត្រ មាសផ្អិទខ្ទឹមខាត់ ក្រោងព្រាយស្មើ ។

ភមោប្អូនគន់ ទ្រទេសទ្រទន់ ទ្រលន់ស្រស់ស្រី បង្គួយកៅទណ្ឌ សុវណ្ណមណី ស្រស់ស្រេចឥតបី គ្មានគួរឡើយណា ៗ បងគន់ព្រះស្រួល ក្រពុំមាត់មូល ស្ងួនសមនេត្រា ព្រះឧស្ឋស្រស់ស្រី ប្រិម-ប្រិយដិតស្មា ថ្ពាល់ដូចផលា មាក់ប្រាំងមាសមៃ ៗ ព្រះភក្ត្រប្អូនស្រី ដូចចន្ទបូណ៌មី ថែងចាំងឯព្ធ មណ្ឌលអាកាស វេហាសនាយនៃ ក្ដីទូចាំងផ្ទៃ ក្រោមក្រែកាក ៗ បងគន់សូរង អូលម៉ដ្ឋឥតគ្គង ស្ងួនសមសោភា ផ្ចត់បីដាន់ដុំ ក្លៀវក្លៃថ្ងថ្លា សមព្រះភក្ត្រា ស្រេចស្រស់ប្រពៃ ៗ ឯអង្គស្នាគាង គាងគួសមពង់ ពងរៀវល្មមល្មៃ ចង្កេះក្លៀវក្លុំ ស្ងួនសមណាស់ទៃ អស់អង្គប្អូនថ្លៃ ស្រស់ស្រេចសោភា ៗ ចាំងសងសុដន់ ដោះនាងប្អូនគន់ បងទឹងទបមា ដូចផ្លែទន្លាប់ មាសផ្កាប់នៅនា ទ្រូងទ្រង់ទុក នូននាងប្អូនស្រី ៗ ប្អូនល្អឥតគ្គង ត្រូវទឹងក្នុកចង គ្រប់បញ្ចស្ត្រីយ មានតែប្អូនហោង គន្ធវែងស្រី ទូទាំងលោកិយ ជម្ពូទ្វីបណា ៗ សម្ដេចភូមី សរសើរប្អូនស្រី នូវពាក្យស្នេហា សព្វសពាង្គស្រេច សម្ដេចពងា យកព្រះហស្ដា ស្ដេចស្ទាបព្រះភក្ត្រ ៗ រួបដល់សុដន់ ទើបព្រះប្អូនគន់ នាងធ្វើជាភ្ញាក់ ស្ទើរយល់សព្វសាយ ពយមាយពុំផាក់ ប្រែប្រាណហើយអ្នក នាងផ្ទុំទៀតទៅ ៗ ស្ដេចយល់ប្អូនមាស ផ្ទំលក់សេយ្យាសន៍ ទើបព្រះចមចៅចើបថៃព្រះភក្ត្រ ថ្ពាល់អ្នកប្អូនពៅ ថ្នមដាក់លើភ្លៅ ឥន្ទ្រលក ៗ (មានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## បរិយាយពីវត្ថុជាគ្រឿងតំណាង

លោក ស្រី-អ៊ូ រៀបរៀង

បុព្វបុរសរបស់ខ្មែរពីព្រេងនាយ ធ្វើការអ្វីមួយ ៗ ច្រើនតែធ្វើប្រារព្ធដល់ហេតុដើម ឬធ្វើតំណាងរបស់ដើម ដូចយ៉ាងខ្មែរបុរាណធ្វើគ្រឹះស្ថានសម្រាប់នៅ គឺផ្ទះសម្បែង ព្រះវិហារ កុដិ សាលាជាដើម ច្រើនតែធ្វើបែរមុខទៅទិសខាងកើត ពុំសូវធ្វើបែរមុខទៅទិសខាងលិចទេ ។ គេគូរឬឆ្លាក់ក្បាច់ជាផ្កាឈូក ៥ ផ្កាឈូក ៤ រីក ផ្កាមួយក្រពុំជាដើម ៗ កិច្ចការទាំងនេះបញ្ជាក់ឲ្យឃើញថាទំនៀមខ្មែរបុរាណធ្វើអ្វីនីមួយ ៗ គេមិនមែនធ្វើយកតែលំអមួយមុខទេ គេធ្វើឲ្យល្អផង ធ្វើប្រារព្ធដល់ហេតុដើម ឬធ្វើជាតំណាងរបស់ដើមផង ដែលធ្លាប់មានពីបុរាណព្រេងនាយមក ហើយធ្វើនោះទៀត មិនមែនជាទំនៀមខេមរជនភាគតិចទេ គឺជាទំនៀមសាកលរបស់ខេមរជន ហើយហាក់ដូចជាប្រស្នា ទុកឲ្យកូនចៅជាន់ក្រោយត្រិះរិះដោះស្រាយដោយវិចារណញ្ញាណចុះ ។

ពេលនេះ ខ្ញុំសូមដោះស្រាយ តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរនៅពុទ្ធសាសនបណ្ឌិត្យ មានសេចក្ដីដូចតទៅនេះ ៖

– គេធ្វើគ្រឹះស្ថានផងទាំងពួង បែរមុខទៅទិសខាងកើត ជាការសំដែងនូវសេចក្ដីគោរពចំពោះព្រះអាទិត្យ ព្រោះលទ្ធិខ្មែរបុរាណព្រេងនាយ

គេយល់ថា ព្រះអាទិត្យជាទេវបុត្រមួយអង្គ ជាបុត្រអាទិតិ ឈ្មោះអាទិត្យ ឬសុរិយាទិត្យ ជាទេវបុត្របំភ្លឺលោកឲ្យភ្លឺត្រចះ គេយកព្រះអាទិត្យទើបនឹងរះមកពីទិសបូព៌ាជាទីគោរព ជាសិរីមង្គលសួស្តី បានជាគេធ្វើគ្រឹះស្ថានផងតាំងពួង ឈមមុខទៅទិសបូព៌ា សូម្បីគេផ្សំផ្គុំកូនប្រុសស្រីឲ្យមានគូស្រករបង់មានមង្គលសួស្តី ក៏គេយកពេលព្រះអាទិត្យទើបនឹងរះជាមង្គលសួស្តី បានជាគេឲ្យកូនប្រុសក្រាបសំពះព្រះអាទិត្យ ទើបនឹងរះពាដង ហើយពាក្យនោះជាសញ្ញាថា ពេលបានហើយ ទើបគេហៅកូនប្រុសឡើងទៅធ្មឹម ។

— គេតំកល់ព្រះពុទ្ធរូបក្នុងព្រះវិហារនានា បែរព្រះភក្ត្រទៅទិសខាងកើត ជាតំណាងកាលព្រះបរមគ្រូមុនបានត្រាស់ ទ្រង់គង់ខាងកើតគល់ពោធិព្រឹក្ស បែរព្រះភក្ត្រឆ្ពោះទៅកាន់ទិសបូព៌ា ។

— គេសាងព្រះពុទ្ធរូប ទ្រង់ពែនព្រះភ្នែនតម្រួតព្រះហស្តស្តាំលើព្រះហស្តឆ្វេង ជាតំណាងកាលព្រះអង្គទ្រង់កំពុងផ្គត់សមាធិ ។

— គេសាងព្រះពុទ្ធរូប ទ្រង់ប្រតិស្ឋានលើផ្កាឈូករីក ជាតំណាងកាលព្រះអង្គបានសម្រេចពោធិញ្ញាណ រីកជាព្រះពុទ្ធពេញទី ដូចផ្កាឈូករីកហើយដូច្នោះ ។

— គេសាងព្រះពុទ្ធរូបអំពីប្រាក់ក្តី មាសក្តី ស៊ីម៉ង់ត៍ឬថ្មក្តី មានភាពជារូបនាគកជមួយ ពែនព័ទ្ធៈថែតពពារគ្របប្រក់ពីលើព្រះអង្គ ហៅថាព្រះពុទ្ធរូបនាគប្រក់ ជាតំណាង កាលព្រះសក្យមុនីបានត្រាស់អស់

រយៈ ៣៥ ថ្ងៃរួចហើយ មាននាគរាជមួយឈ្មោះមុចលិន្ទ មកបើកពពារគ្របប្រក់ពីលើព្រះអង្គ ដើម្បីការពារកំដៅថ្ងៃនិងខ្យល់ជាដើម ជាការគោរពចំពោះព្រះសម្ពុទ្ធពេញ ៧ ថ្ងៃ ។ សូម្បីគេធ្វើព្រះវិហារតំកល់ព្រះពុទ្ធរូប ក៏មានដាក់រូបនាគនៅដំបូលព្រះវិហារ ដែលហៅថា ជហ្វាជងក្តារ ។

– ជហ្វាជាកន្ទុយនាគ ដែលគេដាក់ភ្ជាប់នៅចុងមេដំបូល , ជងក្តារជាតួខ្លួននាគ គេដាក់ភ្ជាប់ពីគល់ជហ្វាមក សណ្តូកខ្លួនមានក្បាលចេញមកខាង ។ ដែលគេធ្វើដូច្នោះ ជាតំណាងកាលមុចលិន្ទនាគរាជមកសំដែងការគោរពចំពោះព្រះបរមគ្រូអស់ ៧ ថ្ងៃនោះដែរ ។

ចុះគេដាក់រូបគ្រុឌ ក្រោមសំយាបគ្រប់ជ្រុងថែងទាំងអស់ តើជាតំណាងអ្វីដែរ ?

– គេដាក់រូបគ្រុឌត្រង់ថែងខាងក្រោមនោះ ជាតំណាង កាលគ្រុឌច្បាំងគ្នានឹងនាគ ។

ចុះគេដាក់កណ្តឹងនៅដំបូលព្រះវិហារជាតំណាងអ្វីដែរ ?

– គេដាក់កណ្តឹងនៅដំបូលព្រះវិហារ ជាគ្រឿងពុទ្ធបូជាតំណាងដូរ្យតន្ត្រី ដែលទេវបុត្រប្រគំថ្វាយចំពោះព្រះសម្ពុទ្ធ ព្រោះកណ្តឹងនេះកាលត្រូវខ្យល់បក់មកលាន់ឮសូររងំ ហាក់ដូចជាគេប្រគំថ្វាយព្រះពុទ្ធរូបនៅក្នុងព្រះវិហារនោះ ។

– គេគូរឬឆ្លាក់ក្បាច់ជាផ្កាឈូក ៥ ជាតំណាងព្រះសម្ពុទ្ធ ៥ ព្រះអង្គ

គឺ ព្រះកកុសន្ធោ កោនាគមនោ កស្សបោ គោតមោ អរិយមេត្តេយ្យោ ។

- គេគួរធ្វើផ្កាជាផ្កាឈូក ៤ រីក ជាប្រស្នាថា ព្រះពុទ្ធ ៤ ព្រះអង្គបាន ត្រាស់ហើយ ដូចផ្កាឈូករីកហើយដែរ ផ្កាឈូកមួយនៅក្រពុំ ជាប្រស្នាថា ព្រះពុទ្ធមួយព្រះអង្គទៀត ពុំទាន់បានត្រាស់ដឹងនៅឡើយ ។

បុព្វបុរសជាន់ដើម មានការពិសោធន៍ដ៏ជ្រាលជ្រៅ ដែលនឹងធ្វើម ធ្វើរបស់អ្វីនិមួយៗ ឡើង ច្រើនតែធ្វើប្រារព្ធដល់ហេតុដើម ហើយហាក់ ដូចជាប្រស្នាធុន សូម្បីតែពាក្យនិយាយប្តីសុភាសិតផ្សេងៗ ក៏ហាក់ដូចជា ប្រស្នាដែរ តែប្រស្នានោះងាយដោះស្រាយ ហើយបានសេចក្តីទូលំ ទូលាយពន់ពេក ដូចសុភាសិតមានដើមថា :

ប្រើត្រាប់កុកសាប់ កុំបីត្រាប់កុកស
ប្រើត្រាប់ឫស្សីស្រល កុំបីត្រាប់ស្វាយកន្ទ្រាញ ។

ពាក្យថា "ប្រើត្រាប់កុកសាប់" គឺឲ្យយកគម្រាប់លំនាំតាម កុកសាប់ ព្រោះកុកសាប់ ជាសត្វមានពេមសនៅខាងក្នុង មានពេមប្រផេះ ផុះគ្របនៅពីលើ កាលបើទទះស្លាបហើរឡើង ទើបឃើញពណ៌ស សំពោងនេះយ៉ាងណា មនុស្សយើងបើមានចំណេះច្រើនយ៉ាង គេប្រើ ឫកពារម្យ៉ាំ មិនបញ្ចេញឫកលលោលលាំ គេធ្វើហាក់ដូចជាមនុស្ស សាមញ្ញ កាលបើមានគេចោទអាថ៌ប្រស្នាអ្វីមក ទើបបានបញ្ចេញឫទ្ធិ

អានុភាពតម្រិះប្រាជ្ញាកណ្ដាលប្រជុំជនយ៉ាងស៊ប់ស្ងៀន ដូចកុកសាប់ទទះស្លាបឡើងសសំពោងដូច្នោះ ៗ

ពាក្យថា « កុំបីត្រាប់កុកស » គឺកុំឲ្យយកតម្រាប់តាមលំនាំកុកស ព្រោះកុកសទំនៅស្ងៀម ក៏សសំពោង ទទះស្លាបហើរឡើង ក៏នៅតែសដដែល បានដល់មនុស្សខ្លះមិនមានវិជ្ជាអ្វីមាំមួននៅក្នុងខ្លួនសោះ តែធ្វើឫកពាហាក់ដូចជាគ្រាន់បើណាស់ តែបើមានគេសួរប្រស្នាអ្វីមួយ ក៏ទញ់ទាល់ពុំអាចហើបមាត់ឆ្លើយបានឡើយ ៗ

ពាក្យថា "ប្រើត្រាប់ឫស្សីល" គឺឲ្យយកតាមលំនាំឫស្សីដែលលំទាំងគុម្ពុះក្នុងប្រាំងទន្លេ ទឹកជន់មកលិចអស់នៅសល់តែមួយដើម លិចត្រឹបភ្លុត ៗ ដល់តាមទៅឃើញច្រើន ដូចមនុស្សចំពូកខ្លះ មើលទៅដូចជាមិនចេះអ្វីប៉ុន្មាន ដល់សួរដេញដោលទៅ ស្រាប់តែឃើញចំណេះវិជ្ជាច្រើន ៗ

ពាក្យថា « កុំត្រាប់ស្វាយកន្ទ្រាញ » គឺកុំឲ្យយកតាមលំនាំដើមស្វាយអណ្ដែតទឹក ដែលមានតែសំណុំមែកសាងញ៉ាង ហើយមានតែដើមតូចមួយ ដូចមនុស្សចំពូកខ្លះ គេក្រឡេកមើលទៅដូចជាមានចំណេះវិជ្ជាខ្លាំងពូកែណាស់ ដល់គេល្បងមើល ឥតបានការសោះដូច្នោះ ៗ

# រឿងសាមកុក

## កណ្ឌទី ៣៦

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តទៅ)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជការឆ្លាស បើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ពីបុរាណ ចាត់តែងយកតាមអំពើចិត្តឯងដូច្នេះ ឯងនឹងធ្វើឲ្យផែនដីស្រុកកេងជីវ នឹងគាណាខេត្តដែលជាចំណុះវិនាសអន្តរាយនៅក្នុងកណ្ដាប់ដៃអ្នកដទៃឬ ? ឯងខំចិត្តនឹងអ្នកដែលមានវាសនា ហើយស្លាប់ទៅនោះ មិនវិលមកកាប់កឯងឲ្យស្លាប់តាមទៅឬ ? ៗ ឈួម៉ីបានឮដូច្នោះខឹងណាស់ ទើបបង្គាប់ឲ្យទាហានចាប់ខ្លួនលីគុយទៅសម្លាប់ចេញ ៗ លីគុយក៏ស្រែកជេរឈួម៉ីមិនដាច់ពាក្យមួយមាត់សោះ ទាល់តែទាហានកាប់ដាច់កស្លាប់ ៗ

កាលឈួម៉ី តាំងខ្លួនឡើងជាចៅហ្វាយស្រុកកេងជីវ ជំនួសឡៅប៉ៀវនោះ ក៏ចាត់តែងស្នំគ្រប់ក្លួក ដែលជាសេដាមួយគ្នានោះ ឲ្យ

លើករេហ៍ពលសកលយោធាចេញទៅក្រៅគ្រប់ដំបន់ ក្នុងស្រុកកេនជ័រ តាំងមូល ហើយឲ្យទៀនយីទឹងឡៅសៀន ដែលជានាម៉ឺនធំនៅក្រៅស្រុកកេនជ័រ ឈ្លួមក៏នាំនាងឈ្លួហ៊ួយយិនទឹងឡៅចង នូវអស់នាម៉ឺនទាំងពួង ទៅតាំងទីក្រុងនៅស្រុកស៊ុងយ៉ុង ប្រាជ្ញាទឹងបានគស៊ូទឹងឡៅពន្ធូរឡៅគីវ

ខណៈនោះ មានបំរើសេះមកប្រាប់ថា ឥឡូវចូចូលើកទ័ពធំចេញពីស្រុកហ៊ូតោទឹងធ្ងង់មកតាមផ្លូវត្រូវលើស្រុកស៊ុនយ៉ុងនេះ ។ ឡៅចងបានឮដូច្នោះ ក៏ភ័យណាស់ ទើបប្រឹក្សាទឹងឈ្លួម៉ទឹងកេនអួតថា ឥឡូវចូចូលើកកងទ័ពមកហើយ អ្នកពល់គ្នាទឹងជួយរិះគិតការពារប្រការម្ដេច? ។ ហ៊ួស្ងួនឆ្លើយថា នេះដោយសារចូចូលើកទ័ពមក លោកក៏បានជំនឿទូនទាន់ទីងការពារអន្តរាយ បើប្រសិនជាចូចូមិនលើកទ័ពមកទេ គង់តែឡៅពីទឹងឡៅគីលើកទ័ពមកជាប្រាកដ ព្រោះយើងធ្វើការលើសតាមអំពើចិត្ត មិនបានប្រាប់ឲ្យឡៅពីទឹងឡៅគីដឹងផង បើសិនណាឡៅពីឡៅគីមានសេចក្ដីតូចចិត្ត ក៏ទំនងលើកកងទ័ពមកវាយខ្ញុំពីម្ខាង មុខជាលោកទឹងបានសេចក្ដីអន្តរាយ កលឧបាយរបស់ខ្ញុំ គិតឃើញមួយយ៉ាង បើលោកធ្វើតាម បណ្ដាអ្នកស្រុកក៏មិនមានទុក្ខក្ដៅក្រហាយ ទាំងខ្ញុំនិងលោកសោត ក៏បានសេចក្ដីសប្បាយ គ្រប់គ្រងស្រុកក៏មិនមានទុក្ខក្ដៅក្រហាយ ។

ឡៅចងសួរថា កលឧបាយរបស់អ្នកទឹងធ្វើប្រការម្ដេច ? ។ ហ៊ួ

ស្ងួនឆ្លើយថា សូមឲ្យលោកលើកស្រុកកេងដីវ ទីនិងអាណាខេត្តឯកទាំង៩ ឲ្យទៅប្អូនបុះ មុខជាប្អូននឹងមានសេចក្ដីត្រេកអរ ទីនិងជប់លៀងក្បាលោក ឲ្យបានសេចក្ដីសុខរីករាយ ។ ទៀវចន៍ឮដូច្នោះ ក៏ខឹងណាស់ ស្រែកគំហកឲ្យហ៊ីស្នួនថា បិតាខ្ញុំទើបតែនឹងអនិច្ចកម្មទៅថ្មី ៗ ឥឡូវខ្ញុំបានគ្រងស្រុកជំនួសមិនទាន់បានប៉ុន្មានថ្ងៃផង លោកមកនាំពាក្យឲ្យលើកស្រុកឲ្យទៅប្អូនទេ នោះព្រោះហេតុអ្វី ? ។ កេងអួត ឆ្លើយតបទៅទៀវចន៍ថា ដែលហ៊ីស្នួននិយាយនោះត្រូវណាស់ ព្រោះកើតមកជាមនុស្ស ត្រូវតែពិគ្រោះឲ្យដឹងការធ្ងន់ការស្រាលទើបគួរ ដូចសព្វថ្ងៃនេះ ប្អូនបានជាមហាឧបរាជ មានរឹទ្ធិអំណាចនឹងធ្វើការក្បួយកព្រះជម្រាសព្រះចៅហៀនគេជាប្រមាណ ស្ងួនប្រាប់ប្រាមបានស្រុកទេសជាចំណុះច្រើនណាស់មកហើយ ឥឡូវទើបនឹងបានតាំងខ្លួនឡើងជាធំ សូម្បីតែការខាងក្នុងបងប្អូនរបស់លោក ក៏នៅមិនទាន់ជាប្រក្រតីនឹងគ្នាសោះ ដែលនឹងរៀគិតធ្វើសឹកសង្គ្រាមខាងក្រៅ ក៏ឃើញថាជាទម្ងន់ណាស់ទៅហើយ បើប្អូនលើកទ័ពមកដល់ហើយ មុខជាបណ្ដាពស្ត្រីទាំងពួងនឹងកោតខ្លាចបបួលគ្នាគេទៅចូលនឹងប្អូនទាំងអស់ ឃើញថាលោកនឹងតស៊ូម្ដេចបាន ! ។

ទៀវចន៍បានស្ដាប់ហើយតបថា ដែលលោកនិយាយនេះត្រូវហើយ តែជាបិតាខ្ញុំ ប្រគល់ស្រុកទុកឲ្យមិនទាន់បានប៉ុន្មានថ្ងៃ នឹងលើកទៅឲ្យអ្នកដទៃទៀតនោះ ក៏ឃើញដូចជាក្បាក្ដីមរតកមាតាបិតាមិនបាន

នាងមិនជាចិត្តរហោទិន្នាដល់ហើយឬ ? ៗ អង្គភានដែលដាក់ទីប្រឹក្សា ក៏ឆ្លើយទៅទៀបថា ដែលហ៊ីសួននាងកេងអួតនិយាយនោះត្រូវណាស់ ហេតុម្តេចបានជាលោកមិនយល់ព្រមធ្វើតាម លោកប្រមាណចិត្តរបស់លោកឃើញថា គស៊ីនាងបួនបានឬ ? ឥឡូវបួនក៏មានទីប្រឹក្សានាងសេនាទាហានមានចំនួនច្រើនណាស់ ស៊ូប៊ៀតែលីប៉ោ អួនសៀវ នាងអ៊ួនស៊ុត ដែលមានសតិប្រាជ្ញាទិនឆក់ឡាំងគ្រាន់បើ ម្តេចបួនច្បាំងចាល់តែអន្តរាយកំចាត់ចេញអស់ រលោះនេះរីតតែមានចិត្តកំរើកឡើងទៀត ឥឡូវបួនលើកទ័ពមកកំចាត់អាណាខេត្តខាងទិសទក្សិណ ដែលលោកនាងរិះគិតច្បាំងគស៊ីមិនបានចំណុះចុះចូលបួននោះ យូរទៅលោកនាងដឹងច្បាស់ប្រាកដព្រោះលោកមិនបានស្ដាប់ទីប្រឹក្សាទាំងពួង ៗ ឡៀបនិតបថាដែលលោកនិយាយគឿនរំពុកស្មារតីខ្ញុំនោះត្រូវណាស់ហើយ តែខ្ញុំនាងសូមនាំសេចក្ដីយល់របស់អស់លោកទៅពាក្រោះទិនមាតាខ្ញុំសិន ៗ

ខណៈនោះ ទទួលនាងឈ្មោះហ៊ុយមិនដើរចេញមកពីខាងក្នុង បាទព្យ ហើយក៏សួរទៀបថា អ្នកទាំងពេប្រឹក្សាគ្នាឃើញត្រូវគ្នាហើយឬ ? បានជានិយាយដូច្នេះ ចៅមិនបាច់នាំយកសេចក្តីនោះមកពាក្រោះទិនម៉ែធ្វើអ្វីទៀតទេ ចូរប្រព្រឹត្តទៅតាមអធ្យាស្រ័យនៃអ្នកកល់គ្នាចុះ ៗ ឡៀបថ៍ព្យមាតាថាដូច្នោះ ក៏ត្រេកអរ ទើបសរសេរសំបុត្រសូមចំណុះបួន ១ ច្បាប់ស្រេចហើយក៏ប្រើសុនតុនកាន់ទៅឲ្យបួន ទទួលជួបនាងបួនលើកទ័ពមកដល់ដែនស្រុកអ៊ួនសៀវ សុនតុនក៏ជូនសំបុត្រទៅឲ្យបួន ៗ ទទួល

មើលដឹងសេចក្តីក៏មានអំណរណាស់ ទើបឲ្យបំណាច់រង្វាន់ដល់សុងគុងតាមសមគួរ ហើយផ្តាំថា បើអ្នកឯងត្រឡប់ទៅវិញ ឲ្យប្រាប់ឡៅចងចុះថា ដែលមានសំបុត្រមកនោះ យើងបានទទួលព្រមហើយ ត្រូវឲ្យឡៅចងចេញមកតំនាប់យើងតាមប្រវេណី យើងនឹងជួយទំនុកបំរុងឲ្យបានសេចក្តីសុខតទៅ ។ សុងគុងទទួលបណ្តាំហើយ ក៏លាចូលចេញទៅ លុះទៅដល់ទន្លេទីងឆ្វង់ ក៏ប្រទះនឹងពួកតាហានគួនអ៊ូ ក៏ចាប់ខ្លួនសុងគុងបានទើបសួរថា គង់ធុរកិច្ចការស្រុកកេងជីវនោះ ជាប្រការម្តេច ? ។ សុងគុងក៏ធ្វើអឹមអៀមមិនស្តី លុះគួនអ៊ូបង្ខំសួរខ្លាំង ឃើញថាលាក់មិនបានក៏ប្រាប់ដោយពិតថា ឥឡូវឡៅបៀវដល់នូវសេចក្តីស្លាប់ហើយ ឯស្រុកទេសតាំងពួង នាងឈួហ៊ូយិន ទីងឈួម៉ាវៈគិតគ្នានឹងឡៅចងលើកទៅឲ្យចូចតាំងអស់ហើយ ។ គួនអ៊ូឮដូច្នោះក៏តក់ស្លុតស្មារតី ទើបនាំខ្លួនសុងគុងទៅស្រុកសិនអៀ ហើយអធិប្បាយជំពប់ឡៅពី តាមពាក្យសុងគុងគ្រប់ប្រការ ។

ឡៅពីដឹងថាឡៅបៀវស្លាប់ដូច្នោះ ក៏យំសោកាល័យពាល់តែដួលសន្លប់ ។ លុះឡៅពីភ្ញាក់ដឹងខ្លួនឡើង ទៀវហ៊ុយក៏និយាយថា លោកនឹងមកទោមនស្សដូច្នេះមិនគួរទេ សុំឲ្យយកសុងគុងទៅសម្លាប់ចេញទើបត្រូវ រួចសឹមលើកទ័ពទៅវាយយកស្រុកស៊ីយ៉ុង សម្លាប់ឡៅចងនឹងឈួម៉ឲ្យបាន ទើបធ្វើការសង្គ្រាមតទៅមុខទៀត ។ ឡៅពីក៏យំតថា

ខ្ញុំឯងនៅក្នុងសេចក្ដីណាស់ ទឹងបេះដូងជានិចតាស់មិនគួរទេ ចូរបិទមាត់ កុំអាលនិយាយសិន ឯកិច្ចការទាំងអម្បាលនេះ បងក៏បានត្រិះរិះអស់ ហើយ រួចឡើងពីកំសួរសុងតុងថា ខ្ញុំអ្នកឯងក៏មានដម្រេះប្រាជ្ញាដែរ បើអ្នកឯទៀតគិតមិនត្រូវ ហេតុម្ដេចមិនយកសេចក្ដីនោះមកប្រាប់ឲ្យយើងដឹងសិន បើយើងទឹងសម្លាប់ខ្ញុំនឹងឥឡូវនេះ ក្របុំយើងក៏ប្រឡាក់ឈាមទទេឥតប្រយោជន៍ ចូរអ្នកឯងស្រួតរូតទៅស្រុកសុងយ៉ុងឲ្យឆាប់ ហើយប្រាប់ថា យើងចាប់បានខ្ញុំលៃងមកវិញ ៗ សុងតុងមានសេចក្ដីត្រេកអរណាស់ គំនាប់ឡើងពីហើយក៏លាចេញទៅ ៗ

ខណៈនោះ នាយទ្វារបាលចូលមកប្រាប់ឡើងពីថា ឥឡូវឡើងគីប្រើអ៊ីបៀមកគំនាប់លោក ៗ ឡើងពីឮដូច្នោះ ក៏ត្រេកអរណាស់ គិតដល់គុណអ៊ីបៀ ដែលបានប្រាប់ហេតុផលមកពីថ្ងៃមុននោះ ក៏ចេញទៅទទួលដល់ក្រៅទ្វារនាំចូលមកខាងក្នុង អ៊ីបៀគំនាប់ឡើងពីហើយជំរាបថា ឥឡូវឡើងគីប្រើខ្ញុំបាទមកជំរាបលោក ព្រោះឡើងបៀវជាបិតាទទួលអនិច្ចកម្មទៅហើយ នាងឈ្លួហ៊ួយនិងទឹងឈ្លួម៉ គិតគំនិតត្រូវគ្នាបិទបាំងសេចក្ដីនេះទុកមិនបានជំរាបមកលោកឲ្យជ្រាប ឥឡូវប្រាប់ឡើងគីឲ្យដឹងសោះ រួចលើកឡើងចង ឲ្យធ្វើជាចៅហ្វាយស្រុកតាមអំពើចិត្ត ខុសអំពីទម្លាប់ទំនៀមពីបុកណ ឥឡូវឡើងចងថែមទាំងលះបង់ចោលស្រុកកេរ្តិ៍ដែរ លើកទៅនៅស្រុកសុងយ៉ុងវិញ សុំឲ្យលោកលើកកងទ័ពទៅបញ្ចូលគ្នានឹង

ឡៅពីរ៉ាយយកស្រុកគេនដីវៀងបាន ឡៅពីបានស្តាប់ ក៏ប្រាប់អ៊ុះចៀថា សេចក្តីនេះ អ្នកដ៏នៃតែត្រឹមឡៅបង់អង់អាចតាំងខ្លួនឡើងធ្វើធំ ដែលឈ្មោះទឹងនាងឈ្មោះហ៊ុយមិនគិតត្រូវគំនិតគ្នា លើកយកស្រុកទាំង ៩ មណ្ឌលទៅឲ្យប្អូនអស់លើងនោះ អ្នកមិនដឹងសោះទេ ។ អ៊ុះចៀឮដូច្នោះ ក៏ភ័យស្លុតស្មារតីឆ្លើយថា សេចក្តីទាំងអម្បាលនេះ ហេតុម្តេចបានជាលោកជ្រាប ។ ឡៅពីប្រាប់ថា គួនអ៊ីចាប់ខ្លួនស៊ុងតុងបានយកមកសាកសួរឆ្លើយប្រាប់រឿងរ៉ាវទាំងអស់ បានជាយើងដឹង ។ អ៊ុះចៀថា ដូច្នោះ ក៏ឃើញថាជាការត្រូវហើយ សូមឲ្យលោកលើកទាហានទៅប្រាប់ថា ខឹងលើកមកគំនាប់សពឡៅប៉ៀវតាមប្រវេណី បញ្ឆោតឲ្យឡៅចង់ចេញមកទទួលរួចត្រូវចាប់ខ្លួនសម្លាប់ឲ្យស្លាប់ចេញ ក៏នឹងបានស្រុកនោះដោយងាយ ។

ខុនបេនដំកៈឡៅពីថា ដែលអ៊ុះចៀនិយាយនោះក៏ឃើញថាត្រូវមែនហើយ សូមឲ្យលោកធ្វើតាមចុះ ។ ឡៅពីបានឮខុនបេននិយាយដូច្នោះ ក៏យំសោកកាល័យថា ឡៅប៉ៀវបងខ្ញុំ កាលកំពុងឈឺធ្ងន់បានហៅខ្ញុំទៅនិយាយផ្តាំផ្ញើកូនចៅទាំងពួង ឥឡូវអត់ពីឡៅប៉ៀវទៅមិនទាន់បានប៉ុន្មានថ្ងៃ ខ្ញុំនឹងទៅកែកែប្រទូសរ៉ាយដល់បុត្រភរិយាដណ្តើមយកស្រុកទេសនោះមិនគួរសោះ បើដឹងនៅមិនទាន់ស្លាប់ក៏នឹងមើលមុខគេមិនពេញភ្នែក ។ ខុនបេនឆ្លើយថា ឥឡូវនេះ ប្អូនក៏លើកកងទ័ពមកដល់ស្រុកអ៊ូនសៀហើយ ដែលលោកនឹងគិតការនៅអស់អែកមិនទៅរ៉ាយយកស្រុកស៊ុងយ៉ុងនោះ លោកនឹងគិតការពារប្រការម្តេច ? ។ ឡៅពីថា បើដូច្នោះយើង

ត្រូវតែទៅពួនទៅក្នុងស្រុកហ៊ួនសៀ កាលឡៅពីកំពុងចរចាដូច្នោះ មាន បំរើរសះចូលមកប្រាប់ថា ចូចូលើកទ័ពមកដល់ដំបន់វាលកុកបង់ហើយ ឡៅពីដឹងដូច្នោះ ក៏បង្គំឲ្យអ៊ីបៀត្រឡប់ទៅស្រុកកាំងហែ ឡៅពីនឹងខុងបេង ក៏ចាត់ចែងត្រៀមពួកពលរេហ៍ដែលត្រូវតែតាំងច្បាំងនឹងចូចូ ។

ខុងបេងជំរាបឡៅពីថា ដែលចូចូលើកទ័ពមកគ្រានេះ ជាធុរៈរបស់ខ្ញុំបាទចុះ លោកកុំព្រួយបារម្ភឡើយ គ្រាកាលហែហូទុនលើកមកមុនតែគប់ៈក្តីមួយ យើងក៏ដុតទាហានទាំងអស់ឲ្យវិនាសយកជ័យជំនះបាន ចូចូបើកមកគ្រានេះគង់តែខ្ញុំបាទនឹងធ្វើកលឲ្យចូចូទៅក្នុងកន្ទ្រប់របស់ខ្ញុំបាទជាប្រាកដ តែថាយើងនឹងតាំងនៅក្នុងស្រុកស៊ិនអៀនេះមិនបាន សុំលោកឲ្យទៅប្រកាសប្រាប់បណ្តាអ្នកស្រុក ទាំងប្រុសស្រីក្មេងចាស់ទាំងប៉ុន្មានថា ឥឡូវកងទ័ពចូចូលើកមកនឹងធ្វើអន្តរាយហើយ យើងនឹងនៅក្នុងទីនេះមិនបានទេ នឹងទៅនៅស្រុកហ៊ួនសៀ បើនរណានឹងទៅជាមួយនឹងយើង ក៏ឲ្យប្រុងខ្លួនទុកឲ្យស្រេច បើយើងលើកទៅវេលាណា ក៏នឹងបានទៅជាមួយគ្នា បើនរណាមិនចូលចិត្តទៅទេ នឹងនៅក្នុងស្រុកស៊ិនអៀនេះចុះ បើមានទុក្ខភ័យប្រការម្តេចទៅថ្ងៃមុខ ក៏កុំឲ្យបន្ទោសយើងថា រត់យកតែខ្លួនឯងឡើយ ។ ឡៅពីយល់ឃើញត្រូវផង ក៏ប្រើឲ្យមនុស្សទៅស្រែកប្រកាសប្រាប់អាណាប្រជានុរាស្ត្រក្នុងស្រុកនោះឲ្យបានដឹងគ្រប់គ្នា ហើយចាត់ប្រើ

បីតុក ជាអ្នកសម្រាប់បញ្ជូនគ្រប់គ្រួសារទាហានទាំងពួង លើកទៅស្រុកអ៊ួនសៀ ។

ខុងបេងក៏ចាត់ឲ្យគួនអ៊ូនាំទាហាន ១ ពាន់ លើកទៅនៅលើដើមទឹកព្រែកប៉ែះហោ ឲ្យយកការុងប្រកដ៏ខ្សាច់ទម្លាក់ទប់ធ្វើទំនប់ បិទទប់ទឹកទុកឲ្យខាងចុងទឹកនោះរាក់ ហើយបង្គាប់ថា បើទាហានប៉ូចូបែកទ័ពមកចុះធ្លងទឹកស្ទឹងនោះ បើបានឮសំឡេងអឺងកងឡើងហើយ ចូរបើកទំនប់ចេញឲ្យទឹកបាក់ចុះទៅត្រូវលើទាហាន ដែលកំពុងដើរធ្លងនោះលិចលង់ស្លាប់រួចត្រូវលើកទាហានតាមខ្សែទឹកនោះវាយខ្ទប់ចុះទៅ ហើយឲ្យទាវហ៊ុយនាំទាហាន ១ ពាន់ លើកទៅពួនបង្កប់នៅដំបន់ផាក់ឡេងខាងក្រោមទឹក ហើយបង្គាប់ទុកថា បើឃើញទាហានប៉ូចូលើកធ្លងត្រើយមក ឲ្យវាយខ្ទប់ឡើងទៅប្រសព្វគ្នានឹងគួនអ៊ូ ទើបចាត់ជូឡុងឲ្យនាំទាហាន ៣ ពាន់ ញែកគ្នាជា ៣ កង បង្គាប់ឲ្យយករំសេវបាចទៅលើដំបូលផ្ទះ អាណាប្រជានុរាស្ត្រ ដែលរត់ចោលជាច្រើននោះ ហើយលើកទាហានទៅបង្កប់នៅក្រៅស្រុកខាងទិសឯជើង ទិសឯត្បូង ទិសឯលិច ជា ៣ កង ឯព្រួញធ្នូនោះ ឲ្យចងប្រឆេះរំសេវគ្រប់ព្រួញ បើឃើញទាហានប៉ូចូចូលស្រុកក្នុងពេលកណ្ដាលយប់ព្រមហើយ ក៏ឲ្យទាហានអុចប្រឆេះនោះចុងព្រួញ បាញ់ទៅក្នុងស្រុក ឲ្យភ្លើងឆេះឡើង ហើយឲ្យស្រែកហោពីក្រៅស្រុក ទាហានប៉ូចូក៏នឹងបែកទៅសំដៅធ្លងស្ទឹងប៉ែះហោដូចយើងគិតទុក អ្នកចូល

ស្រួតលើកទៅបញ្ចូលគ្នានឹងទៀតហ៊ុយជួយគ្នា ទើបចាត់ឲ្យប៊ីហាននឹងឡៅហាន២នាក់នេះនាំទាហាន១ពាន់នាក់ កាន់ទង់ក្រហម១កង កាន់ទង់ខៀវ១កង លើកទៅបង្កប់នៅដំបន់វាលធប្លូយដោ ក្រៅស្រុកស៊ុនអៀចម្ងាយផ្លូវប្រហែល៣០០សិន (១២គ.ម.) ហើយបង្គាប់ថា បើឃើញកងទ័ពចូច្ចូលើកមក ត្រូវឲ្យកងស្តាំលើកចូងទៅខាងកងឆ្វេង ឲ្យកងឆ្វេងលើកចូងទៅខាងកងស្តាំ ផ្លាស់ប្តូរគ្នាទៅវិញទៅមកកុំឲ្យឈប់ កងទ័ពចូច្ចូមិនដឹងក៏សំគាល់ថាទាហានកងទ័ពយើងច្រើន ក៏នឹងរង់នៅមិនអាចចូលទៅក្នុងស្រុកក្នុងពេលថ្ងៃ នឹងឲ្យទាហានលើកចូលស្រុកក្នុងពេលយប់វិញ បើទីងមិនធ្វើទុកដូច្នេះ ទាហានចូច្ចូចូលស្រុកបានក្នុងពេលថ្ងៃហើយ ការរបស់យើងគិតធ្វើនោះក៏នឹងមិនសម្រេច បើដល់ពេលយប់ត្រូវឲ្យអ្នកថយចេញឲ្យអស់ បើឃើញភ្លើងឆេះឡើងក្នុងស្រុកហើយ អ្នកចូរជួយដុំឡុងស្រែកហ៊ោសន្ធាប់ទៅ បើឃើញកងទ័ពចូច្ចូបែកទៅហើយ អ្នកចូរនាំទាហានស្រួតទៅបញ្ចូលគ្នានឹងទ័ពគួនអ៊ូឯស្លឹងប៉ែះហោ ។

លុះខុងបេង ចាត់ចែងរៀបកងទ័ពឲ្យលើកទៅហើយ ក៏នាំឡៅពីចេញពីស្រុកស៊ិនអៀ ទៅឡើងលើភ្នំខ្ពស់មួយអង្គុយចាំលបមើលទាហានចាំងតួង ៗ ឯខៅជូដែលជានាយទ័ពស្រួចរបស់ចូចួលើកទាហាន ៣ ពាន់មកមុន លុះលើកមកដល់វាលធប្លូយដោ ក្រឡេកឃើញកងទ័ពប៊ីហានឡៅហានតាំងនៅដូច្នោះ ក៏បរពលចូលបំពារទៅមុខនឹងប្រយុទ្ធគ្នា ។

ប៉ិហាន, ឡេហ៊ានឃើញទៅជូដេញទាហានចូលមក ក៏ឲ្យទាហានផ្លាស់កងស្តាំទៅឆ្វេង ផ្លាស់កងឆ្វេងធ្វេងៈទៅស្តាំ ប្រផ្លាស់គ្នាទៅវិញទៅមកមិនឈប់ ៗ ទៅជូឃើញដូច្នោះ ក៏ឃាត់ទាហានទាំងពួងថា យើងនឹងចូលទៅច្បាំងក្នុងពេលនេះ មិនទាន់បានទេ ខ្លាចក្រែងខុងបេងនឹងប្រើកលឧបាយបង្កប់ទាហានទុកច្រើនកង ទៅជូក៏ស្រុតត្រឡប់វិលមកប្រាប់ទោយ៉ិនទោហាន ៗ ទោយ៉ិននិយាយថា ដែលខុងបេងធ្វើបែបនេះជាកលឧបាយបញ្ឆោតយើងទេ អ្នកមិនដឹងក៏ភិតភ័យ និងខ្លាចអ្វីចូរស្រុតលើកទៅចុះ សឹមយើងលើកទ័ពជំនួនទៅតាមក្រោយ ៗ

ឯទៅជូក៏លើកទាហានចូលទៅដល់ប៉ុងវ៉ាល ទទួលពេលជិតព្រលប់ទើបឃើញកងទ័ពលើករត់ទៅចូលព្រៃទាំងអស់ ទៅជូរៀបទាហាននឹងឲ្យតាមទៅបញ្ចាន់រក ទទួលឮស្នូរសំឡេងមនុស្សស្រែកហ៊ោនៅលើភ្នំទើបងើយឡើងមើល ឃើញឡេហ៊ានទីនឹងខុងបេងជាំងសប្បធនអគ្គបេជឹកស្រាជាមួយគ្នា ទៅជូខឹងណាស់ដេញទាហានឡើងទៅចាប់យកខ្លួនខុងបេង ១ ក៏ឲ្យទាហានទាំងពួងប្រមៀលដុំថ្មធំធ្លាក់ចុះមក ត្រូវទាហានទៅជូពិការស្លាប់អស់ជាច្រើន ឡើងទៅមិនបាន ក៏ថយត្រឡប់មកវិញវិហើយឮស្នូរសំឡេងមនុស្សស្រែកហ៊ោពីក្រោយភ្នំ ទៅជូបំរុងនឹងលើកទា-ហានខ្មាំងទៅតច្បាំង ទទួលទោយ៉ិនលើកទ័ពជំនួយមកដល់ឃាត់ថា ពេល

នេះយប់ងងឹតណាស់កុំអាលចូលច្បាំង យើងត្រូវលើកទៅវាយយកស្រុកស៊ិនអៀសិន ត្រូវបង្អង់ឲ្យទាហានសំរាកកំឡាំងបន្តិច ហាមដូច្នោះ ហើយក៏នាំទៅធ្វូលើកស្រូតទៅដល់ជើងកំពែងស្រុកស៊ិនអៀ ឃើញទ្វារបើកចំហទាំង ៨ ទិស មិនបានឃើញមនុស្សដល់ម្នាក់សោះ ហោយិនមានអំណរណាស់ក៏លើកទ័ពចូលទៅក្នុងស្រុក ។ ហោហង់និយាយនឹងហោយិនថា គ្រានេះឃើញថា ខុងបេងនឹងឡៅពីតាលចង្អៀតខ្លួនណាស់ហើយ ទើបលើកចោលស្រុកនាំគ្រប់គ្រួគេទៅអស់ យើងត្រូវបង្អង់ឲ្យទាហានសំរាកកម្លាំងនៅ ១ យប់សិន ព្រឹកស្អែកសឹមលើកទៅតាមទ័ពចាប់យកខ្លួន ខុងបេង នឹងឡៅពីឲ្យបាន ។ ហោយិននឹងហោហង់ ក៏នាំគ្នាចូលទៅនៅក្នុងកន្លែងលំនៅឡៅតី ទាហានទាំងពួងក៏ដាក់ដេករៀងគ្នាគ្រប់ទីកន្លែង ខ្លះផ្លូវនឿយហត់ណាស់ក៏ប្រះលក់ទៅ ។

លុះដល់ពេលប្រហែលយាម ៣ កើតខ្យល់ព្យុះធំបោកបក់ជាខ្លាំង ដូខ្យង់ឃើញបានចំណាប់ ក៏ឲ្យទាហានស៊ុចប្រះឆេះនៅចុងព្រួញទាំងអស់ ហើយលើកធ្នូបាញ់ព្រមគ្នាចូលទៅក្នុងស្រុក មនុស្សដែលអង្គុយយាមឃើញភ្លើងឆេះគ្រប់ដំបូលផ្ទះ ក៏រត់ចូលទៅដាស់ហោយិន ហោហង់ថា ឥឡូវគេតកើងឆេះគ្រប់ដំបូលផ្ទះហើយ ។ ហោយិនឮដូច្នោះក៏ថា ដែលភ្លើងឆេះនេះ ព្រោះទាហានទាំងពួងដុតដាំបាយប្រហែសបានជាកលឆេះ អ្នកទាំងអស់គ្នាកុំភ័យបារម្ភឡើយ ចូរប្រញាប់នាំគ្នាជួយលត់ឲ្យអស់ទៅ

កាលហោយ៉ិនឃើញដូច្នោះ មិនទាន់ផុតមាត់ ភ្លើងក៏ឆេះព្រមគ្នាគ្រប់ទាំង ៣ ទិសពន្លឺភ្លឺបីដូចជាថ្ងៃ ។

ហោយ៉ិនឃើញដូច្នោះក៏ភ័យតក់ស្លុត ស្រែកហៅទាហានទាំងអស់មកប្រជុំគ្នា ហើយហោយ៉ិន ហោហាំង ក៏ឡើងសេះបរកាត់ភ្លើងចូលទៅតាមទ្វារទិសឯកើត កាលខណៈហោយ៉ិនតែល្អះភ្លើងចេញទៅនោះ ទាហានទាំងពួងក៏ប្រជ្រៀតគ្នាចេញទៅតាមជាន់គ្នាស្លាប់ជាច្រើនណាស់ ។ ជូឡុងក៏ឲ្យទាហានស្រែកហៅសន្ធាប់ បីដូចនឹងដេញតាមសម្លាប់ពីក្រោយ ។ ទាហានហោយ៉ិន ក៏ភ្ញាក់ផ្អើលបណ្តាយបែកទៅប្រពាក់ប្រពូនលើគ្នា ។ ឬហាំង, ឡៅហាំងដែលលើកទៅបង្កប់ ឃើញបានចំណាប់ដូច្នោះ ក៏ដេញទាហានពានទំលាយចូលទៅ ស្ទាត់វាយចាក់កាប់សម្លាប់ទាហានហោយ៉ិនខូចខាតជាច្រើនណាស់ ។ ទាហានហោយ៉ិន ក៏រត់តែបែកបាក់ប្រពាក់ប្រពូនលើគ្នាជាប្របល់ លុះដល់ពេលយាម៣ផ្លាយ ក៏លើកគ្នាទៅដល់ស្ទឹងប៉ិះហោ ទាហានទាំងពួង ក៏ចុះចូលស្ទឹងនឹងទៅត្រើយខាងនាយ សំឡេងដែលស្ដីនិយាយ ក៏លាន់ឮកក្រើកញាប់ញ័រខ្ទរផែនដី ។

ឯគួនអ៊ូដែលនាំទាហានពួនបង្កប់នៅលើដើមទឹក ក៏ឲ្យទាហានទំលាយទំនប់ដែលទប់នោះទាំងអស់ ទឹកក៏ហូរធ្លាក់ធ្លាក់ចុះទៅ ទាហានហោយ៉ិននឹងចូលមិនទាន់ ក៏លិចលង់ស្លាប់លើសលប់នឹងរាប់គណនាពុំបាន គួនអ៊ូក៏ដេញទាហានចំពារទៅចាក់កាប់ សម្លាប់ទាហានហោយ៉ិន ។ ឃើញ

ដូច្នោះក៏ភ័យណាស់ប្រឹងស្ទុះរត់ចូលរំលងទឹកទៅដល់ត្រើយម្ខាង ហើយរត់វាងទៅដល់វាលគុកបង ទៀតហើយក៏លើកទាហានចេញមកស្ទាក់ពីមុខវាយខ្ទប់ប្រសព្វគ្នា ហើយស្រែកថាទ័ពត្រង់នេះ ពួកសាហោរទង់ស្លាប់អស់ហើយ ហោយិន, ហោហង, ទៅជួយើញទៀតហើយលើកទាហានចេញមកដូច្នោះ ក៏ស្លុតស្មារតីភ័យស្មានការមិនបានប្រុងទីងតស៊ូ ក៏នាំទាហានទាំងពួងស្ទុះរត់ចេញទៅ ទៀតហើយក៏លើកទាហានដេញតាមជួបនឹងឡេវពី, ខុងបេង, ក៏នាំគ្នាត្រឡប់មកឯស្ពឹងប៉ែះហោវិញ ខុងបេងក៏ឲ្យបិតុកបង្ខំចម្លងទាហានទាំងពួងពីស្ពឹងប៉ែះហោ ស្រួតទៅស្រុកអ៊ិនសៀអស់ស្រេច ហើយក៏ឲ្យពុះទំលាយទូកនឹងផែទាំងអស់ចេញ ។

ឯហោយិន រួមទាហានដែលសល់ពីស្លាប់និងខាត់ក្មាត់មកនោះបានហើយ ក៏លើកទ័ពត្រឡប់ទៅតាំងនៅស្រុកស៊ិនអៀវិញ ទើបចាត់ឲ្យហោហងនាំដំណឹងទៅជំរាបចូចូចំងណាស់ ឲ្យលើកទាហានស្រួតមកទៀត ដូច្នេះដល់ស្រុកស៊ិនអៀហើយ ក៏ឲ្យទាហានជញ្ជូនដីលើកធ្វើទំនប់ទប់ស្ពឹងប៉ែះហោ ហើយក៏ចាត់ទាហានជាជើងគង់ នឹងឲ្យលើកទៅតាមឡេវពីត្រាជាខ្ទឹងផាន់សង្កត់ស្រុកអ៊ិនសៀឲ្យបាន ៕

ឡេវហ៊ូទីប្រឹក្សាក៏និយាយនឹងខុងបេងថា ដែលមហាទ័ពចោឈលើកមកទីនេះក្រាប់ក្រាមសណ្ណានេក្ត ខាងទិសទក្សិណត្រានេះ គួរនឹងប្រយកចិត្តសណ្ណាប្រជានុរាស្ត្រទាំងពួង ឲ្យមានសេចក្តីមេត្រីស្រឡាញ់ណោះស៊ិន

រថះលោកទឹងបង្ខំលើកទៅដោយកំឡាំងក្រោធឥឡូវនេះក៏គង់បាន  តែថាអាណាប្រជានុរាស្ត្រទាំង២ស្រុកទឹងបានសេចក្តីទុក្ខក្តៅក្រហាយស្លាប់ខ្ចាត់ខ្ចាយអស់  ព្រោះឡៅពីជាតួអាទិដើមហេតុ  ហេតុនេះសុំឲ្យលោកសំពកកង់ទ័ពទុកសិន  ហើយប្រើឲ្យបំរើទៅនិយាយល្បួងយកចិត្តឡៅពីឲ្យចូលមកស្ម័គ្រស្មាគមវិញល្អជាជាង  ទោះបើបើឡៅពីទឹងមិនមកក្តី អាណាប្រជា-នុរាស្ត្រទាំងពួង  ក៏ទឹងក្រឡេកឃើញថា  លោកនៅមានចិត្តអាណិតអ្នកស្រុកមែនៗ  បើឡៅពីមកលំអុតលំទុនដល់លោកហើយ  អាណាខេត្តដែលជាចំណុះស្រុកកេងជីវនោះ  ក៏ទឹងបានមកជារបស់លោកទាំងអស់ដោយងាយ  មិនបាច់ទឹងច្បាំងឲ្យលំបាកពលទាហានទាំងពួងឡើយ ។

ចូចូបានស្តាប់ក៏យល់ចូលចិត្ត  ទើបសួរថា  បើដូច្នោះយើងទឹងប្រើឲ្យអ្នកឯណាទៅចរចាដោយល្អ? ។ ឡៅហ៊ូឆ្លើយថា  ដែលទឹងប្រើឲ្យអ្នកដទៃទៅនិយាយបញ្ចុះបញ្ចូលឡៅពីនោះ  ឃើញជាមិនបានទេ  មានតែឈើស៊ីមួយ  ដែលអាចទឹងទៅនិយាយបាន  ព្រោះឈើស៊ីនេះ  ពីដើមជាមនុស្សរាប់អានគ្នានឹងឡៅពីជាទីទុកចិត្តឥតដែលពាស់គង្យាស្រ័យ  សូមឲ្យលោកប្រើឈើស៊ីនេះទៅចុះ  មុខជានិយាយឲ្យបានការ ។  ចូចូថាអ្នកគិតនេះត្រូវណាស់  តែថាឈើស៊ីនោះ  ជាមនុស្សត្រូវអគង្យាស្រ័យនឹងឡៅពី  បើប្រើទៅហើយឈើស៊ីត្រឡប់ជាមិនវិលមកវិញ  យើងមិនខូចការ

ឬ? ។ ទៀហ៊ូឆ្លើយថា ឯឈីស៊ីនោះជាមនុស្សសុចរិតណាស់ ដែលប្រើទៅហើយ ទឹងមិនត្រឡប់មករកលោកវិញនោះមិនមែនទេ ព្រោះមនុស្សនេះ ជាអ្នកខ្ជាប់សេចក្ដីទិន្នណាស់ លោកកុំសង្ស័យឡើយ ចូរប្រើឲ្យឈីស៊ីទៅចុះ គង់តែវិលត្រឡប់មកវិញជាប្រាកដ ។

ចូចូឮដូច្នោះ ក៏ឲ្យហៅឈីស៊ីចូលមកហើយនិយាយថា ឥឡូវយើងមានសេចក្ដីតូចចិត្តនឹងឡៅពីណាស់ គិតនឹងលើកទ័ពទៅជាន់សង្កត់ស្រុកអ៊ូនសៀឲ្យល្អិតជាធូលី តែមកគិតអាណិតដល់អាណាប្រជានុរាស្ត្រទាំងពួង ទឹងបណ្ដាយឲ្យខូចវិនាសទៅទេ ។ ទៅមិនគួរសោះ សព្វថ្ងៃនេះយើងក៏ដឹងថា ខ្លួនអ្នកនឹងឡៅពីជាមនុស្សត្រូវគំនិតគ្នា ទើបឲ្យអ្នកទៅចរចានិយាយនឹងឡៅពី ឲ្យចូលមកលន់តួអង្វរយើងដោយល្អ កុំឲ្យមានសេចក្ដីក្ដៅក្រហាយដល់បណ្ដារាស្ត្រឡើយ ខ្លួនយើងក៏មិនយកទោសឡៅពីដែរ ទឹងចំនុកបំរើឲ្យបានតាមសេចក្ដីប្រាថ្នា បើទឹងប្រើអ្នកដទៃឲ្យទៅនិយាយការ ខ្លាចក្រែងខូចសេចក្ដីដែលគិតទុក ឃើញតែអ្នកដែលមានសេចក្ដីចំនុកទុកចិត្តល្អត្រង់សុចរិត ចូរអ្នកគិតទៅនិយាយនឹងឡៅពីតាមសំដីយើងចុះ ។ ឈីស៊ីទទួលពាក្យចូចូហើយ ក៏លាចេញទៅដល់ស្រុកអ៊ូនសៀ ។

ខណៈនោះឡៅពី ខុងបេងដឹងថា ឈីស៊ីមកក៏មានអំណរណាស់

ចេញទៅទទួលនាំចូលមក ហើយសាកសួរសុខទុក្ខតាមទំនុកដែលនិរាស ប្រាសចាកគ្នាពីគ្រាមុនរហូតមកតាមប្រវេណី ហើយឈីស៊ុកនិយាយថា ដែលខ្ញុំបាទមកនេះ ព្រោះប្អូនប្រើមកនិយាយល្បួងលួងលោមឲ្យលោក ទៅចំណុះចុះចូល បើខ្ញុំបាទមិនទទួលមកនិយាយក៏មិនបាន តែតាមការ ដែលខ្ញុំបាទប្រមាណឃើញពិត ចិត្តប្អូននោះប្រាថ្នានឹងយកចិត្តអស់អា-ណាប្រជានុរាស្ត្រទាំងពួងទេ ដើម្បីឲ្យអាណាប្រជានុរាស្ត្រទាំងអស់នោះ ស្មោះស្ម័គ្រស្រឡាញ់ប្អូន ទើបបានត្រង់អស់អញនឹងលោកនោះក៏ឥតអ្វី មាន ឥឡូវប្អូនគិតធ្វើការធំណាស់កេណ្ឌពលរេហ៍ឲ្យលើកទំនប់ទប់ទឹកស្ទឹង ប៉ែះហោទាំងមូល ហើយប្រមូលទាហានលើកចែកទុកជា ៨ កង ប៉ងនឹង មកកំចាត់លោកចេញឲ្យបាន ឯស្រុកអ៊ុនសៀនេះជាទីតូចចង្អៀតណាស់ ឃើញថាទទួលកំឡាំងប្អូនមិនបាន ប្អូនឲ្យលោករិះគិតអានខែប្រែប្រួល ទៅឲ្យឆាប់ៗ ឡៅតបថា ដែលអ្នកមកនិយាយដាស់តឿនស្មារតីឲ្យដឹង ជូនស្រាលទាំងអម្បាលនេះពេញចិត្តខ្ញុំណាស់ ខ្លួនអ្នកនឹងខ្ញុំបែកចាកគ្នាទៅ យូរហើយគ្រានេះខ្ញុំឃើញមុខអ្នកហើយ ក៏គឺបុណ្យក៏ត្រូវតែអ្នកនឹងនៅឲ្យ ជាប់កុំត្រឡប់ទៅវិញឡើយ ៗ ឈីស៊ុកឮហើយក៏ឆ្លើយតបថា ខ្ញុំបាទនឹងនៅ នឹងលោកមិនត្រឡប់ទៅរកប្អូនគ្រានេះ ក៏នឹងជាទីគរហានិន្ទាដល់មនុស្ស ទាំងពួងថា ជាមនុស្សគ្មានសេចក្តីកតញ្ញូ មួយទៀតសពមាតាក៏ធ្លាក់ទៅ នៅក្នុងស្រុកហ៊ូតោ ត្រូវតែត្រឡប់ទៅវិញសិន ដែលលោកនឹងធ្វើការ

តទឹងចូចូនោះមិញ ខុងបេងមកនៅជាបង្គោលមាំមួនហើយ លោកទឹងភ័យបារម្ភថា ការអ្វីក៏គង់តែបានសម្រេចដូចប្រាថ្នាទាំងអស់ ឈើស៊ីថាដូច្នោះហើយ ក៏លាឡៅពីខុងបេងត្រឡប់ទៅប្រាប់ចូចូវិញ លុះទៅដល់ស្រុកស៊ុនអៀ ក៏ចូលទៅជំរាបចូចូថា ខ្ញុំបាទបានទៅនិយាយល្បួងឡៅ-ពីដោយសុភាពហើយ ឥឡូវឡៅពី មិនព្រមចូលមកលំអុតលំទុនដល់លោកទេ ៗ ចូចូឮដូច្នោះ ក៏ខឹងណាស់ ទើបឲ្យលើកកងទ័ពស្រូតទៅទឹងជាន់សង្កត់ស្រុកអ៊ិនសៀឲ្យបាន ៗ

ឯឡៅពីក៏សួរខុងបេងថា ដែលយើងតតាំងច្បាំងនឹងចូចូលើកនេះតើត្រូវគិតប្រការម្ដេច ? ៗ ខុងបេងថា យើងនឹងតតាំងច្បាំងនឹងកងទ័ពចូចូក្នុងស្រុកអ៊ិនសៀនេះមិនបានទេ ត្រូវតែបោលស្រុកអ៊ិនសៀនេះវិះទៅនៅឯស្រុកស៊ុនយ៉ុនដែលជាទីមាំទើបបាន ៗ ឡៅពីថា ដែលនឹងបោលស្រុកអ៊ិនសៀទៅនៅឯស្រុកស៊ុនយ៉ុននោះ ក៏ល្អណាស់ហើយ តែថាខ្ញុំមានសេចក្ដីព្រួយនឹងអាណាប្រជានុរាស្ត្រទាំងពួងបងកំឡាំងប្រឹងតាមយើងមកផង យើងនឹងបោះបង់បោលគ្នាតែស្រួលយកតែខ្លួនក៏ដូចជាគ្មានធម៌សប្បុរស គួរឲ្យអាណិតអាធ័ណាស់ ៗ ខុងបេងថា បើដូច្នោះត្រូវឲ្យបំរើទៅស្រែកប្រកាសថា ឥឡូវកងទ័ពចូចូលើកមកធ្វើអន្តរាយស្រុកយើងនេះទៀតហើយ បើញាតិលើកកំឡាំងនឹងទ្រាំនៅពុំបាន យើងត្រូវរួតប្រែប្រួលបបួលគ្នាលើកទៅនៅស្រុកស៊ុនយ៉ុន អ្នកទាំងឡាយនឹងទៅ

តាមយើងក៏ទៅ បើមិនទៅនិងស៊ូត្រូវចង់នៅក្នុងស្រុកនេះក៏តាមអធ្យាស្រ័យចុះ ។ ទៀតពីឮដូច្នោះក៏ប្រើគួនអ៊ូទៅចាត់ចែងរកទូកសម្រាប់ចំឡងគ្នាទៅស្រុកសុនយ៉ុង ហើយក៏ឲ្យស៊ុនខៀននិងកាន់យ៉ុងទៅស្រែកប្រកាសប្រាប់ប្រជាជនទាំងពួងតាមពាក្យខុងបេង ។

ខណៈនោះ បណ្ដាអ្នកស្រុកដែលឮដូច្នោះក៏ឆ្លើយថា យើងខ្ញុំនិងនៅក្នុងស្រុកស៊ីនសៀនោះ ស៊ូឲ្យស្លាប់ជីវិត មិននៅជាដាច់ខាត បើទៀតពីទៅនៅទីណា យើងខ្ញុំពលគ្នាក៏សុំទៅតាមជាមួយ អ្នកស្រុកទាំងពួងក៏ស្រុះស្រួលគ្នាព្រមចោលទីលំនៅទាំងអស់ លើកគ្រប់គ្រួចេញទៅតាមទៀតពី ខ្លះក៏យំស្រែកដោយផ្លូវទៅ លុះទៀតពីឆ្លងទៅដល់កណ្ដាលទឹកស្ទឹងក្រឡេកមើលមកក្រោយ ឃើញបណ្ដាស្ត្រីយំស្រែកអឺងកងតាមត្រើយទាំងសងខាង ក៏ទន់ចិត្តអាណិតអាសូរណាស់ ទៀតពីក៏យំសោកថា មនុស្សទាំងអស់នេះនាំគ្នាមក ប៉ុនសេចក្ដីលំបាកក្រាត់ក្រាសទឹកនៃទ្ន ក៏ព្រោះយើងនេះឯង ទៀតពីជាដូច្នោះហើយ ក៏ក្រោកឈរឡើងគិតនឹងលោតទឹកសម្លាប់ ទាហានក៏ស្ទុះទៅចាប់ឃាត់ទុកហើយយំសោកទាំងអស់គ្នា ។

លុះឆ្លងទៅដល់ត្រើយម្ខាងហើយ ទៀតពីក៏នៅមិនទាន់ទៅទៀត រង់ចាំពួកអ្នកស្រុកឲ្យឆ្លងទៅរួចទាំងអស់គ្នា បង្ខំឲ្យគួនអ៊ូយកទូក

(នៅមានត)

## ផ្នែកកំណត់និងប្រវត្តិការណ៍

# ពិធីបើកការសិក្សានៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងពិធីសម្ពោធគ្រឹះស្ថានព្រះសីហនុ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជ.

លោក ជ.ង.–ខ.ង. រៀបរៀង

កាលពីព្រឹកថ្ងៃពុធ ៤ កើត ខែជេស្ឋ ឆ្នាំកុរឯកស័ក ព.ស ២៥០២ (១០-៦-៥៩) មានធ្វើពិធីសម្ពោធបើកការសិក្សានៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងពិធីសម្ពោធគ្រឹះស្ថានព្រះសីហនុរាជ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជ នាយករដ្ឋមន្ត្រី ។

នៅម៉ោង ៨-៣០ មានការជួបជុំព្រះសង្ឃទាំងពីរគណៈ និងពុទ្ធបរិស័ទ ។ ម៉ោង ៨ ៤៥ សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្ត ព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា ជាតំណាងនៃសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ប្រធានសភាទាំង ២ សមាជិករដ្ឋាភិបាល សមាជិកសភាទាំង ២ ព្រមទាំងមន្ត្រីអ្នករាជការគ្រប់តំណែង និមន្ត ស្តេចយាង អញ្ជើញមកដល់ ។

ម៉ោង ៨-៩០ អន្ទូតនានា ប្រធានគណៈកម្មការអន្តរជាតិ បានអញ្ជើញមកប្រជុំក្នុងពិធីនេះ ៗ

នៅម៉ោង ៩ សម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជនាយករដ្ឋមន្ត្រី ដោយមានទាំងសមាជិកក្រុមប្រឹក្សានៃព្រះរាជា និងព្រះរាជបរិពារផ្ទាល់ព្រះអង្គតាមហែផង បានស្តេចយាងមកដល់កន្លែងប្រកបពិធី ដែលនៅទីនោះ មានកងទាហានក្រុមរក្សាព្រះអង្គ ក្រុមជន្ត្រីព្រះរាជទ្រព្យបានធ្វើគារវកិច្ចជាព្រះរាជកិត្តិយស ៗ តមក ក្រុមជន្ត្រីព្រះរាជទ្រព្យបន្ទឹងនូវបទនគររាជថ្វាយជាទីគោរព ៗ ក្រោយដែលព្រះនរបតី គង់ប្រថាប់លើព្រះសុវណ្ណកោដ្ឋៈហើយ លោក អ៊ុំ-ហុងសាធ រដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថា មានសេចក្តីដូចតទៅនេះ-

សូមព្រះតេជៈដ៏កល់លើត្បូង,

សូមព្រះរាជទានក្រាបបង្គំទូល សម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជ-

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ៗ

ក្នុងនាមនៃក្រសួងធម្មការ និងមហាសនសក្យាធិការ និងក្នុងនាមផ្ទាល់នៃទូលព្រះបង្គំជាខ្ញុំ, ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានថ្លែងនូវសេចក្តីសោមនស្សរីករាយជាបំផុត ព្រមទាំងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ និង

ដោយគោរពបំផុតរបស់ទូលព្រះបង្គំជាខ្ញុំ ចំពោះព្រះករុណាថ្លៃវិសេស ដែលទ្រង់សព្វព្រះរាជហឫទ័យស្តេចយាងមកជាព្រះរាជាធិបតី ក្នុងពិធីបើកការសិក្សា នៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងពិធីសម្ពោធឆ្លងគ្រឹះស្ថានព្រះសីហនុ ដែលទើបនឹងសង់រួចថ្មីៗនេះ ។

ម្យ៉ាងទៀត ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងនូវសេចក្តីអំណរយ៉ាងក្រៃលែង ចំពោះសម្តេចព្រះសង្ឃនាយក ព្រះថេរានុត្ថេរៈទាំងឡាយ ទ្រង់ ឯកឧត្តម អស់លោក និងអស់អ្នក ដែលនិមន្ត យាង អញ្ជើញមកជួយលើកតំកើងពិធីនេះ ឲ្យបានរុងរឿងជាពិសេសក្នុងពេលនេះ ។

សូមទ្រង់ព្រះមេត្តាប្រោស,

ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដែលកើតឡើងដោយអំណាចនៃព្រះរាជក្រមលេខ៨៧៩ ន-ស-បុះថ្ងៃទី ១ កក្កដា ១៩៥៤ គឺជាវិទ្យាល័យខាងផ្នែកព្រះពុទ្ធសាសនា ឋិតនៅក្នុងព្រះបរមរាជូបត្ថម្ភដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។ ពុទ្ធិកវិទ្យាល័យនេះ តាំងពីកើតឡើងដរាបដល់ឥឡូវនេះ មានអាយុ ៨ ឆ្នាំហើយ តែក្នុងរយៈកាលដែលកន្លងទៅនេះ ពុំទាន់មានការសិក្សានៅឡើយ ដោយហេតុមកពីពុំទាន់មានគ្រឹះស្ថានសិក្សា ពុំទាន់បានរៀបចំកម្មវិធីនៃការសិក្សា ព្រមទាំងពុំទាន់

មានសមណនិស្សិត ដែលមានការចេះដឹងគ្រប់គ្រាន់ល្មមនឹងចូលមកសិក្សាបានផង ។

ក្នុងរយៈកាល ៩ ឆ្នាំ ដែលកន្លងទៅនេះ ជាពេលដែលត្រូវរៀបចំបណ្ដុះបណ្ដាលសមណនិស្សិត ដែលសិក្សាក្នុងពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត អស់កាល ៤ ឆ្នាំ ឲ្យមានចំណេះវិជ្ជាការចេះដឹងគ្រប់គ្រាន់ល្មមអាចចូលមកសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យបាន ទាំងកម្មវិធីនៃការសិក្សាក៏បានរៀបចំហើយស្រេច ទាំងគ្រឹះស្ថានសិក្សា គ្រឹះស្ថានសម្រាប់ចាត់ការទីចាត់ការទីបណ្ណាល័យ ព្រមទាំងគ្រឿងសម្ភារៈផ្សេង ៗ ក៏បានស្ថាបនាបានបង្កើតឲ្យមានសព្វគ្រប់ ។

សូមទ្រង់ព្រះមេត្តាប្រោស,

កិច្ចការគ្រប់យ៉ាងដូចខាងលើនេះ ក្នុងរយៈកាល ៩ ឆ្នាំ ដែលកន្លងទៅនេះ ក្រសួងធម្មការបានផ្ទុកដាក់លើព្រះតេជព្រះគុណព្រះពោធិវ័ង្ស សូមឲ្យលោកចាត់ការគ្រប់យ៉ាង ជាកបង់ហើយស្រេច ។ ព្រះតេជព្រះគុណព្រះពោធិវ័ង្ស លោកបានខំប្រឹងចាត់ការគ្រប់យ៉ាង មានការស្ថាបនាគ្រឹះស្ថានជាដើម ដោយផ្ទាល់អង្គលោក មិនបានប្រគល់ផលសហគ្រាសណាមួយឲ្យទទួលម៉ៅឡើយ ដើម្បីឲ្យធូរថ្លៃផង ឲ្យបានឆាប់ហើយស្រេចផង ។

ហេតុនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតនិមន្តព្រះពោធិវ័ង្ស ជាអគ្គាធិការពុទ្ធិកសិក្សា ធ្វើសេចក្ដីរាយការណ៍អំពីកិច្ចការ

សព្វសារពើ ក្រាបបង្គំទូលព្រះករុណាថ្លៃពិសេស ដើម្បីទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ទីបំផុត ទូលព្រះបង្គំជាខ្ញុំ សូមឧទ្ទិសព្រះពរកុសល ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ និងសម្តេចព្រះឧបយុវរាជ សូមព្រះអង្គបានប្រកបដោយសុភមង្គល និងសិរីសួស្តីគ្រប់យ៉ាង និងសិរីរាជសម្បត្តិអស់កាលជាអង្វែងតទៅ ។

សូមព្រះតេជៈតំកល់លើត្បូង

បន្ទាប់មកព្រះពោធិវង្ស ហួត-តាត អគ្គាធិការពុទ្ធិកសិក្សា បានថ្លែងសុន្ទរកថាតមកទៀត មានសេចក្តីដូចតទៅនេះ :

សូមថ្វាយព្រះពរ ព្រះករុណាជាអម្ចាស់ជីវិត សម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជ ,

សូមថ្វាយបង្គំសម្តេចសង្ឃនាយក ,

សូមថ្វាយព្រះពរសម្តេច ទ្រង់ សូមចំរើនពរ ឯកឧត្តម និងអស់លោកទាំងឡាយ ,

ពេលនេះ ខ្ញុំព្រះករុណា អាត្មាភាព មានបីតិសោមនស្ស បរិកពយរាងក្រៃលែង ចំពោះព្រះករុណាជាអម្ចាស់ជីវិត សម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះឧបយុវរាជ សម្តេចសង្ឃនាយក ទ្រង់ ឯកឧត្តម និងអស់លោកទាំងឡាយ ដែលបានស្តេចមក និមន្តមក អញ្ជើញមក

ជាព្រះរាជាធិបតី និងជាកិត្តិយសក្នុងឱកាសពិធីបើកការសិក្សានៃពុទ្ធិក-មហាវិទ្យាល័យព្រះសីហនុរាជ និងពិធីសម្ពោធឆ្លងគ្រឹះស្ថានព្រះសីហនុ ដែលទើបនឹងសង់រួចថ្មី ៗ នេះ ។

សូមទ្រង់ព្រះមេត្តាប្រោស ,

អម្បាញ់មិញនេះ លោករដ្ឋលេខាធិការក្រសួងធម្មការ និងសាសន-សិក្សាធិការ បានថ្លែងសេចក្ដីរាយ អំពីការកើតឡើងនៃពុទ្ធិកមហា-វិទ្យាល័យនេះរួចហើយ ។

ឥឡូវនេះ អាត្មាភាព សូមព្រះរាជទានព្រះរាជវរោកាសបន្តិច ថ្លែងសេចក្ដីរាយ អំពីការស្ថាបនាគ្រឹះស្ថាននៃពុទ្ធិកមហាវិទ្យាល័យ និងអំពីកិច្ចការខ្លះ ដែលទាក់ទងដល់ពុទ្ធិកមហាវិទ្យាល័យនេះ ដើម្បីទ្រង់ជ្រាបដូចមានសេចក្ដីតទៅនេះ :

នៅពេលបន្ទាប់អំពីការកើតឡើង នៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជនេះ សម្ដេចព្រះឧបយុវរាជ កាលគង់លើព្រះរាជបល្ល័ង្កនៅឡើយ ទ្រង់បានប្រោសព្រះរាជទានទីដីនេះ ឲ្យសង់គ្រឹះស្ថានសិក្សាសម្រាប់ពុទ្ធិកមហាវិទ្យាល័យនេះ ។ បន្ទាប់ពីនោះមកទៀត ទ្រង់បានប្រោសព្រះរាជទាន ព្រះរាជទ្រព្យពីរលើក គឺលើកទីមួយ ចំនួន ១០ ម៉ឺនរៀល លើកទីពីរចំនួន ១៥០ ម៉ឺនរៀល មកក្រសួងធម្មការ ឲ្យចាត់ចែងកសាងគ្រឹះស្ថាននៃពុទ្ធិកមហាវិទ្យាល័យ ។ ក្រសួងធម្មការបានប្រគល់ការ:

កសាងមកអាត្មាភាព អាត្មាភាព ក៏បានទទួលរៀបចំស្ថាបនាគ្រឹះស្ថានទាំងអស់ក្នុងទីនេះ តាំងពីឆ្នាំ ១៩៥៤ រហូតមកដល់ចុងឆ្នាំ ១៩៥៨ បានហើយស្រេច ដូចមានសេចក្តីរៀបរាប់ថ្វាយតទៅនេះ:

១- គ្រឹះស្ថានសិក្សា ១ ខ្នងខាងលិច ទទឹង ១០ ម៉ែត្រ បណ្តោយ ៤០ ម៉ែត្រ មានបន្ទប់សិក្សាទាំងថ្នាក់ក្រោម ទាំងថ្នាក់លើ ១០ បន្ទប់ ។ គ្រឹះស្ថាននេះ គឺគហបតី ប៉េ-យ៉ាន មានសទ្ធាជ្រះថ្លា បានបរិច្ចាគទ្រព្យរបស់ខ្លួនកសាងក្នុងឆ្នាំ ១៩៥៤ ។ ក្នុងឆ្នាំនោះ គហបតី ប៉េ-យ៉ាន កសាងបានតែត្រឹម ៦ បន្ទប់ អស់តម្លៃ ៧០ ម៉ឺនរៀល ហើយបានធ្វើបុណ្យឆ្លងគ្រឹះស្ថាននោះ មកពងរដ្ឋាភិបាល ឲ្យដំកល់ទុកជាសម្បត្តិរដ្ឋសម្រាប់ធ្វើជាកន្លែងសិក្សាខាងព្រះពុទ្ធសាសនា ។ លុះដល់មកឆ្នាំ ១៩៥៧ បុត្រប្រសារនិងធីតាបង្កើតនៃគហបតី ប៉េ-យ៉ាន បានកសាងបន្ថែមទៀត គឺលោកតាន់-អៀមគង់ និងនាង ប៉េ-ស៊ុក៉ន សាងពីរបន្ទប់ទៅខាងជើង លោកលី-ជិនលឹម នាង ប៉េ-ស៊ុក៉ត សាងពីរបន្ទប់ទៅខាងត្បូង រួមទាំងមុនផង ១០ បន្ទប់ ។ រួមតម្លៃទាំងមុនទាំងក្រោយ ១១០ ម៉ឺនរៀល បើគិតទាំងតម្លៃតុរៀនគ្រប់ថ្នាក់ ៥ ម៉ឺនរៀលទៀត ត្រូវជា ១១៥ ម៉ឺនរៀល ។

២- គ្រឹះស្ថានមួយខ្នងខាងជើង ជាគ្រឹះស្ថានសិក្សាទទឹង ១០ ម៉ែត្រ បណ្តោយ ២៤ ម៉ែត្រ ធ្វើជាបន្ទប់សិក្សាបាន ៦ បន្ទប់ ។ គ្រឹះស្ថាននេះ

សាងក្នុងឆ្នាំ ១៩៥៦ ដោយប្រាក់ថវិកាជាតិ ៥០ ម៉ឺនរៀល និងប្រាក់ព្រះរាជទ្រព្យសម្តេចព្រះឧបយុវរាជ ២០ ម៉ឺនរៀល ដែលដកយកពីក្នុងចំនួន ១៦០ ម៉ឺនរៀល រួមប្រាក់ទាំងពីរផ្នែកនេះ ចំនួន ៧០ ម៉ឺនរៀល, សាងអស់តែ ៦៧ ម៉ឺនរៀល នៅសល់ ៣ ម៉ឺនរៀល ។ ៣ ម៉ឺនរៀល ដែលសល់នេះ ចំណាយជាគ្រឿងទិញកៅអី រៀបចំធ្វើបណ្ណាល័យបណ្តោះអាសន្នមួយសម្រាប់ពុទ្ធិកមហាវិទ្យាល័យ ។

៣–គ្រឹះស្ថាន ១ខ្នងខាងត្បូង ទទឹង ១១ម៉ែត្រ បណ្តោយ ២៥ម៉ែត្រ ។ គ្រឹះស្ថាននេះ សាងក្នុងដើមឆ្នាំ ១៩៥៨ ដោយប្រាក់ព្រះរាជទ្រព្យសម្តេចព្រះឧបយុវរាជ ដែលទ្រង់ប្រោសព្រះរាជទាន ១៦០ ម៉ឺនរៀល ប៉ុន្តែបានដកយក២០ម៉ឺនរៀល ទៅបំពេញការកសាងគ្រឹះស្ថានខាងជើង នៅសល់តែ ១៤០ ម៉ឺន ។ នេះ យកមកចំណាយក្នុងការកសាងគ្រឹះស្ថានថ្មី ១ និងឃ្លាំង ១ អស់ចំនួនប្រាក់ ១.៣១៤.២៩១៛០១ (មួយរយសាមសិបមួយម៉ឺនបួនពាន់ពីររយកៅសិបមួយរៀល) ។

គ្រឹះស្ថាននេះ សាងអស់ចំនួនប្រាក់ច្រើនជាងគ្រឹះស្ថានខាងជើងដោយហេតុគ្រឹះស្ថាននេះ ដំបូលធ្វើតាមប្រពៃណីបុរាណ ហើយថ្នាក់ខាងក្រោមបានរៀបចំធ្វើកន្លែងសម្រាប់ចាត់ការនៅពុទ្ធិកមហាវិទ្យាល័យផង ធ្វើជាកន្លែងសម្រាប់ចាត់ការ ខាងពុទ្ធិកសិក្សាក្នុងព្រះរាជាណាចក្រផង ទើបត្រូវធ្វើឲ្យមានបន្ទប់ច្រើន ៗ ឯថ្នាក់ខាងលើធ្វើជាបណ្ណាល័យនៃពុទ្ធិកមហា-

វិទ្យាល័យ ។ ក្រៅពីនេះ មានការចំណាយទៅក្នុងការរៀបចំដាក់ភ្លើង ការរៀបចំការិយាល័យគ្រប់ថ្នប់ ព្រមទាំងចំណាយក្នុងការចាក់ដីបំពេញត្រង់កន្លែងទំនាបឲ្យបានរាបស្មើ អស់ចំនួនប្រាក់៧២.៩៨០រ៉ុ០០ (ប្រាំពីរម៉ឺនពីរពាន់ប្រាំបួនរយប៉ែតសិបរៀល) រួបរួមទាំងអស់ «១.៣៨៧ ២៧១រ៉ុ០០ (មួយរយសាមសិបប្រាំប៉ឺនប្រាំពីរពាន់ពីររយចិតសិបមួយរៀល) ។

សូមទ្រង់ព្រះមេត្តាប្រោស

ព្រះសង្ឃ គ្រហស្ថជាពុទ្ធបរិស័ទទាំងឡាយ មានសេចក្ដីរីករាយក្រៃលែង ចំពោះព្រះរាជអំណោយ ដែលសម្ដេចទ្រង់បានប្រោសព្រះរាជទាន មកជួយបំពេញកិច្ចសាងនាពុទ្ធិកមហាវិទ្យាល័យនេះ ឲ្យបានសម្រេចដោយប្រពៃ ។ ប្រសិនបើពុំមានព្រះរាជអំណោយ ដែលមានចំនួនដូចខាងលើនេះទេ ការសាងនាគ្រឹះស្ថាន មុខជានឹងមានការរអាក់រអួលពុំខាន ។

ដោយហេតុនេះ ពុទ្ធបរិស័ទទាំងឡាយមានកតញ្ញូតាធម៌ចំពោះព្រះគុណដ៏ខ្ពង់ខ្ពស់នេះ ឥតមានភ្លេចសោះឡើយ ព្រះគុណមួយទៀត គឺទឹកព្រះទ័យដ៏បរិសុទ្ធរបស់សម្ដេច កាលក្នុងឱកាសដែលគង់លើព្រះរាជបល្ល័ង្កនៅឡើយ ទ្រង់បានប្រោសព្រះរាជទានព្រះរាជានុញ្ញាត ឲ្យបង្កើតពុទ្ធិកមហាវិទ្យាល័យនេះឡើង,ព្រះគុណនេះ ឧត្តុង្គឧត្តមណាស់ ព្រោះព្រះរាជានុញ្ញាតឲ្យបង្កើតពុទ្ធិកមហាវិទ្យាល័យនេះឡើង ប្រាកដស្មើដូចជាទ្រង់ប្រោសព្រះរាជទាន ឲ្យបង្កើតគ្រឿងចក្រមួយ យ៉ាងទាន់សម័យ សម្រាប់

បណ្ដុះបណ្ដាលឲ្យកើតប្រាជ្ញាភ្លឺស្វាង ដល់មជ្ឈដ្ឋាននៃព្រះសង្ឃពុទ្ធសាសនិកក្នុងប្រទេស ៗ លុះតមក សម្ដេចទ្រង់នៅតែមានព្រះទ័យអនុគ្រោះជួយឧបត្ថម្ភឲ្យពុទ្ធិកមហាវិទ្យាល័យ មានដំណើរប្រព្រឹត្តទៅស្រួលរហូតដល់មកថ្ងៃនេះ ដែលជាថ្ងៃត្រូវបើកការសិក្សាជាផ្លូវការតទៅ ៗ

ពុទ្ធិកមហាវិទ្យាល័យនេះ តាំងពីកើតឡើង ៤ ឆ្នាំហើយ ទោះបីពុំទាន់ដល់កាលទីត្រូវបើកការសិក្សានៅឡើយក៏ពិតមែន ប៉ុន្តែពុទ្ធិកមហាវិទ្យាល័យ អាចបានទទួលផលបណ្ដើរៗ មកដែរ រហូតដល់ពេលនេះគឺៈ

១-រាជការបារាំងសែស ខាងផ្នែកវប្បធម៌បានជួយផ្ដល់សាស្ត្រាចារ្យជាតិបារាំងសែស១នាក់ ឲ្យជួយបង្រៀនភាសាបារាំងសែស នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ដល់មកបើកការសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យនេះ បានជួយផ្ដល់សាស្ត្រាចារ្យជាតិបារាំង១នាក់ទៀត ព្រមទាំងជួយផ្ដល់សៀវភៅសិក្សាជាច្រើន ៗ

២-មូលនិធិអាស៊ីជាអង្គការសមាគមអាមេរិកាំង បានជួយផ្ដល់សាស្ត្រាចារ្យ ២ នាក់ ជាតិអាមេរិកាំង ១ នាក់ ជាតិខ្មែរ១នាក់ ឲ្យជួយបង្រៀនភាសាអង់គ្លេស នៅពុទ្ធិកវិទ្យាល័យទាំងនៅពុទ្ធិកមហាវិទ្យាល័យនេះ ព្រមទាំងសៀវភៅសម្រាប់សិក្សារាប់ពាន់សៀវភៅ ហើយជួយផ្ដល់ឲ្យបោះពុម្ពសៀវភៅសម្រាប់សិក្សាជាអក្សរខ្មែរផងទៀត ៗ

៣-រាជការឥណ្ឌៀ បានជួយផ្ដល់សាស្ត្រាចារ្យមួយនាក់ជាតិឥណ្ឌៀ

ឲ្យជួយបង្រៀនភាសាសំស្ក្រឹត នៅពុទ្ធិកវិទ្យាល័យ និងនៅពុទ្ធិកមហាវិទ្យាល័យនេះ ព្រមទាំងជួយផ្តល់សៀវភៅសំស្ក្រឹតជាច្រើនសៀវភៅ ។

សាស្ត្រាចារ្យឯទៀតៗក្រៅពីជំនួយបរទេស ដែលបង្រៀនវិជ្ជាខាងផ្លូវព្រះពុទ្ធសាសនា និងខាងផ្លូវលោក ជាភារៈលើរដ្ឋាភិបាលជាតិ គឺរដ្ឋាភិបាលនៃសង្គមរាស្ត្រនិយម ដែលមានអគ្គសម្តេចជាព្រះមគ្គុទ្ទេសក៍ ។

មួយទៀត គង់ពុទ្ធិកមហាវិទ្យាល័យនេះ បានបង្កើតបណ្ណាល័យ ១ ជាបណ្តោះអាសន្ន ៤ ឆ្នាំហើយ ឥឡូវនេះ កំពុងរៀបចំឲ្យមានរបៀបរៀបរយ ។ បណ្ណាល័យនេះ ទោះបីនៅជាបណ្តោះអាសន្នក៏ដោយ គង់បានទទួលផលដោយលំដាប់ គឺបានទទួលអំណោយសៀវភៅពីបរទេសមានអង្គការនៃមូលនិធិអាស៊ីជាដើម ។ មានសៀវភៅឯទៀតខ្លះ ក្រៅពីជំនួយបរទេស ច្រើនជាសៀវភៅអក្សរខ្មែរនោះ បានចំណាយប្រាក់ថវិកាស្វយ័តនៃពុទ្ធិកមហាវិទ្យាល័យបន្តិចបន្តួច ជាវយកមកដាក់តម្កល់ទុក ។

សព្វថ្ងៃនេះ គង់បណ្ណាល័យមានសៀវភៅភាសាខ្មែរ ភាសាបារាំងសែស ភាសាអង់គ្លេស ភាសាបាលី ភាសាសំស្ក្រឹត ភាសាថៃ ភាសារុស្ស៊ីខ្លះ និងភាសាចិនខ្លះ រួមទាំងអស់ប្រមាណ ៥.០០០ សៀវភៅ ។

ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ សូមសំដែងនូវកតញ្ញូតាធម៌ ចំពោះរាជរដ្ឋាភិបាលសង្គម ដែលបានជួយជ្រោមជ្រែង ជួយផ្តល់ការខ្វះ

ខាត ឲ្យមានដំណើរត្រង់ទៅតាមវិញ្ញូនភាពក្នុងអនាគត ម្យ៉ាងទៀត សូមអរគុណចំពោះអស់លោក ជាតំណាងរដ្ឋាភិបាលនៃប្រទេសនានា ដែលបានជួយផ្ដល់ដល់ពុទ្ធិកមហាវិទ្យាល័យដោយសម្ភារៈ នឹងបុគ្គលិក ឬគ្រឿងសិក្សា ។

ម្យ៉ាងទៀត កិច្ចការទាំងឡាយក្នុងពុទ្ធិកមហាវិទ្យាល័យនេះ ដែលបានចំរើនតៗមក ដោយអាស្រ័យនឹងលោកអគ្គលេខាធិការ ដែលជាអ្នកកាន់កាប់ផ្ទាល់ :

អគ្គលេខាធិការទី១ គឺលោក អ៊ុប-វ៉ែន លោកបានខំយកចិត្តទុកដាក់ណាស់ នាំឲ្យបានចំរើន ។

អគ្គលេខាធិការទី២ គឺលោក សុខ-សេន ក៏លោកខំប្រឹងបំពេញកិច្ចការនេះណាស់ដែរ នាំឲ្យបានចំរើនតមកទៀត ។

អគ្គលេខាធិការទី៣ គឺលោក អៀង-គុណ សាគី សព្វថ្ងៃនេះ ។

លោកអគ្គលេខាធិការទាំង ៣ នេះ លោកមានវិជ្ជា នឹងសមត្ថភាពប៉ុណ្ណា លោកបានបំពេញកិច្ចការ ក្នុងមហាវិទ្យាល័យនេះ ដោយយកចិត្តទុកដាក់ជាបំផុត នាំឲ្យដំណើរការក្នុងមហាវិទ្យាល័យ រេះតែបានប្រព្រឹត្តទៅមុខជាដរាប ។

អាត្មាភាពជាតំណាងបុគ្គលិកខាងពុទ្ធិកសិក្សា សូមថ្លែងនូវអំណរគុណចំពោះក្រសួងធម្មការ ដែលបានជួយខ្នះខ្នែងក្នុងកិច្ចការជាសាធារណៈ

នៃពុទ្ធិកមហាវិទ្យាល័យនេះ ជាពិសេសទៅទៀត មានអំណរគុណចំពោះក្រសួងសិក្សាធិការជាតិ ដែលបានជួយផ្ដល់នូវសាស្ត្រាចារ្យនិងគ្រូបង្រៀន ព្រមទាំងបុគ្គលិកបច្ចេកទេស ឲ្យមកជួយក្នុងពុទ្ធិកមហាវិទ្យាល័យនេះ ។

នៅអវសាននេះ អាត្មាភាពសូមរំលឹកគុណព្រះរតនត្រ័យ និងសូមសំបូងសម្រួងចំពោះទេវតាដែលមានចិត្តសប្បុរស សូមជួយអភិបាលរក្សាព្រះករុណាជាអម្ចាស់ជីវិត សម្ដេចព្រះមហាក្សត្រិយានី និងសម្ដេចព្រះឧបយុវរាជ ព្រមទាំងព្រះរាជវង្សានុវង្ស មួយអន្លើដោយឯកឧត្តមនិងអស់លោកអ្នកទាំងឡាយ ឲ្យបានប្រកបតែនឹងសេចក្ដីសុខសួស្ដីជ័យមង្គលដ៏ប្រសើរគ្រប់ទិវារាត្រីអស់កាលជាអង្វែងតទៅ កុំបីឃ្លៀងឃ្លាតឡើយ ។

ជាទីបំផុត សម្ដេចព្រះនរោត្តម-សីហនុ នាយករដ្ឋមន្ត្រី ព្រះអង្គបានថ្វាយព្រះរាជសុន្ទរកថា មានអត្ថរសដ៏ជ្រាលជ្រៅ ដូចមានតទៅនេះ:

សូមពិតពុទ្ធដីកា សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក សម្ដេចព្រះសុធម្មាធិបតីសង្ឃនាយក ព្រះសង្ឃគ្រប់ព្រះអង្គ សូមជ្រាប ។

សូមជំរាបពុទ្ធបរិស័ទ ដែលបានមកជួបជុំក្នុងទីនេះ ។

នៅឱកាសដ៏ប្រសើរនេះ ខ្ញុំព្រះករុណាខ្ញុំ មានហឫទ័យរីករាយ សោមនស្សយ៉ាងលើសលុប ដោយមានភ័ក្តិយសបានតាមដង្ហែសម្ដេចព្រះមហាក្សត្រិយានី ជាម្ចាស់លើត្បូង ស្ដេចយាងមកក្នុងពិធីបើកការ

សិក្សានៅពុទ្ធិកមហាវិទ្យាល័យ ទីងពិធីសម្ពោធគ្រឹះស្ថានព្រះសីហនុក្រោមអធិបតីភាពនៃព្រះអង្គ ។

ព្រះគុណម្ចាស់គ្រប់ព្រះអង្គ !

អស់លោក !

ខ្ញុំព្រះករុណាខ្ញុំ មានសេចក្ដីអរព្រះគុណយ៉ាងជ្រាលជ្រៅ ចំពោះសម្ដេចព្រះមហាសុមេធាធិបតី ដែលព្រះអង្គមានទត្តមគតិដ៏ប្រសើរ បានរៀបចំស្ថាបនាមហាវិទ្យាល័យនេះ ការស្ថាបនានេះ បានសម្រេចដោយសារពលិកម្មរបស់ពុទ្ធបរិស័ទជួយឧបត្ថម្ភ ។

ចំណែក ខ្ញុំព្រះករុណាខ្ញុំ ដែលបានធ្វើពលិកម្មរួបរួមជាមួយ ក៏មានសោមនស្សរីករាយជាពន្លឹកពេកណាស់ ។

ការដែលប្រទេសកម្ពុជាយើង បានបង្កើតឲ្យមានពុទ្ធិកមហាវិទ្យាល័យនេះ ជាការដ៏ប្រសើរមួយ ដែលត្រូវតែគ្រោងទុកក្នុងប្រវត្តិសាស្ត្រនៃជាតិយើងនៃប្រទេសយើង ដែលអំណើះតទៅ សាកលលោកសន្មតបានថា មានវឌ្ឍនធម៌ខ្ពង់ខ្ពស់ក្នុងពុទ្ធិកសិក្សា ស្មើហានឹងអារ្យប្រទេសឯទៀត ដែលកាន់លទ្ធិសាសនាដូចគ្នា ។

រាជរដ្ឋាភិបាលបានជួយឧបត្ថម្ភដំណើរមហាវិទ្យាល័យថ្មីនេះ ដោយផ្ដល់ឲ្យនូវប្រាក់ថវិកានិងសាស្ត្រាចារ្យ សូមបវារណា នឹងព្រះតេជព្រះគុណព្រះពោធិវង្ស ជាអគ្គាធិការពុទ្ធិកសិក្សា ហើយព្រះអង្គជាវីរៈបុរស បាន

ស្ថាបនាមហាវិទ្យាល័យដោយព្រះហស្ថា និងជួយឧបត្ថម្ភមហាវិទ្យាល័យនេះ ក្នុងការដែលអាចជួយបានតទៅ គឺដូចជាបន្ថែមសាស្ត្រាចារ្យក្តី ប្រគេនអាហារូបករណ៍សម្រាប់ព្រះគ្រូអង្គខ្លះ ដែលមានករណីយកិច្ចទៅធ្វើការពិសោធន៍ និងបំពេញវិជ្ជាខាងគរុកោសល្យនៅក្រៅប្រទេសក្តី ។

ខ្ញុំករុណា សូមឱកាសចំពោះសម្តេចទាំងពីរព្រះអង្គ ព្រះសង្ឃសមណនិស្សិត ដើម្បីប្រគេនទុកខ្លះ សម្រួលតាមកម្មវិធី ទោះបីមានឆ្គាំឆ្គងខ្លះ សូមមេត្តាអភ័យទោស ។

ព្រះតេជព្រះគុណគ្រប់ព្រះអង្គ !

ខ្ញុំករុណា មានហឫទ័យរីករាយពន់ពេកណាស់ ដោយបានឃើញថា អំណើះតទៅ សមណនិស្សិត ដែលមានចំណេះវិជ្ជានិងបញ្ញាក៏នឹងអាចបន្តវិជ្ជាជាន់ខ្ពស់បានយ៉ាងងាយតៈទៅទៀត ដោយមានផែនក្នុងកម្មវិធីមហាវិទ្យាល័យស្រាប់ ៗ ដូច្នេះហើយ កិត្តិនាមព្រះពុទ្ធសាសនាខ្មែរនឹងបានទទួលផលចំរើនតទៅមុខ ៗ

ក្រៅពីការសិក្សាខាងព្រះពុទ្ធសាសនា និងមគធភាសា ដែលមានផែនក្នុងកម្មវិធីមធ្យមសិក្សា និងឧត្តមសិក្សាស្រាប់ហើយ កម្មវិធីនេះ មានទាំងផែនអំពីការបង្រៀនគា ហសាគលទិយម ដែលជាយានសម្រាប់ទាក់ទងក្នុងការអន្តរជាតិ សព្វថ្ងៃនេះ ហើយនិងវិទ្យាសាស្ត្រសម័យថែមទៀតផង ។

កិច្ចនេះជាការមានប្រយោជន៍ពិតប្រាកដណាស់ ពីព្រោះភិក្ខុសង្ឃយើង ដែលជាអ្នកដឹកនាំខាងទឹកចិត្តនិងសីលធម៌នៃប្រទេសជាតិ ត្រូវតែដំកល់ខ្លួនជាអ្នកមានចេតនារម្មណ៍ដែលក្តីចិត្តពួនជាងគេ ។

ចំពូកមួយទៀត ជាការជួយនឹងសាសនាឯទៀត, សាសនាព្រះពុទ្ធនេះ ទោះបីបើមានផលដែលគេឃើញក្នុងវិទ្យាសាស្ត្រក្រោយ ៗ មកទៀត យ៉ាងដូចម្ដេចក៏ដោយ ក៏អាចគង់នៅឋិតថេរចីរកាលជាដរាបបាន ដោយព្រះធម៌នៃព្រះពុទ្ធអង្គ ពុំមានផ្ទាំផ្គង់ជួយនឹងវិទ្យាសាស្ត្រសម័យថ្មី ។

ទោះបីនៅក្នុងសម័យបរមាណូរយើងនេះក៏ដោយ ព្រះពុទ្ធសាសនាក៏នៅតែមានថេរភាពដដែលនឹងជាក់ស្ដែងដដែល ។

ពិភពលោកសព្វថ្ងៃនេះ ដែលឋិតនៅក្នុងការព្រួយបារម្ភ ដោយអនាគតមិនក្ដីស្មាន បើសិនជាប្រញាប់យកធម៌ព្រះពុទ្ធមកពិចារណាអាចនឹងដោះស្រាយអស់ទាំងបញ្ហាគ្រប់យ៉ាងរបស់ខ្លួនបាន ទុកជាបញ្ហានោះស្មុគស្មាញយ៉ាងណាក៏ដោយ ។ នេះហើយដែលជាសេចក្ដីជឿស៊ប់នៃប្រជាជាតិ ដែលមានចំនួនកាន់តែច្រើនឡើងក្នុងលោក សូម្បីតែជនអ្នកកាន់សាសនាដទៃ ក៏ចាប់ផ្ដើមសិក្សាលទ្ធិពុទ្ធសាសនាដែរ ។ ស្ទើរតែគ្រប់ប្រទេសក្នុងពិភពលោក មានអ្នកកប់អាននឹងសមាគមអ្នកពិនិត្យស្រាវជ្រាវទូវធម៌នៃព្រះពុទ្ធអង្គ ។

ចំណែកខាងការកែប្រែ នឹងការរៀបចំពុទ្ធិកសិក្សា ឲ្យបានទាន់

សម័យ យើងពិតជាចូលក្នុងមាគ៌ាដ៏ត្រូវ ។

ក៏ប៉ុន្តែ ខ្ញុំករុណា សូមរំលឹកដល់ព្រះគុណម្ចាស់ និងសមណនិស្សិតទាំងឡាយថា ការដែលយើងដើរតាមសម័យថ្មីនេះ តម្រូវជាកាតព្វកិច្ចដល់យើងទាំងឡាយ កុំធ្វើឲ្យព្រះពុទ្ធសាសនាឃ្លាតចេញចាកពីពុទ្ធបំណងដែលជាហេតុនាំឲ្យពុទ្ធសាសនាសាបរលាបអស់ខ្លឹមសារ ។

ព្រះពុទ្ធសាសនាមានសាខាពីរ ដែលនឹងអាចដុះដាលទៅកាន់វិសិដ្ឋភាពបាន លុះណាតែសាខាទាំងពីរ បានទទួលការផ្គត់ផ្គង់ដោយស្មើភាគគ្នា គឺវិជ្ជានិងវិន័យ ។

ការប្រតិបត្តិតឹងតែង ដោយឥតវិជ្ជា ដោយមិនស្គាល់ជម្រៅ ព្រះពុទ្ធសាសនាជាកិច្ចប្រតិបត្តិឥតបានផល ។

ឯវិជ្ជានិងវិទ្យាសាស្ត្រទៀតសោត ក៏លែងមានប្រយោជន៍ខាងផ្លូវចិត្ត និងផ្លូវសាសនា កាលបើវិជ្ជានិងវិទ្យាសាស្ត្រមិនពឹងផ្អែកលើគុណធម៌ និងការប្រតិបត្តិវិន័យដោយម៉ឺងម៉ាត់ (គោលបំណងនៃសាសនារបស់យើងគឺ វិសិដ្ឋភាពនៃមនុស្សជាតិ ១ ការលើកទឹកសំអាតទឹកចិត្ត ១ ការស្វែងរកសុភមង្គលនិងសេចក្ដីសុខ ១ ការប្រយុទ្ធនឹងរោគាពាធនិងទុគ៌តភាព ១ ការរំកិលទៅជិតព្រះនិព្វានបើមិនទាន់បានដល់ ១ ) ។

ព្រះពុទ្ធសាសនាពិតប្រាកដ បានដល់អរិយមគ្គខាងហីនយាន ។ យើងជាអ្នកកាន់ព្រះពុទ្ធសាសនាប៉ែកខាងហីនយាន ។ ហេតុនេះ ការដុះ

ផលខាងវិជ្ជារបស់យើង ដើម្បីនឹងឲ្យបានប្រយោជន៍ដល់ព្រះពុទ្ធសាសនា និងជាតិ ត្រូវតែបិតនៅក្នុងក្របខ័ណ្ឌនៃការប្រតិបត្តិវិន័យបែបហីនយាន ដែលជាលទ្ធិព្រះពុទ្ធសាសនាមានក្រឹត្យវិន័យយ៉ាងតឹងរ៉ឹង ពុំមែនជាទស្សនវិជ្ជាឥតគោលបំណងដ៏ជាក់លាក់ឡើយ ។

ក្នុងបេសកកម្មពិសិដ្ឋ ខាងការដឹកនាំប្រជាជាតិយើងទៅកាន់សន្តិភាព សាមគ្គីភាព សុភមង្គល ព្រះភិក្ខុសង្ឃជាតិយើងដែលមានព្រះសង្ឃចេះដឹងជ្រៅជ្រះជាងគេជាដើម មិនគ្រាន់តែជាទីប្រឹក្សាប៉ុណ្ណោះទេ គឺជាចៅក្រមសំរេចវិនិច្ឆ័យដោយយុត្តិធម៌ ដល់អ្នកបំរើប្រទេស អ្នកទទួលបន្ទុកការខុសត្រូវ ក្នុងវិជ្ជាជីវៈឬក្នុងរដ្ឋបាលដល់រាជបល្ល័ង្កផង ។

រាជបល្ល័ង្ក តែងមានសេចក្ដីទុកចិត្តលើយុត្តិធម៌នៃសាសនា ហើយតែងតែបំរើនិងការពារព្រះពុទ្ធសាសនា ដោយសមានចិត្ត ចាប់តាំងពីដើមកំណើតនៃរដ្ឋកម្ពុជាមក ។

ក្នុងប៉ុន្មានឆ្នាំនេះ មានជនខ្លះដែលច្រើនតែរស់នៅឯបរទេស គិតខំបញ្ចុះបញ្ចូលឲ្យព្រះភិក្ខុសង្ឃយើងកាន់ជើងខ្លួន ព្រោះគេដឹងថា ព្រះភិក្ខុសង្ឃយើង មានអានុភាពលើប្រជាពលរដ្ឋរបស់យើងជាពិត ។

គោលបំណងអ្នកទាំងនេះ គឺបង់រំលំរាជបល្ល័ង្ក ហើយតាំងសាធារណរដ្ឋជំនួស ដើម្បីបានគេជាអ្នកកាន់បង្គ្បជាកំពូល ។

ដើម្បីនឹងសំរេចគោលបំណងនេះ គេធ្វើដូចម្ដេចឲ្យភិក្ខុសង្ឃជួយ

គេ គឺជួយដោយដើរថ្លែងពាក្យមួលបង្កាច់ពីកដបល័ក្ខ ដែលគេចោទអំពីបទអាក្រក់គ្រប់យ៉ាងប្រាប់ប្រជាកស្ត្រ ។

គេបង្កាច់ថា កដបល័ក្ខជាស្ដេចធ្វើការប្រឆាំងនឹងឯកភាពរបស់ប្រទេស ប្រឆាំងនឹងឯកភាពជាតិ ។

បច្ចុប្បន្នសម័យនេះ យុត្តិធម៌នៃព្រះពុទ្ធជាម្ចាស់បានបង្ហាញដល់ព្រះភិក្ខុសង្ឃ និងដល់យុវជនឲ្យឃើញការពិតលើវត្ថុធាតុទាំងពីរ គឺឯករាជ្យ និងឯកភាព ។

ក្នុងបច្ចុប្បន្នកាលនេះ គេពុំអាចរកឃើញមានប្រទេសឯណាមួយ ដែលមានឯករាជ្យបរិបូណ៌ដាច់ដោយឡែកពីបក្សពួក (Bloces) ប្រឆាំងគ្នាដោយលទ្ធិ និងប្រយោជន៍ផ្ទុយគ្នា ព្រមទាំងដាច់ពីការជះជាន់របស់មហាអំណាចចក្រពត្តិនិយម ទាំងខាងលិច ទាំងខាងកើត ឲ្យស្មើនឹងប្រទេសកម្ពុជា បានឡើយ ។

ប្រជាជាតិយើងដឹងច្បាស់ថា ឯករាជ្យនិងអព្យាក្រឹតភាពបានមកពីអ្នកណា ? ហើយអ្នកណាចង់បំផ្លាញឯករាជ្យនិងអព្យាក្រឹតរបស់ជាតិខ្លួន ដើម្បីជាគុណប្រយោជន៍ឲ្យបរទេសវិញ ។

ឯកភាពជាតិទៀតសោត ក៏បានលូតលាស់ជាលំដាប់ទៅកាន់វឌ្ឍនភាពតាំងពីឆ្នាំ ១៩៥៣ មក ហើយបានពេញបរិបូណ៌ក្នុងសម័យនេះ ទើបមានជនក្បត់ជាតិខ្លះ ដោយប្រាថ្នាប្រយោជន៍ផ្ទាល់ខ្លួន បានចូលដៃនឹង

មហាអំណាចបរទេស ដែលចង់បំផ្លាញបូរណភាព ឯកភាព អធិប-
តេយ្យភាព នៃព្រះរាជអាណាចក្រ ។

ដល់គេរំលំរាជបល្ល័ង្កមិនបាន គេរកសម្លាប់អ្នកទ្រទ្រង់រាជបល្ល័ង្កនេះ គឺខ្ញុំករុណានេះឯង ។ ហើយគេព្យាយាមទូលពុទ្ធដីកាព្រះអង្គខ្លះ ដើម្បីឱ្យទៅផ្សាយដល់ប្រជារាស្ត្រថា ការចំរើន ការលូតលាស់នៃប្រទេស ដែលធ្វើក្រោមដឹកនាំខ្ញុំករុណាមានតែលើក្រដាសទេ ហើយថា សហការីដែលបំរើខ្ញុំករុណានោះ សុទ្ធតែជាអ្នកពុករលួយ ចេះតែបញ្ចោរប៉ុណ្ណោះ ។

ខ្ញុំករុណា សុំឱ្យព្រះគុណម្ចាស់ ព្រមទាំងភិក្ខុសង្ឃទាំងឡាយ មេត្តារកយុត្តិធម៌ឱ្យបានដឹងទៅចុះ ។ តាំងពីយើងបានឯករាជ្យមក ហើយជាពិសេស តាំងពីបានចលនាសង្គមមក ខ្ញុំករុណាតាំងនាមប្រជាជាតិ ដែលបានធ្វើសេចក្តីទុកចិត្តលើខ្ញុំករុណា ហើយដែលបានតម្រូវ ឱ្យខ្ញុំករុណាកាន់កាប់ការប្រទេសយើង បានបញ្ជាជាដាច់ខាតដល់ភ្នាក់ងាររាជការទាំងអស់ ឱ្យខំធ្វើការតាមកម្មវិធីដែលយើងបានគ្រោងទុក ឱ្យអស់ពីកំឡាំងចិត្ត និងកំឡាំងកាយ គ្រប់ទាំងអស់ ។

ខ្ញុំករុណា បាននិមន្តគណៈប្រតិភូសង្ឃទាំងពីរគណៈ ទៅពិនិត្យមើលលទ្ធផលរបស់យើង ដែលបានកើតឡើង តាំងពីទីក្រុងរហូតដល់និគមជនបទដាច់ស្រយាល ។

ព្រះសង្ឃច្រើនព្រះអង្គ ដែលប្រកបដោយព្រះទ័យសុទ្ធចិត្ត និងយុត្តិ-

ធម៌ បានមានពុទ្ធដីកាថា ស្រាប់តែភ្ញាក់នឹងលទ្ធផលទាំងធំទាំងតូចរបស់សង្គម ហើយថាមិនគាប់ចិត្តនឹងលទ្ធផលទាំងនោះបានគ្រប់សព្វ ដោយឥតសំចៃកយ៉ាំងយូរក្នុងរាល់នឹងស្វែងរកកិច្ចអ្វីៗ ។ ពួកមហាអំណាចបរទេសដែលមានអ្នកតំណាង នឹងអ្នកបង្កើតការនៅក្នុងនេះស្រាប់ ឬរដ្ឋបុរសរបស់គេ ដែលបានអញ្ជើញមកទស្សនាប្រទេសយើង មានរដ្ឋមន្ត្រីជប៉ុនក្រសួងនានាប្រទេស ដែលបានអញ្ជើញមកកាន់ប្រទេសយើងក្នុងខែសីហាឆ្នាំនេះជាដើម បានបញ្ជាក់ចំពោះមិត្តអន្តរជាតិ ថាយើងបានធ្វើការឱ្យមានសេដ្ឋកិច្ចចំរើនដល់ប្រទេសមានលទ្ធផលល្អច្រើនជាពិតប្រាកដ ។

ព្រះតេជព្រះគុណ ! ធម្មតាប្រទេសនីមួយៗ ប្រទេសយើងក៏ដូចប្រទេសគេ យើងនៅមានខ្វះចន្លោះដែលនឹងត្រូវបំពេញក្នុងអនាគត យើងនៅមានគុណវិបត្តិមិនខុសពីរបស់ទាំងឡាយ ដែលមនុស្សលោកធ្វើនោះទេ ហើយជួនកាលយើងជួបប្រទះនឹងឧបសគ្គស្ទើរធ្វើមិនរួច មានឧបសគ្គនៃពួកក្បត់ជាតិនឹងពួកបរទេសជាចៅហ្វាយនាយរបស់គេជាដើម ។ ក៏ប៉ុន្តែ បើយើងគិតឱ្យដល់មធ្យោបាយដំណោះស្រាយរបស់ប្រទេសយើងៗគាប់មើលមុខប្រទេសជាតិឯទៀតដោយឥតអៀនខ្មាស ក្នុងករណីដែលយើងសាងជាតិយើងនេះ ។ ឯរឿងដែលគេចោទថា សហការីរបស់ខ្ញុំករុណាពុករលួយ ហើយថាចេះតែបញ្ចេញបញ្ចោះនោះ ខ្ញុំករុណាសូមព្រះគុណម្ចាស់ និងយុវសមណៈមេត្តាពិនិត្យឱ្យច្បាស់លាស់ឱ្យបានផងចុះ ។

ខ្ញុំករុណា សូមទូលពុទ្ធដីកាឲ្យបានជ្រាបដូចតទៅនេះ : ក្នុងសម័យបោះឆ្នោតសាកលជាថ្មីក្នុងឆ្នាំ ១៩៥៨ ពួកវរជនចំណាន ៗ ដែលធ្លាប់ទ្រទ្រង់គណបក្សប្រឆាំង មានគណបក្សប្រជាធិបតេយ្យជាដើម ព្រមទាំងពួកយុវជនចេះដឹង ទឹងមានសញ្ញាប័ត្រខ្ពង់ខ្ពស់ បានចូលរួបរួមក្នុងសង្គម ហើយ ក្នុងពាក្យសុំចូលរបស់គេនោះ គេបញ្ជាក់ថា គេស្របតាមនយោបាយខាងក្នុងនិងខាងក្រៅប្រទេស ព្រមទាំងទទួលស្គាល់ថា ការគ្រប់គ្រងប្រទេសរបស់សង្គម ជាការត្រឹមត្រង់ប្រសើរ ៗ តាមសេចក្តីស្នើរបស់សង្គម ការរំលាយរដ្ឋសភាសង្គមទី ១ ដោយមានសមាជិកច្រើននាក់ បានប្រព្រឹត្តកំហុសខាងការស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន ដូចជាពួកគណបក្សក្នុងរដ្ឋសភាមុន ការរំលាយនេះ នាំឲ្យពួកប្រឆាំងពីដើមឃើញថាសង្គមមិនការពារកូនចៅដែលមានកំហុសរបស់ខ្លួនឡើយ ៗ

ម្យ៉ាងទៀត ក្នុងពេលដែលផ្លាស់ប្តូរគណៈរដ្ឋមន្ត្រីម្តង ៗ ខ្ញុំករុណាតែងតែខំផ្លាស់ប្តូរមនុស្សដែលត្រូវកាន់តំណែងរដ្ឋមន្ត្រីមួយ ៗ តាមគោលការណ៍តែម្យ៉ាងគឺ: សមត្ថភាព, កិរិយាមារយាទល្អ, អតីតកាលស្អាតស្អំ ៗ

ក្នុងសម័យនេះ សូមព្រះគុណម្ចាស់សួរដល់លេខាធិការដ្ឋានទៅទីស្តីការនាយករដ្ឋមន្ត្រី ឲ្យបង្ហាញបញ្ជីរាយនាមរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយក្រុម នាយក្រសួងរាជការទាំងអស់ក្នុងព្រះរាជអាណាចក្រ ព្រមទាំងសមាជិករដ្ឋសភា ព្រះអង្គនឹងឃើញថា អស់លោក

ទាំងនោះ គាត់ប្រើនស្លូតែយុវជនស្អាតបរិសុទ្ធ គ្មានរឿងហេតុក្នុងការ ឬជាអតីតគណបក្សប្រឆាំងពីដើម ដែលពុំបានជួយខ្ញុំករុណាក្នុងការបោះឆ្នោត ដើម្បីធ្វើឲ្យសង្គមមានជ័យជំនះ ហើយដែលក្នុងពេលនេះទៀត ក៏មិនបេះបញ្ចើចបញ្ចើខ្ញុំករុណាទេ ។ ចំពោះខ្ញុំករុណានៅតែរើសយក ហើយប្រគល់តំណែងនឹងអគ្គការដ្ឋមន្ត្រីញយាងសំខាន់ៗ ដែលជាអាយុជីវិតនៃប្រទេសឲ្យកាន់កាប់ ។ ហិរញ្ញវត្ថុ សេដ្ឋកិច្ចជាតិ-ធនាគារ ។ ល ។ ខ្ញុំករុណាបានប្រគល់ឲ្យសហជីវិន ដែលទើបនឹងចូលសង្គមថ្មីៗ ហើយមិនដែលបានជួយសង្គម ព្រមទាំងមិនដែលបានបញ្ចើចបញ្ចើខ្ញុំករុណាផង ។

សហជីវិន ថ្មីៗថ្មោងទាំងនោះ ដែលមានខ្លះបានទាំងទិទៀនដេរប្រមាថមើលងាយខ្ញុំករុណាខ្ញុំពីដើមផង អាចពិតពុទ្ធដីកាព្រះគុណម្ចាស់បានថា ដើម្បីធ្វើឲ្យខ្ញុំករុណាទុកចិត្ត ពុំចាំបាច់ធ្វើអ្វីដទៃក្រៅពីធ្វើការដោយម៉ត់ចត់ ហើយស្មោះត្រង់ជូនប្រទេសនឹងព្រះនោះទេ ។

ខ្ញុំករុណាពុំអាចអួតថា ខ្ញុំករុណា បានកំចាត់ពួកអ្នកកជការ ឬសហការីដែលគ្មានសេចក្ដីទុកចិត្ត របស់ខ្ញុំករុណាបានទាំងអស់នោះទេ ។ ក៏ប៉ុន្តែ ព្រះគុណម្ចាស់ ដែលជ្រាបនូវភាពនៃមនុស្សលោកច្បាស់ជាងនរណាៗទាំងអស់ អាចយល់បានថា តើមានរដ្ឋាភិបាលណាមួយ ដែល

ត្រូវតែប្រើរបៀបប្រជាធិបតេយ្យ ហើយពុំអាចយករបៀបបង្ក្រាបយ៉ាងម៉ឺងម៉ាត់សាហាវតាមលទ្ធិកុម្មុយនិស្តមកប្រើផង អាចធ្វើឲ្យបានប្រសើរជាងនេះ ក្នុងការបោសសំអាតបានឬទេ ?

ចំណែកខ្លួនខ្ញុំករុណាៗ មិនធ្លាប់ការពារអ្នកកជការអាក្រក់នោះឡើយ ទោះបីជាមនុស្សស្និទ្ធស្នាលក៏ដោយ ។

ខ្ញុំករុណា ឥតរួញរាក្នុងផ្តន្ទាទោសចំពោះកំហុសទាំងអស់ ដែលគេឃើញនោះទេ ។ ខ្ញុំករុណាស្តាយត្រង់ថា ក្នុងបណ្តាពួកដែលចោទប្រកាន់រាជរដ្ឋាភិបាល ដោយមានមនុស្សពុករលួយ ក្នុងព្រះរាជអាណាចក្រខ្លះ អ្នកចោទខ្លាំងជាងគេ គឺខ្លួនអ្នកនោះឯងតែម្តង (គឺពួកសម-សារី) ដែលរាស្ត្រទាំងឃុំជនបានទាត់ចេញពីសង្គមជាតិ ដោយអំពើពុករលួយកែពុំឡើងរបស់ខ្លួន ហើយដែលក្នុងពេលនេះ ធ្លាក់ខ្លួនទៅធ្វើជាអ្នកសុំកងដែនដីបរទេស ដើរពោលមួលបង្កាច់តែប្រទេសខ្លួនដោយឥតអៀនខ្មាស ដើម្បីនឹងទទួលលាភសក្ការៈលុយកាក់ នឹងបានបន្តបំណងឧក្រិដ្ឋរបស់ខ្លួន ។

នៅទីបំផុតនេះ ខ្ញុំករុណាសូមប្រសិទ្ធិពរប្រគេនដល់ព្រះគុណម្ចាស់គ្រប់ព្រះអង្គជាសាស្ត្រាចារ្យនិងនិស្សិត ហើយសុំឲ្យមហាវិទ្យាល័យនេះតាំងនៅឋិតថេរកាល ជាប្រយោជន៍ដល់អនុជនទៅអនាគត សុំឲ្យធម៌និងវិន័យព្រះពុទ្ធជាម្ចាស់មានប្រសិទ្ធិភាពជាក់ស្តែង សមណនិស្សិតគ្រប់អង្គ

សូមបានទទួលផល នៃការសិក្សាព្រះពុទ្ធសាសនា ក្នុងមហាវិទ្យាល័យ ជាកិរិយាភាពតទៅ ។

លុះចប់ព្រះរាជសុន្ទរកថាហើយ សម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ដោយមានសម្ដេចព្រះឧបយុវរាជ និងឥស្សរជនខ្មែរ-បរទេស តាមហែអមព្រះអង្គផង បានស្ដេចយាងកាត់ខ្សែបូ ជានិមិត្តរូបនៃការបើកការសិក្សាគ្រឹះស្ថានខាងទិសឧត្តរ រួចព្រះអង្គបានស្ដេចយាងទតកន្លែងសិក្សាដែលមានសមណនិស្សិត ៤០ រូប ។

បន្ទាប់មកទៀត ព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា សំដែងនូវនាមសាស្ត្រាចារ្យថ្វាយព្រះអង្គទ្រង់ជ្រាប ដែលពេលនោះព្រះសង្ឃជានិស្សិត បានស្វាធ្យាយជមិជយន្តោ ប្រសិទ្ធិពរថ្វាយព្រះអង្គ ដើម្បីទ្រង់ប្រកបដោយព្រះបរមសុខសួស្ដីក្នុងព្រះរាជសម្បត្តិ ។

បន្ទាប់ពីនោះ សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះឧបយុវរាជ ដែលមានព្រះរាជបរិពារដែលហែអមព្រះអង្គផង បានស្ដេចយាងកាត់ខ្សែបូនៅគ្រឹះស្ថានព្រះសីហនុ ហើយព្រះអង្គទ្រង់បានទស្សនាទីផ្សេងៗក្នុងគ្រឹះស្ថាននោះ រួចស្ដេចយាងឡើងទតនូវបណ្ណាល័យខាងលើ ដែលខណៈនោះ សម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូងនឹងសម្ដេចព្រះឧបយុវរាជ ទ្រង់សព្វព្រះរាជហឫទ័យ ឡាព្រះហស្ត-លេខាលើសៀវភៅមាស ។ ឯសមាជិកអង្គទូតនានា ក៏បានចុះហត្ថលេខា

លើសៀវភៅមាសនោះជាបន្ទាប់បន្តគ្នា ដើម្បីទុកជាអនុស្សាវរីយ៍ ។

លុះចប់កិច្ចទស្សនានេះហើយ ក៏មានការថ្វាយកេសដ្ឋៈ ចំពោះសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជ ព្រមទាំងជូនកេសដ្ឋៈ ចំពោះភ្ញៀវកិត្តិយសទាំងឡាយ សោយនិងទទួលទាន ក្នុងបរិយាកាសដ៏រីករាយយ៉ាងក្រៃលែង ដើម្បីជាកិច្ចបញ្ចប់ពិធី ។

នៅវេលាម៉ោង ១១ ១៥ សម្តេចព្រះមហាក្សត្រិយានីនិងសម្តេចព្រះឧបយុវរាជ ដោយមានព្រះរាជបរិវារដែលតាមហែព្រះអង្គផង បានទ្រង់ស្តេចយាងទៅកាន់ព្រះបរមរាជវាំងវិញ ដោយក្រុមទាហានធ្វើការ-កិច្ចថ្វាយជាព្រះរាជកិត្តិយស ដូចកាលស្តេចយាងមកដល់ ។

លុះដល់ពេលរសៀល មានការសម្ពោធឆ្លងគ្រឹះស្ថានព្រះសីហនុ តាមរបៀបព្រះពុទ្ធសាសនា ។ ការបុណ្យនេះ ចាត់ចែងធ្វើឡើងដើម្បីថ្វាយព្រះរាជកុសល ចំពោះសម្តេចព្រះឧបយុវរាជ ជាកិច្ចចំរើនព្រះជន្មាយុនៃសម្តេច ដោយព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា បុគ្គលិកក្រុមពុទ្ធសាសនបណ្ឌិត្យ បុគ្គលិកក្នុងអគ្គាធិការដ្ឋាន ក្នុងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងក្នុងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ទាំងព្រះសង្ឃទាំងគ្រហស្ថ ព្រមទាំងសាស្ត្រាចារ្យ និងសមណនិស្សិតទាំង

អស់ក្នុងការឧបត្ថម្ភនៃក្រសួងធម្មការ ដែលមានលោក អ៊ុង–ហុងសាធ រដ្ឋលេខាធិការជាទៅក្រសួង ។

នៅម៉ោង ១៩·៣០ បាននិមន្តព្រះសង្ឃ ៣៩ អង្គ ចំរើនព្រះបរិត្តនៅទីគ្រឹះស្ថានព្រះសីហនុដាក់ខាងលើ ។ ម៉ោង ២០-៣០ និមន្តព្រះតេជព្រះគុណព្រះធម្មលិខិត ម៉ឹង សែស ចៅអធិការ វត្តមហាមន្ត្រី សំដែងធម៌ទេសនា ។ បន្ទាប់មក បានបញ្ចាំងខ្សែភាពយន្តអំពីរឿងព្រះរាជសកម្មភាពនៃសម្តេចព្រះឧបយុវរាជ រហូតដល់ម៉ោង ១ អធ្រាត្រ ។

ថ្ងៃព្រហស្បតិ៍ ៥ កើត ខែជេស្ឋ ឆ្នាំកុរឯកស័ក ព.ស. ២៥០២ (១១-៦·៥៩) នៅម៉ោង ៩ ព្រឹក ព្រះសង្ឃ ៣៩ អង្គ ដែលចំរើនព្រះបរិត្តពីយប់ថ្ងៃទី ១០ ពុទ្ធបរិស័ទ – បុគ្គលិកអគ្គរាជការក្នុងក្រុមពុទ្ធសាសនបណ្ឌិត្យ – ក្នុងអគ្គាធិការដ្ឋាន – ក្នុងក្រសួងធម្មការ – ក្នុងពុទ្ធិកមហាវិទ្យាល័យ និងក្នុងពុទ្ធិកវិទ្យាល័យ និមន្ត អញ្ជើញមកដល់ ។ នៅម៉ោង ៩-៣០ សម្តេចព្រះឧបយុវរាជស្តេចយាងមកដល់ ។ តមក ព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា ឧទ្ទិសព្រះរាជកុសល ហើយពុទ្ធបរិស័ទសមាទានសីល ៥ ព្រះសង្ឃក៏បានសូត្រធម៌ពហូទវាជ្ជូង ។ បន្ទាប់មក សម្តេចព្រះឧបយុវរាជទ្រង់ប្រោះព្រួសដាក់បាត្រ ព្រមទាំងប្រគេនទេយ្យទាន ។ ព្រះសង្ឃអនុមោទនាថ្វាយព្រះរាជកុសលរួចថ្វាយព្រះពរលា ។ សម្តេចព្រះឧបយុវរាជ ស្តេចយាងទៅកាន់ព្រះរាជដំណាក់វិញ ។

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

( តទៅ )

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

**អជ្ញាន** នបុំ. អញ្ញាណៈ សេចក្ដីល្ងង់ខ្លៅ ។ គុ. ដែលមិនចេះ, ដែលមិនពិសោធ ។

**អជ្យេឞ្ឋ** បុំ. ការមិនមែនជាបង; គុ. ដែលមិនច្បង ។ – *វ្ឫត្តិ* បុំ. ដែលមិនប្រព្រឹត្តទៅជាបង ។

**អញ្ច៑** ធាតុ. អញ្ចតិ ; អច្យតេ ; អញ្ចយតិ ; អញ្ចិត (អចិត) : ទៅ ថ្វាយបង្គំ គំនាប់; បញ្ចូមីវិភត្តិ ផលិត; ងះឡើង; (សក់) កន្លាញ់; អញ្ចិតគតៈ ខ្ពង់ខ្ពស់, ខ្លាំងក្លា ។

**អញ្ចន** នបុំ. កិរិយាធ្វើឲ្យងះឡើង ។

**អញ្ចល** បុំ. ជាយសំពត់ ជាយក្រមា; ការក្រឡេកភ្នែក, រមិលភ្នែក ។

**អញ្ជ៑** ធាតុ. អនក្តិ អង្ក្តេ; អជ្យតេ; អញ្ជយតិ; អក្ត អញ្ជិត : លាបលន, រិត ស្រឡាប ។

**អញ្ជន** នបុំ. កិរិយាលាប, ថ្នាំសម្រាប់លាប (កែរោគ) ថ្នាំឈឺភ្នែក, ថ្នាំលាបឲ្យមានពន្លឺ (សម្រាប់ភ្នែក) ។ បុំ. បិតានៃព្រះភគវន្ត; ឈ្មោះភ្នំ; ដើមឈើ ឬ ដំរី ។ អញ្ជនា, ស្ត្រី. មាតានៃហនុមន្ត ។ – *កេឝ–កេឝី* គុ. ដែលមានសក់ខ្មៅដូចអញ្ជន ។ – *គិរ*, – *បវ៌ត*, អញ្ជនាចល, អញ្ជនាទ្រិ បុំ. ឈ្មោះភ្នំ ។ – *បវ៌ន* បុំ. ឈ្មោះរាក្សសៈ ។

---

(នៅមានត)